# ការស្វែងរកផ្លូវ របស់ខ្ញុំ

## រឿងនិទានអំពីការជ្រើសរើសផ្លូវដើររបស់អ្នក




The Vanguard Series

# បុព្វកថា

“ជោគវាសនាមិនមែនជាបញ្ហាឱកាសទេ វាគឺជាបញ្ហានៃជម្រើស។ វាក៏មិនមែនជាអ្វីដែលគេរង់ចាំនោះដែរ តែគឺជាអ្វីដែលគេត្រូវខំសម្រេចឱ្យបាន។

William Jennings Bryan

ជីវិតផ្តល់ជម្រើសជាច្រើនដល់យើងរៀងរាល់ថ្ងៃ ប៉ុន្តែជម្រើសខ្លះមិនត្រូវបានគេទទួលយកឡើយ។ តាមរយៈរឿងនេះ អ្នកនឹងឃើញថាតើភាពក្រីក្រ និងកង្វះឱកាសអាចបង្ខំមនុស្សម្នាក់ៗឱ្យធ្វើការសម្រេចចិត្តដែលដ៏ពិបាកដូចម្តេចខ្លះ សូម្បីតែការសម្រេចចិត្តដែលមិនអាចគិតដល់ក៏ដោយ គឺដើម្បីតែការរស់រានមានជីវិតប៉ុណ្ណោះ។ តាមរយៈរឿងនេះអ្នកក៏ទទួលបានលទ្ធផលដែលជាការប្រថុយនឹងគ្រោះថ្នាក់បំផុត។តាមរយៈការចែករំលែកសៀវភៅនេះ និងការពិភាក្សាលើប្រធានបទនេះអ្នកអាចជួយអ្នកដទៃ នៅក្នុងសហគមន៍របស់អ្នកឱ្យមានការយល់ដឹងអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដែលពុំមានសុវត្ថិភាព និងការជួញដូរមនុស្សហើយជំរុញឱ្យពួកគាត់ធ្វើសកម្មភាពនិងបង្កើតឱ្យមានការផ្លាស់ប្តូរសម្រាប់មនុស្សដទៃទៀតនៅលើពិភពលោក។

នៅក្នុងរឿងនេះ គេតម្រូវឱ្យអ្នកដើរតួជាតួអង្គស្រីម្នាក់ដែលរស់នៅក្នុងទ្វីបអាស៊ីខាងកើត។ បញ្ហាប្រឈមរបស់អ្នកតំណាងឱ្យបទពិសោធន៍នានាដែលយុវជនជាច្រើនទៀតបានជួបប្រទះនៅក្នុងតំបន់នេះ។តាមរយៈការប្រឡូកទៅក្នុងឆាកជីវិតរបស់តួអង្គនេះអ្នកនឹងឃើញដោយខ្លួនឯងថា សូម្បីតែអ្នកធ្វើការសម្រេចចិត្តលើជម្រើសតូចមួយក៏ដោយ ក៏អាចជះឥទ្ធិពលទៅលើទិសដៅនៃជីវិតរបស់អ្នកដែរ។

សូមជម្រាបថាឈុតខ្លះមិនបានបញ្ចប់ដោយរីករាឡើយ ហើយទីបំផុតអ្នកអាចទទួលបានបទពិសោធន៍មួយ គឺអារម្មណ៍ទាល់ច្រកមិនដឹងជាសម្រេចចិត្តយ៉ាងណា។ ធ្វើយ៉ាងណាត្រូវឆ្លៀតពេលឆ្លុះបញ្ចាំងពីអារម្មណ៍ទាំងនោះដោយអានសំណួរទាំងអស់ដែលមាននៅពេលបញ្ចប់រឿង។

សៀវភៅនេះត្រូវផ្អែកលើរឿងពិត។ រឿងនេះគឺសម្រាប់យុវជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ហើយប្រហែលជាមិនសមស្របសម្រាប់កុមារតូចឡើយ។

Vanguard Series ត្រូវបានរៀបចំឡើងដើម្បីរួមបញ្ចូលធនធាននិងឧបករណ៍ថ្មីៗសម្រាប់ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដែលពុំមានសុវត្ថិភាព ដែលត្រូវបានបង្កើតឡើងដោយកម្មវិធីបញ្ឈប់ការជួញដូរមនុស្សរបស់អង្គការទស្សនៈពិភពលោក (ETIP)។ ធនធានសៀវភៅដែលមានលក្ខណជាការប្រាស្រ័យទាក់ទងគ្នានេះ ត្រូវបានរៀបចំឡើងដោយ Vanguard Series ដើម្បីធ្វើឱ្យយុវជនមានសមត្ថភាពប្រើប្រាស់មេរៀន ដែលខ្លួនបានចេះដឹងពីក្នុង Smart Navigator និង Voice Up for Change Toolkits។

# ការស្វែងរកផ្លូវរបស់ខ្ញុំ

## រឿងនិទានអំពីការជ្រើសរើសផ្លូវដើររបស់អ្នក

### ការសម្រេចចិត្តក្នុងការផ្លាស់ប្តូរជីវិត



អ្នកកំពុងអង្គុយនៅពីមុខមនុស្សប្រុសដែលសង្ហារជាងគេក្នុងលោក ហើយអ្នកជឿទេថាគាត់ពិតជាចាប់អារម្មណ៍លើអ្វីដែលអ្នកកំពុងនិយាយ។

អ្នកបានរៀបចំទៅជួបមិត្តជិតស្និទ្ធរបស់អ្នកឈ្មោះ សូរិយាដើម្បីទៅញ៉ាំទឹកក្រឡុក ហើយនិយាយគ្នាលេងដូចសព្វដង។ បន្ទាប់មកអ្នកពិតជាស្រឡាំងកាំងនៅពេលដែលមិត្តរបស់អ្នកនាំប្រុសស្អាតម្នាក់ចូលមកដែរ ហើយបានណែនាំថាគេឈ្មោះណារិនជាបងប្អូនជីដូនមួយរបស់នាងដែលមកពីទីក្រុង។ ពីមុនមកសូរិយាធ្លាប់និយាយពីគេដែរ តែនាងគ្រាន់តែប្រាប់ថាបងប្អូនជីដូនមួយរបស់នាងមានអាយុ១៦ឆ្នាំ ហើយបានទៅធ្វើការឆ្លងដែន។ គេមានអាយុទើបតែ ១៦ឆ្នាំមានន័យថាគេបងអ្នកតែ ១ឆ្នាំតែប៉ុណ្ណោះតែគេបែរជាមានសំលៀកបំពាក់ស្អាតៗ មានទូរសព្ទដៃទំនើបប្រើ ហើយមានម៉ូតសក់ស្រស់ស្អាតទៀតផង។ គេប្រហែលជាមកពីស្រុកផ្សេងហើយ។

ឥឡូវនេះអ្នកកំពុងតែនិយាយពីបញ្ហារបស់អ្នកពេលនៅផ្ទះ (និយាយតែពេលដែលសូរិយាសួរ) ហើយពួកគេបានបញ្ចុះបញ្ចូលអ្នក។ ណារិនហាក់ដូចជាកំពុងតែរកលេសដើម្បីចេញទៅវិញ (ឬគេកំពុងតែផ្ញើរសារទៅមិត្តភក្តិរបស់គេ) តែគេនៅតែស្តាប់។

អ្នកប្រាប់ពួកគេថា“យើងតែងតែបានលុយមកពីត្រី ដែលឪពុករបស់ខ្ញុំចាប់បានហើយយកទៅលក់នៅផ្សារ”។ តែនៅពេលដែលពុករបស់ខ្ញុំឈឺគាត់មិនអាចជួសជុលសំណាញ់បានទៀតឡើយ ហើយពុកឧស្សាហ៍ចេញទៅរកត្រីទាំងពេលដែលសុខភាពគាត់មិនសូវជារឹងមាំ។ ម្តាយខ្ញុំ ប្អូនស្រីខ្ញុំ និងខ្ញុំតែងព្យាយាមចាប់ក្រែងត្រីបានខ្លះតែសំណាញ់កាន់តែចាស់ណាស់ទៅហើយ។ ទីបំផុតឪពុកខ្ញុំក៏បានទៅខ្ចីលុយគេដើម្បីជួសជុលសំណាញ់ ក៏ប៉ុន្តែពុកខ្ញុំមិនអាចរកលុយសងគេទាន់ពេលឡើយ។ ម្ចាស់បំណុលកំពុងតែទារការប្រាក់ខ្ពស់ពីឪពុកខ្ញុំ ហើយខ្ញុំពិតជាមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទើបអាចសងលុយគេវិញបាន។ ចំណែកពុកហាក់ដូចជាឆេវឆាវគ្រប់ពេល។ ខ្ញុំពិតជាមិនអាចទ្រាំនៅផ្ទះបានឡើយ។ ខ្ញុំស្អប់ខ្លាំងណាស់ពេលដែលពុកស្រែកដាក់ម៉ែ និងពួកខ្ញុំ។ ក្នុងនាមខ្ញុំជាកូនច្បងក្នុងគ្រួសារ ខ្ញុំគិតថាខ្ញុំត្រូវតែឈប់រៀនហើយរកការងារធ្វើ។”



សូរិយាមើលទៅដូចជារន្ធត់ណាស់ នាងហាក់ដូចជាមិនជឿនូវអ្វីដែលនាងបានលឺឡើយ។

នាងសួរទាំងដង្ហក់ថា“ឯងនិយាយលេងទេអី?ឯងរៀនពូកែសឹងអី។ឯងមិនត្រូវឈប់រៀនទេ”

អ្នកគំហកនាងវិញថា “អញ្ចឹងអោយខ្ញុំធ្វើម៉េចទៅ?” សម្លេងរបស់អ្នកចាប់ផ្តើមអួល ហើយអ្នកមានអារម្មណ៍ថាអ្នកមិនអាចទប់ទឹកភ្នែកបាន។ អ្នកសឹងតែមិនជឿថាអ្នកស្ទើរតែនឹងសម្រក់ទឹកភ្នែកនៅពីមុខប្រុសម្នាក់នោះទៅហើយ។ អ្នកក៏មានអារម្មណ៍ល្អឡើងវិញ ក្រោយពីបានស្រែកដាក់សូរិយា។ អ្នកចាប់ដៃរបស់នាង។

អ្នកក៏និយាយថា “ឱ្យខ្ញុំសុំទោសផងណាសូរិយា”ហើយអ្នកព្យាយាមញញឹម។ តែនាងនៅតែគ្រវីក្បាលរបស់នាង ។

នាងនិយាយថា “ខ្ញុំសង្ឃឹមថាពាក្យដែលឯងនិយាយទាំងប៉ុន្មានសុទ្ធតែជាការលេងសើច។ តែនាងអាចមើលដឹងតាមរយៈខ្សែភ្នែករបស់អ្នកថា អ្នកមិនមែនកំពុងតែលេងសើចឡើយ។

ក្រោយមក ណារិនដែលមិនទាន់បាននិយាយតាំងពីគេចូលមកអង្គុយក៏

បាននិយាយជាលើកដំបូងថា "បើប្អូនសម្រេចចិត្តថាចង់ធ្វើការឆ្លងដែនកុំភ្លេចទូរសព្ទមកបង"

រំពេចនោះស្រាប់តែសូរិយាសម្លឹងបងជីដូនមួយនាងហើយនិយាយថា "អេ! ម៉េចបានជាបងមិនជួយលើកទឹកចិត្តនាង?"

ណារិនញញឹមលាយអៀនហើយតបវិញថា "បងគ្រាន់តែនិយាយតើ! បងគិតថាល្អបើសិនជាឯងមានអ្នកស្គាល់ស្រាប់ ពេលឯងទៅដល់ទីក្រុងធំ។"

អ្នករៀបនឹងអរគុណបងជីដូនមួយសូរិយា ស្របពេលដែលសូរិយាឈានជើងចេញ។ សូរិយា កំពុងតែគេចចេញពីកិច្ចសន្ទនានេះ ហើយធ្វើដូចជាគ្មានរឿងអ្វីកើតឡើងឡើយ។

នាងនិយាយថា៖ "ក្រោកឡើង! ទៅលេងនៅក្រៅវិញ។"

◈◈◈

អ្នកក៏បានទៅផ្ទះមិត្តរបស់អ្នករាំបទដែលអ្នកចូលចិត្ត ហើយក៏សើច។ ដំបូងឡើយអ្នករាំជាមួយសូរិយាទេ តែនាងបានលួងលោមណារិនឱ្យចូលមករាំដែរ។ អ្នកធ្វើជាមិនដឹងថា ណារិនកំពុងតែតាមមើលអ្នក។ ល្ងាចនេះអ្នករីករាយបំផុត និងជាពេលដែលធ្វើឱ្យអ្នកចងចាំ។ អ្នកពិតជាមិនចង់ឱ្យពេលវេលាសប្បាយបែបនេះចប់ទេ ទោះដឹងច្បាស់ថា ឪពុកអ្នកនឹងខឹងអ្នកនៅពេលអ្នកទៅដល់ផ្ទះក៏ដោយ។

នៅពេលដែលអស់ចម្រៀង អ្នកសម្រាកបន្តិចហើយក៏ទទួលទឹកពី ណារិន។

អ្នកសួរណារិនថា៖ ពេលណាទើបបងទៅវិញ?

ណារិនតបទាំងទឹកមុខស្រពោនថា "បងទៅវិញនៅថ្ងៃស្អែក។ បើសិនជាប្អូនចង់ទៅទីក្រុងធំ ប្អូនត្រូវទាក់ទងមកបងណា។ នេះលេខទូរសព្ទរបស់បង។"

អ្នកក៏បានយកលេខទូរសព្ទរបស់គេ ហើយកត់ចូលក្នុងទូរសព្ទរបស់អ្នក។ ទោះបីជាអ្នកមិនចង់ត្រលប់ទៅផ្ទះវិញតែអ្នកត្រូវតែទៅ។

អ្នកឱបសូរិយាហើយប្រាប់ថាចាំជួបគ្នាពេលក្រោយទៀត។

អ្នកក៏បាននិយាយថាលាទៅកាន់ណារិន ហើយអ្នកមានអារម្មណ៍ថាមិនស្រួលចិត្តសោះរហូតទាល់តែណារិនឱនខ្សឹបថា ជួបគ្នាម្តងទៀតនៅពេលក្រោយ។

◈◈◈

អ្នករត់ត្រលប់មកផ្ទះវិញហើយបើកទ្វារថ្នមៗតាមដែលអាចធ្វើទៅបាន។អ្នកក៏បានធូរចិត្តខ្លះព្រោះឪពុករបស់អ្នកសម្រាន្តលង់លក់នៅលើកៅអី។អ្នកដើរលបៗកាត់គាត់ហើយប្រយ័ត្នមិនឱ្យទាត់ដប ស្រាបៀរដែលនៅជុំវិញកៅអីដែលពុកអ្នកសម្រាន្ត។ពេលនោះអ្នកស្រាប់តែឈប់ហើយសម្លឹងមើលមុខរបស់ឪពុកអ្នក។អ្នកមិនឃើញមានសញ្ញាណាមួយនៅលើមុខគាត់បង្ហាញពីកំហឹងដូចសព្វដងឡើយ។ នេះជាអ្វីដែលអ្នកតែងតែចងចាំអំពីគាត់។ អ្នកចង់ឱ្យគាត់បែបនេះរហូតទៅ។

នៅយប់នោះអ្នកយល់សប្តិឃើញរាំជាមួយសូរិយា និងណារិន តែឃើញណារិនបែរខ្នងដាក់អ្នក។អ្នកវាយស្មាគាត់ ហើយពេលគាត់បែរមកស្រាប់តែអ្នកស្រឡាំងកាំង ព្រោះគេមិនមែនជាណារិនឡើយ តែបែរជាលោកស្នេកគីម្ចាស់បំណុលកំណាចទៅវិញ។ ពេលនោះអ្នកក៏ថយក្រោយរហូតជំពប់ជើងដួល តែម្ចាស់បំណុលកំណាចលោកស្នេកគី នៅតែមកតាមអ្នកហើយស្រែកខ្លាំងៗ សួររកលុយដែលអ្នកជំពាក់។ នៅពេលអ្នកដឹងខ្លួន ទើបអ្នកដឹងថាសម្លេងដែលអ្នកបានឮជារបស់ពុកអ្នក។ គាត់បានស្រែកខ្លាំងៗទៅកាន់ម្តាយរបស់អ្នកក្នុងបន្ទប់គាត់។ អ្នកក៏ទាញភួយគ្របក្បាល ហើយខ្ទប់ត្រចៀក។

◈◈◈

នៅថ្ងៃបន្ទាប់ តាមផ្លូវទៅផ្ទះរបស់សូរិយា អ្នកបានឃើញប័ណ្ណប្រកាសលើក្តារខៀនភូមិអ្នក។

## តើកំពុងរកការងារធ្វើមែនឬទេ?

នៅលើប័ណ្ណប្រកាសមានលេខទូរសព្ទរបស់ឈ្មោះ ដេវី។ តើនេះជាសញ្ញាអ្វីមែនទេ? តើនេះជាចម្លើយដែលអ្នកកំពុងតែស្វែងរកមែនទេ? អាទិត្យក្រោយចូលរៀនវិញហើយ តែអ្នកត្រូវធ្វើការសម្រេចចិត្តឱ្យបានឆាប់។នេះជាការសម្រេចចិត្តដ៏ធំបំផុតក្នុងជីវិតរបស់អ្នក។ អ្នកកត់លេខទូរសព្ទយ៉ាងលឿន ហើយបន្តដំណើរទៅមុខទៀត ។

ពេលដែលអ្នកទៅដល់ផ្ទះសូរិយាអ្នកក៏ប្រាប់នាងពីប័ណ្ណប្រកាសដែលអ្នកបានឃើញ ហើយពេលនោះសូរិយាក៏ចាប់ផ្តើមសង្ស័យ។

នាងបានហាមអ្នកថា "ឯងត្រូវតែប្រយ័ត្នប្រយែងជាមួយអ្នកដែលឯងត្រូវទាក់ទងជាមួយ។ បើមិនអញ្ចឹងទេឯងនឹងមានបញ្ហាហើយ។"

នៅពេលដែលអ្នកទម្រេតខ្លួននៅលើគ្រែក្នុងបន្ទប់របស់សូរិយាអ្នកញញឹមទៅកាន់មិត្តអ្នកមិនចេញឡើយ។ តាមដែលអ្នកស្គាល់នាងជាមនុស្សម្នាក់ដែលមាន

ហេតុផលបំផុតហើយមានសណ្ដាប់ធ្នាប់។ដោយសារតែអ្នកមិនសូវចេះចាត់ចែង ទើបអ្នកមិនសូវជាដឹងថាត្រូវធ្វើអ្វី។ ពេលនេះសូរិយាកំពុងយកក្រដាស និងប៊ិច មកអង្គុយសរសេរពីអ្វីដែលមនុស្សម្នាក់ត្រូវពិចារណាក្នុងករណីគេចង់ឆ្លងដែន ទៅធ្វើការនៅក្រៅប្រទេស។

សូរិយានិយាយថា"ឯងត្រូវតែរៀបចំការងារឱ្យបានច្បាស់លាស់មុនពេលដែល ឯងចេញទៅហើយនាងបានសរសេរធំៗថា"ការងារ"ជាអក្សរដិត។"នាងបានបន្ថែម ថា "ឯងត្រូវតែរត់ការរឿងនេះតាមរយៈមជ្ឈមណ្ឌលជ្រើសរើសបុគ្គលិក។ បន្ទាប់ មកឯងត្រូវមានលិខិតឆ្លងដែន និងទិដ្ឋាការការងារ។ ឯងក៏ត្រូវសន្សំលុយខ្លះ សម្រាប់អាហារ និងការស្នាក់នៅ ក៏ដូចជាការចំណាយផ្សេងទៀត។"

អ្នកក៏បានថ្ងូរថា "មានរឿងជាច្រើនដែលត្រូវធ្វើ។ ស្ដាប់ទៅដូចជាត្រូវប្រើ ពេលយូរណាស់ដើម្បីធ្វើរឿងទាំងអស់នេះ។" និយាយទៅអ្នកមិនទាន់បានគិតពី រឿងអស់នេះនៅឡើយទេ។

សូរិយាបានតបវិញថា "ត្រូវហើយ! តើឯងចង់បានអ្វី? តើឯងមិនដឹងថានេះ ជារឿងធំទេហ្អេស?"

ស្រាប់តែអ្នកទប់មិនខឹងមិនបាន ហើយអ្នកក៏តបទៅវិញថា "អើ! មែនហើយ សូរិយាអ្វីដែលពួកយើងកំពុងនិយាយនេះជារឿងយើងទេ។ យើងយល់អស់ហើយ។"

នាងក៏និយាយថា "ឱ្យយើងសុំទោស។ យើងគ្រាន់តែមិនចង់ឱ្យឯងទៅតែ ប៉ុណ្ណោះ។"

អ្នកញញឹមហើយចាប់ដៃនាងរួចនិយាយថា "យើងពិតជាមានសំណាងណាស់ ដែលមានមិត្តដូចជាឯង។"

នាងតបទាំងញញឹមថា "សំណាងជាងឯងគិតទៅទៀត។" ហើយនាងក៏ទុក ក្រដាស និងប៊ិចទៅម្ខាងរួចនិយាយថា "បានហើយ! ឈប់និយាយពីរឿងហ្នឹង ទៀតទៅ។ ឥឡូវប្រាប់យើងមក ឯងកំពុងគិតយ៉ាងម៉េចចំពោះណារិន។"

អ្នកមានអារម្មណ៍ថាមុខរបស់អ្នកឡើងក្រហម ហើយអ្នកក៏បានយកដៃខ្ទប់ មុខ។

សូរិយាចាប់បានហើយនិយាយថា "យើងដឹងហើយ។ យើងអាចប្រាប់ពី ដំណើរដើមទងបាន។ ឯងអាចយកក្រោយនេះដើម្បីនិយាយពីណារិន ហើយ សួរពីអ្វីដែលឯងចង់ដឹងប៉ុណ្ណាក៏បាន។"

សូរិយាមិនសូវជាដឹងច្បាស់ពីណារិនប៉ុន្មានទេ តែនាងគិតថាគេមានការងារ

ល្អនៅទីក្រុងធំ។

នាងសួរថា "តើឯងទៅរកគាត់ឬក៏អត់នៅពេលដែលឯងទៅទីនោះ? កុំប្រាប់ ណាថាឯងមិនទៅរកគេ។" សួររួចនាងក៏ញញឹម។

អ្នកក៏ញញឹម តែមើលទៅសូរិយាហាក់ដូចជាប្រាកដប្រជាទៀតហើយ។

សូរិយានិយាយថា "សន្យានឹងយើងបានអត់ថាកុំទៅអី ព្រោះណារិននៅទីនោះ។"

អ្នកបានតបវិញថា "មិនបាច់បារម្ភទេ។ យើងមិនគិតឡើយបើសិនជានៅផ្ទះមានរឿងមិនល្អ។"

សូរិយានិយាយថា "អញ្ចឹងឯងនៅមានជម្រើសផ្សេងទៀត ត្រូវអត់?"

អ្នកតបថា "មានមែនអត់? មានជម្រើសអីខ្លះ?"

សូរិយានិយាយថា"គឺកុំទៅនៅហ្នឹងជាមួយយើងហើយ។យើងនឹងជួយដោះស្រាយបញ្ហារបស់ឯង។ ហើយយើងអាចសន្សំលុយជាមួយគ្នា។"

អ្នកបែរជាចង់យំនៅពេលដែលឮនាងនិយាយបែបនេះ។ អ្នកក៏បានតបថា "ដឹងម៉េចអត់? មនុស្សដូចយើងនេះ មិនសមមានមិត្តដូចជាឯងទេ។"

សូរិយានិយាយទាំងសើចថា៖ វាត្រូវតែអញ្ចឹងហើយ។

◈◈◈

នៅតាមផ្លូវទៅផ្ទះ អ្នកក៏បានទទួលសារ ពីណារិន

**ណារិន៖** ទើបតែដឹងថាលេខទូរស័ព្ទ
ដែលប្អូនឱ្យបងជាលេខប្អូនមែន ☺

**អ្នក៖** អ្នកណាហ្នឹង?

**អ្នក៖** និយាយលេងទេ ☺ ។ ចាសគឺខ្ញុំ។
បងចេញទៅឬនៅ?

**ណារិន៖** បាទ!! កំពុងតែនៅលើឡាន។
ម៉េចបានជាបងបានជួបប្អូន នៅយប់
ចុង ក្រោយរបស់បងទៅវិញ? ☹

**អ្នក៖** ដឹងថាបងនិយាយពាក្យនេះ
ជាមួយស្រីគ្រប់គ្នាហ្នុំង☺☺☺!!!

**ណារិន៖** អត់ទេ!!!!!

**អ្នក៖** ☺

**ណារិន៖** បងសង្ឃឹមថាពួកយើងនឹងជួបគ្នាម្តងទៀត!

**អ្នក៖** អរគុណ!! តែខ្ញុំមិន
ច្បាស់ថាខ្ញុំត្រូវធ្វើអ្វីទេ!!

**ណារិន៖** នៅបន្តទាក់ទងគ្នាណា!!!!

**អ្នក៖** ☺

ប៉ុន្មានម៉ោងក្រោយមក ស្រាប់តែអ្នកមកអង្គុយនៅពីមុខបុរសម្នាក់ក្នុងតៀមកាហ្វេមួយ។ គេឈ្មោះដេវីជាអ្នកដែលបានបិទប័ណ្ណប្រកាស។វាហាក់ដូចជាលឿនពេករហូតអ្នកគិតថា ខ្លួនឯងមិនដឹងកំពុងតែធ្វើអ្វី។ អ្នកបានសម្រេចចិត្តទូរសព្ទទៅគាត់ ហើយគាត់ក៏សម្រេចចិត្តមកជួបអ្នក។ តើអ្នកកំពុងធ្វើអ្វីហ្នឹង? ចង់និយាយជាមួយបុរសម្នាក់នោះឬ?

នៅពេលនោះអ្នកស្រាប់តែគិតមិនឃើញថា តើអ្នកត្រូវបដិសេធយ៉ាងណា ដូច្នេះហើយទើបអ្នកយល់ព្រមជួបបុរសម្នាក់នោះ ហើយអ្នកគ្មានកន្លែងដែលត្រូវទៅដែរ។

អ្នកដូចជាចូលចិត្តដេវី។ គេសួរពីក្រុមគ្រួសាររបស់អ្នក ហើយគេហាក់ដូចជាមានការសោកស្តាយនូវអ្វីដែលបានកើតឡើងលើឪពុករបស់អ្នក។

គ្រប់ពេលដែលអ្នកប្រាប់គេពីរឿងប្រាក់ដែលគ្រួសាររបស់អ្នកជំពាក់ម្ចាស់បំណុលដ៏កំណាចនោះ គេគ្រវីក្បាលរបស់គេ ហើយនិយាយតិចៗដូចជាគេដឹងពីរឿងបំណុលនេះច្បាស់អញ្ចឹង។

អ្នកប្រាប់គាត់ថាអ្នកមិនទាន់បានសម្រេចចិត្តថាអ្នកធ្វើយ៉ាងណាឡើយ ប៉ុន្តែនាងកាន់តែមានសម្ពាធនៅផ្ទះ។ មិនយូរមិនឆាប់នាងត្រូវការប្រាក់ជាចាំបាច់ដោយមិនដឹងថាគួរទៅរកពីណាបានទេ។

ដេវីនិយាយថា “ពិតជាមិនល្អទាល់តែសោះ។ ខ្ញុំពិតជាអាណិតគ្រួសាររបស់នាងណាស់។ ប៉ុន្តែរឿងទាំងអស់នេះអាចកើតឡើងចំពោះគ្រប់គ្នា។ ខ្ញុំប្រហែលជាអាចជួយនាងឱ្យទៅធ្វើការឆ្លងដែនបាន ឬក៏មានចម្ងល់អ្វីដែលពាក់ព័ន្ធ នាងអាចសួរខ្ញុំបាន។”

អ្នកក៏បាននិយាយថា “អរគុណ! ខ្ញុំពិតជាអរគុណណាស់។ តែខ្ញុំមិនទាន់មានលិខិតឆ្លងដែនទេអញ្ចឹងមានរឿងជាច្រើនដែលខ្ញុំត្រូវធ្វើ។”

ឮបែបនេះ ដេវី ក៏ញញឹម ហើយនិយាយថា “មិនអីទេ! អាហ្នឹងក៏ខ្ញុំជួយបានដែរ។ យើងអាចធ្វើលិខិតឆ្លងដែនបានតែក្នុងរយៈពេលប៉ុន្មានថ្ងៃតែប៉ុណ្ណោះ។ អញ្ចឹងអាទិត្យក្រោយនាងអាចទៅធ្វើការនៅស្រុកក្រៅបានហើយ។“

អ្នកមិនអាចធ្វើអ្វីបានក្រៅពីភ្ញាក់ផ្អើល ហើយសួរគេថា៖ ពិតមែនហ្ន៎?

គេងក់ក្បាល ហើយញញឹម រួចនិយាយថា “ពិតមែនហើយ។ បើសិននាងចង់ឱ្យការងារសម្រេចបានកាន់តែរហ័សទៀតនោះ សូមទាក់ទងខ្ញុំ ហើយខ្ញុំដឹងថាត្រូវធ្វើអ្វីខ្លះទៀត។”

◈◈◈

នៅតាមផ្លូវត្រឡប់មកពីតៀមកាហ្វេវិញ អ្នកនៅតែមានអារម្មណ៍ច្របូកច្របល់ពីរឿងមួយចំនួន តែយ៉ាងហោចណាស់ក៏អ្នកមានអារម្មណ៍ថាការងារអាចដំណើរការបានលឿន នៅពេលដែលអ្វីៗមានភាពប្រាកដប្រជា។

អ្នកសម្រេចចិត្តទៅផ្ទះដោយដើរកាត់តាមផ្សារដើម្បីទៅមើលថា ម្ដាយនិងប្អូនស្រីរបស់អ្នកនៅ ទីនោះដែរ ឬអត់។ កាលពីព្រឹកមិញម្ដាយរបស់អ្នកចាប់បានត្រីតិចតួចដែរ ហើយអ្នកដឹងថា គាត់យកត្រីទាំងនោះទៅលក់នៅផ្សារ។ ពេលដែលអ្នកទៅដល់គាត់កំពុងតែរើតួប។

អ្នកសួរខ្លួនឯងថាៈ មានលាភអត់?

ម្ដាយរបស់អ្នកញោចស្នាបន្តិច ហើយព្យាយាមញញឹម។ មើលទៅគាត់ដូចជាអស់កម្លាំងណាស់ព្រោះគាត់ត្រូវរវល់ពេញមួយថ្ងៃ ហើយត្រូវឆ្លៀតមើលប្អូនតូចរបស់អ្នកទៀត។

នៅតាមផ្លូវត្រលប់ទៅផ្ទះវិញ អ្នកប្រាប់ម្ដាយរបស់អ្នកពីរឿងដែលអ្នកកំពុងតែចង់ឈប់រៀនហើយទៅធ្វើការ។ គាត់ឈប់បន្តិច រួចសម្លឹងមើលអ្នក។

គាត់សួរអ្នកថា “តើឯងគិតថាឯងអាចធ្វើអ្វីបាន បើឯងរៀនមិនទាន់ចប់ផងហ្នឹង?”

អ្នកតបថា “ខ្ញុំដឹង! ខ្ញុំដឹងតើម៉ែ!”

នេះជាការជជែកគ្នាដែលអ្នកធ្លាប់បានធ្វើពីមុនមក។ អ្នកចង់តែស្រែកថា “ពេលខ្លះយើងត្រូវតែធ្វើអញ្ចឹង។ យើងមិនអាចរស់នៅបែបនេះទៀយ។” តែអ្នកបានត្រឹមតែប្រាប់ខ្លួនឯងថាអ្នកមិនគួរនិយាយនៅពេលនេះឡើយ។ អ្នកក៏បាននិយាយទៅប្អូនស្រីអ្នកថា “ណៃ! ស៊ីតា! នាំគ្នារត់ប្រណាំងទៅទន្លេហ្អី?”

អ្នកក៏បានទៅឈរនៅខាងក្រោយប្អូនស្រីរបស់អ្នក ហើយងាកមកស្រែកប្រាប់ម្ដាយរបស់អ្នកថា “ចាំទៅជួបគ្នានៅផ្ទះណាម៉ែ។”

គាត់លើកដៃ ហើយញញឹមដាក់អ្នក។ អ្នកពិតជាចូលចិត្តស្នាមញញឹមមួយនោះណាស់។

◈◈◈



ពេលជិតមកដល់ផ្ទះ ស៊ីតាកំពុងនិទានរឿងរវាងព្រះនាងម្ចាស់ និងសត្វខ្លា (ជាសត្វដែលគួរឱ្យខ្លាចតែមានបេះដូងស្រស់ស្អាត) ពេលដែលកំពុងតែស្ថិតក្នុងភាពដ៏សែនស្មុគស្មាញ ស្រាប់តែអ្នកទាំងពីរឈប់ង៉ក់ព្រោះ តែលឺសម្លេងអ្វីម៉្យាងចេញពីផ្ទះរបស់អ្នក។ អ្នកដឹងច្បាស់ណាស់ថាវាជាសម្លេងឪពុកម្តាយរបស់អ្នកដែលកំពុងតែប្រកែកគ្នាយ៉ាងខ្លាំង។

អ្នកទម្លាយទ្វារចូលទៅ ហើយឃើញពុកម៉ែរបស់អ្នកកំពុងតែប្រតាយប្រតប់គ្នា។អ្នកអាចដឹងភ្លាមៗថាកំពុងតែមានរឿងអ្វីកើតឡើង។ឪពុករបស់អ្នកកំពុងតែប្រឹងទាញកាបូបពីម្តាយអ្នក។ គាត់ចង់យកលុយដែលម្តាយរបស់អ្នកបានមកពីលក់ត្រីនៅផ្សារ តែម្តាយអ្នកមិនព្រមឱ្យ។

ម្តាយអ្នកស្រែកថា “ខ្ញុំមិនឱ្យទេ! លុយនេះខ្ញុំទុកទិញម្ហូប ហើយសងគេ។ លុយនេះមិនមែនសម្រាប់ឯងទិញស្រាផឹកទេ។”

តែពុករបស់អ្នកដែលមើលទៅដូចជាស្រវឹងស្រឿងៗផងនោះមិនព្រមឈប់ងាយៗឡើយ។

ឪពុកអ្នកស្រែកជំទាលថា “ឱ្យលុយមកអញភ្លាម!”

ពេលនោះស្រាប់តែមុខគាត់ប្រែជាក្រហមពេញដោយកំហឹងខ្លាំង។

អ្នកទៅទ្រោបលើខ្នងរបស់គាត់ ហើយព្យាយាមទាញគាត់ចេញ។ សំណាង ហើយដែលឥទ្ធិពលគ្រឿងស្រវឹងធ្វើឱ្យគាត់មិនសូវមានកម្លាំង។ គាត់ដូចជាចង់ដួល ដោយសារតែកម្លាំងទាញរបស់អ្នក ក្រោយមកគាត់ក៏ដួលទៅលើកៅអី។ គាត់បន្ត ស្រែកជេរពីកៅអី តែក្រោយមកគាត់ក៏ឈប់ព្រោះតែគាត់បានឃើញសភាពរបស់ ស៊ីតាដែលឈរអោនមុខយំនៅកៀនទ្វារ។ គាត់បានហុចដៃទៅស៊ីតា ហើយ ប្រាប់នាងឱ្យមកជិតគាត់។ តែនាងខ្លាច ហើយរត់ទៅឱបម្ដាយរបស់អ្នក។ ទឹកមុខ ពុករបស់អ្នកនៅពេលនោះធ្វើឱ្យអ្នកមិនអាចភ្លេចបានឡើយ។ គាត់ឱនមុខចុះ ហើយស្រែកយំ។ អ្នកអង្គុយចុះជិតគាត់ ហើយចាប់ដៃរបស់គាត់។ នៅពេលនោះ អ្នកប្រាកដចិត្តថាអ្នកគួរតែធ្វើអ្វីម្យ៉ាង។

ដល់ពេលអ្នកត្រូវតែសម្រេចចិត្តហើយ។ អ្នកគិតម្ដងហើយម្ដងទៀត ហើយ ពេលនេះ ពុករបស់អ្នកសម្រាន្តលក់នៅក្បែរអ្នក ហើយម្ដាយ និងប្អូនស្រីរបស់អ្នក កំពុងតែលង់លក់ក្នុងដំណេក។ អ្នកបានសម្រេចចិត្តពីអ្វីដែលអ្នកត្រូវតែធ្វើ។



**បើសិនជាអ្នកសម្រេចចិត្តថាត្រូវ ពឹងពាក់ ជេរីសូមចូលទៅកាន់ ទំព័រទី ១២**

**១២**



**បើសិនជាអ្នកសម្រេចចិត្តថា ធ្វើ តាមដំបូន្មានរបស់សូរិយា ហើយ ចាប់ផ្តើមចាត់ចែងការងារសូម ទៅកាន់ទំព័រទី២៧**

**២៧**

# នៅតាមផ្លូវនៅឆ្ងាយពីផ្ទះ



នៅព្រឹកបន្ទាប់ អ្នកទូរសព្ទទៅដេវី។ រឿង៉រាវនៅផ្ទះកាន់តែយ៉ាប់យ៉ឺនឡើង។ អ្នកគិតថា អ្នកត្រូវតែធ្វើអ្វីម្យ៉ាងហើយទើបបាន។

គាត់និយាយថាគាត់យល់ពីបញ្ហានេះ ហើយសួរពីប្រភេទការងារឆ្លងដែនដែលអ្នកចង់ធ្វើ។

អ្នកប្រាប់គាត់ថា អ្នកមិនប្រកាន់ការងារទេអ្វីក៏អ្នកអាចធ្វើបានដែរ ព្រោះអ្នក មិនទាន់មានជំនាញអ្វីផងដោយសារតែអ្នកកំពុងនៅរៀននៅឡើយ។

គាត់សួរថា“តើនាងចេះមើលក្មេងតូចៗឬអត់? ចុះសម្អាតផ្ទះ? ការងារប្រភេទអញ្ចឹងៗ ចេះធ្វើឬអត់?”

អ្នកក៏ប្រាប់គេវិញថាការងារប្រភេទនេះសុទ្ធតែការងារដែលអ្នកចេះធ្វើ។ជាក់ស្តែងអ្នកបានធ្វើការងារនេះសឹងតែពេញមួយជីវិតរបស់អ្នកទៅហើយ ព្រោះអ្នកធ្លាប់មើលប្អូនរបស់អ្នកហើយជួយ ធ្វើការងារផ្ទះម្តាយរបស់អ្នក។

ដេវីក៏និយាយថា “ល្អណាស់ចឹង! ចឹងខ្ញុំសូមទូរសព្ទទៅគេបន្តិច ចប់កិច្ចការចាំខ្ញុំទូរសព្ទទៅវិញ។”

អ្នកអរគុណគាត់ ហើយពេលដែលរៀបនឹងដាក់ទូរសព្ទចុះ អ្នកស្រាប់តែ ឮសម្លេងសួរមកអ្នកថា“អូ!ខ្ញុំចង់សួរនាងរឿងមួយ!តើនាងមានប្រាក់ឬអត់? ប្រហែលជានាងត្រូវចំណាយប្រាក់ដើម្បីធ្វើដំណើរទៅកាន់ទីក្រុងធំនោះ ។

អ្នកមានអារម្មណ៍ខ្មាស់អៀននិយាយប្រាប់គាត់ពីចំនួនទឹកប្រាក់ ដែលអ្នកមាន។ ប្រាក់ដែលអ្នកបានសន្សំទុកពិតជាតិចតួចស្តួចស្តើងសម្រាប់ប្រើប្រាស់ក្នុងពេលមានអាសន្ន តែអ្នកក៏ដឹងដែរថាប្រាក់នេះមិនគ្រាន់សម្រាប់ការចំណាយទេ។

នៅពេលដេវីបានដឹងពីចំនួនទឹកប្រាក់ដែលអ្នកមាន គេបាននិយាយថា "មិនអីទេ! តែត្រូវចាំថា នាងត្រូវធ្វើដំណើរតាមទូក និងតាមឡាន។ ខ្ញុំគិតថាអ្វីដែលពួកយើងត្រូវធ្វើ គឺត្រូវឱ្យថៅកែថ្មីរបស់នាងចេញថ្លៃធ្វើដំណើរឱ្យនាងរួចចាំនាងធ្វើការសងគេវិញ។"

ស្ដាប់មើលទៅនេះគឺជាវិធីតែមួយគត់ដែលអ្នកអាចធ្វើបានដើម្បីធ្វើចំណាកស្រុកទៅកាន់ទីក្រុងធំ។ អ្នកអរគុណដេវីម្ដងទៀត រួចដាក់ទូរសព្ទចុះ។

ពេលនេះជាពេលដែលត្រូវមានរឿងធំ តើអ្នកត្រូវប្រាប់ម្ដាយរបស់អ្នក និងស្វរិយាពីការសម្រេចចិត្តរបស់អ្នកយ៉ាងម៉េច?

◈◈◈

អ្នកបានពិចារណាយ៉ាងល្អិតល្អន់ថាមិនត្រូវប្រាប់ម្ដាយរបស់អ្នកឡើយ។ អ្នកគិតថាអ្នកនឹងចាកចេញដោយមិនបាច់លា ហើយចាំប្រាប់គាត់ពេលដែលអ្នកទៅដល់ទីនោះ។តែពេលនោះស្រាប់តែអ្នកគិតថា គ្រួសារទាំងមូលប្រាកដជាភ័យស្លន់ស្លោ បើនៅសុខៗអ្នកស្រាប់តែបាត់ខ្លួន។ អ្នកក៏សម្រេចចិត្តប្រាប់ម្ដាយរបស់អ្នក។ ដូចអ្វីដែលអ្នករំពឹងទុកម្ដាយរបស់អ្នកមានប្រតិកម្មជាមួយនឹងអ្វីដែលអ្នកបានប្រាប់គាត់យ៉ាងខ្លាំង។ គាត់ព្យាយាមបញ្ចុះបញ្ចូលអ្នកឱ្យប្ដូរចិត្ត ហើយប្រាប់អ្នកថាប្រាកដជាមានវិធីផ្សេងដែលល្អជាងនេះ។

អ្នកសួរគាត់ថា "មានវិធីណាទៀតទៅម៉ែ? បើមានប្រាប់ខ្ញុំមក ខ្ញុំនឹងមិនទៅណាទេម៉ែ។"

គាត់និយាយថា "ចុះមីងបុប្ផាហ្ន៎?" ក៏ប៉ុន្តែទោះជាគាត់និយាយយ៉ាងណាក៏ដោយក៏អ្នកអាចមើលដឹងថាគាត់ជឿថានេះជាចម្លើយ។

គ្មាននរណាម្នាក់ហ៊ានប្រាប់អ្នកមីងបុប្ផាចិត្តល្អពីរឿងបំណុលដែលគ្រួសារអ្នកជំពាក់គេនោះទេ។ ហើយអ្វីដែលគាត់អាចជួយបានមិនលើសពីតំណក់ទឹកក្នុងទឹកសមុទ្រឡើយ។

ម្ដាយរបស់អ្នកនៅតែព្យាយាមនិយាយដើម្បីឱ្យអ្នកដូរចិត្ត ហើយព្យាយាមប្រាប់ថាឪពុករបស់អ្នក

ប្រហែលជិតទៅធ្វើការវិញហើយ។

អ្នកគ្រវីក្បាលហើយនិយាយថា "មែនហ្អីម៉ែ? តែមើលទៅគាត់ដូចជាកាន់តែយ៉ាប់ គ្មានអ្វីប្រសើរឡើងសោះ។" អ្នកពិជាពិបាកនឹងមើលម្ដាយរបស់អ្នករស់នៅក្នុងសភាពបែបនេះ។ គាត់មើលទៅដូចជាអស់សង្ឃឹមនឹងអ្នកណាស់។ គាត់ធ្លាប់

សង្ឃឹមខ្ពស់ចំពោះអ្នកពេលដែលអ្នករៀននៅសាលា ហើយគាត់ធ្លាប់សង្ឃឹមមុនពេលដែលមានរឿងអាក្រក់កើតឡើងថា អ្នកបានទៅរៀននៅមហាវិទ្យាល័យនឹងគេ។

អ្នកនិយាយទៅម្ដាយអ្នកដើម្បីលួងលោមគាត់ថា “កូនគ្រាន់តែសាកល្បង តើម៉ែ! បើសិនជាមិនកើតចាំកូនត្រលប់មកផ្ទះយើងវិញ ហើយចាំយើងព្យាយាមរកវិធីផ្សេងទៀត។”

ពេលនោះគាត់ក៏ឱបអ្នក។ ទោះបីជាគាត់មិនចង់ឱ្យអ្នកទៅក៏ដោយ តែគាត់ដឹងថាគាត់ត្រូវធ្វើ។

◈◈◈

សូរិយាប្រហែលជាមានប្រតិកម្មខ្លាំងជាងម្ដាយរបស់អ្នកទៀត។ អ្នកក៏សម្រេចចិត្តថា អ្នកនឹងប្រាប់នាង នៅពេលដែលអ្នកចេញពីកសិដ្ឋានពូនាង។ អ្នកសម្រេចចិត្តម្ដងទៀតថា អ្នកមិនប្រាប់នាងវិញព្រោះអ្នកដឹងថានាងនឹងមានប្រតិកម្មយ៉ាងម៉េច។ ស្រាប់តែដេវីទូរសព្ទមកប្រាប់អ្នកថាលិខិតរបស់អ្នកធ្វើរួចហើយ។ ហើយគេសង្ឃឹមថាគេនឹងអាចយកអ្នកចុះទូកនៅថ្ងៃបន្ទាប់។ អ្នកគិតថាអ្នកគួរតែនិយាយអ្វីម្យ៉ាង តែអ្នកមិនដឹងថាគួរនិយាយបែបណា។

នៅទីបំផុតអ្នកក៏របូតមាត់និយាយចេញមកថា “យើងសម្រេចចិត្តថាទៅហើយ។”

សូរិយានៅស្ងៀម ហើយសម្លឹងអ្នក។ នាងចំណាយពេលប្រហែលជាមួយសន្ទុះដើម្បីឱ្យប្រាកដចិត្តពីអ្វីដែលអ្នកកំពុងតែនិយាយ។ នាងគ្រវីក្បាលហើយរៀបនឹងនិយាយតប ស្រាប់តែពេលនោះនាងក៏បែរខ្នងហើយរត់ចេញទៅ។ អ្នកស្រែកពីក្រោយនាងក៏ប៉ុន្តែនាងនៅតែព្យាយាមរត់ទៅ។

អ្នករកនាងឃើញនៅកន្លែងរឹតទឹកដោះគោរបស់ពូនាង។

នាងកំពុងតែអង្គុយលើកូនកៅអីតូចហើយរឹតទឹកដោះគោ។ នាងមិនចង់ឱ្យអ្នកឃើញមុខនាងឡើយ តែនាងកំពុងតែជូតទឹកភ្នែកពេលដែលនាងកំពុងទាញដោះគោ។

ក្រោយមកអ្នកទាំងពីរក៏ដើរកៀកស្មាគ្នាទៅផ្ទះវិញ។

ទីបំផុតអ្នកដែលធ្វើឱ្យលែងមានភាពស្ងៀមស្ងាត់គឺជាសូរិយា។

នាងនិយាយថា “និយាយអញ្ចឹងនៅពេលដែលឯងក្លាយជាអ្នកមាន ក្លាយជា

មនុស្សស្រីដែលស៊ីវីល័យ ឯងត្រូវរៀបការជាមួយណារិនណា!” ពេលនោះស្រាប់តែអ្នកផ្ទុះសំណើចហើយរុញនាងចេញ។

ពួកគេចំអន់គ្នាលេងថា “តើប្អូននៅចាំបងឬអត់?” ឬប្រហែលជាគេនិយាយថា “សុំទោស! អាចអោយបងស្គាល់ឈ្មោះរបស់ប្អូនម្តងទៀតបានអត់? អូ! បងនឹកឃើញហើយ ប្អូនឈ្មោះសូរិយា។ ប្អូននៅតែរឹតទឹកដោះគោដដែលតើហ្អី?”

អ្នកទាំងពីរមានអារម្មណ៍ល្អឡើងវិញ ហើយអ្នកបន្តចំអន់គ្នាលេងរហូតមកដល់ផ្ទះ។ ក៏ប៉ុន្តែនៅពីក្រោយភាពរីករាយដែលអ្នកមានជាមួយសូរិយា អារម្មណ៍ព្រួយភ័យក៏ចូលមក។ អ្នកដឹងថាអ្វីៗមិនដូចដើមឡើយ។

◈◈◈

អ្វីដែលកាន់តែពិបាកនោះ គឺអ្នកត្រូវនិយាយពាក្យលាទៅកាន់គ្រួសាររបស់អ្នកនៅថ្ងៃខាងមុខនេះ។

អ្នកយួរកាបូបចេញពីបន្ទប់របស់អ្នក ហើយឃើញម្តាយរបស់អ្នកកំពុងតែកាន់ទូរសព្ទដៃជំនំមួយ។ គាត់បានខ្ចីទូរសព្ទនោះពីអ្នកមីងបុប្ផា។ គាត់បាននិយាយថាទូរសព្ទនោះនឹងអាចឱ្យគាត់ទាក់ទងមកអ្នកបានជារៀងរាល់ថ្ងៃ។ តែគាត់ខ្លាចគាត់ចុចប៊ូតុងខុស ហើយភ្លេចបញ្ចូលលុយ ឬភ្លេច សាកថ្ម។ អ្នកប្រាប់គាត់កុំឱ្យភ័យ ព្រោះយូរទៅគាត់គង់តែធ្លាប់ទេ។ តែមើលទៅគាត់នៅតែព្រួយបារម្ភហើយអ្នកដឹងច្បាស់ថាគាត់គ្រាន់តែយកទូរសព្ទមកធ្វើជាលេស។ ការពិតគាត់ប្រហែលជាបារម្ភពីរឿងផ្សេងច្រើនជាង ហើយសឹងតែមិនដឹងថាអ្នកកំពុងដើរចេញ។

ទីបំផុតអ្នកចាប់ស្មារបស់គាត់ ហើយនិយាយថា “កុំបារម្ភអីម៉ែ! ខ្ញុំមិនអីទេ”។ អ្នកឱបគាត់យ៉ាងយូរ។ ពេលដែលអ្នកចេញទៅ គាត់រត់ចេញទៅហើយប្រាប់ថាគាត់ប្រញាប់ទៅរកឆ្នាំងសាកថ្មទូរសព្ទ។

ពុករបស់អ្នកកំពុងតែអង្គុយនៅក្រោមដើមឈើក្រៅផ្ទះជួសជុលសំណាញ់នេសាទត្រី។ ពេលដែលអ្នកដើរហួសស្រាប់តែគាត់មើលអ្នកបន្តិច ហើយងាកមកធ្វើសំណាញ់របស់គាត់វិញ។

អ្នកនិយាយថា “ពុក! ខ្ញុំទៅហើយ។” គាត់ងក់ក្បាលហើយនិយាយតិចៗ រួចគាត់បន្តជួសជុលសំណាញ់របស់គាត់ទៀត។

ពេលដែលអ្នកកំពុងតែដើរ ឪពុករបស់អ្នកបានហៅឈ្មោះរបស់អ្នក។ អ្នក

ឈប់ដើរ ហើយងាកក្រោយ។ អ្នកក៏បានឃើញគាត់ងាកមុខយំតែមិនដឹងថាត្រូវនិយាយអ្វី។

អ្នកនិយាយម្ដងទៀតថា "ពុក! ខ្ញុំទៅហើយ។" គាត់ក៏ងក់ក្បាល។ ស៊ីតាដើរតាមអ្នករហូតដល់របង។ អ្នកប្រាប់នាងថា "ត្រូវមើលថែពុក និងម៉ែជំនួសបងផងណា!"

នាងតបវិញថា "ចាំសបង! តែពេលណាទើបបងត្រលប់មកវិញ?"

អ្នកនិយាយថា "នៅពេលដែលបងសន្សំលុយបានច្រើន បងនឹងមកលេង។"

ស៊ីតាតបថា "សន្យាណា?"

អ្នកនិយាយថា "ចាំស! បងសន្យា។"

អ្នកក៏បានឱប ហើយថើបនាង។

ពេលដែលអ្នកងាកក្រោយ អ្នកក៏ឃើញម្ដាយរបស់អ្នកកំពុងតែមើលមកអ្នកពីទ្វារខាងមុខផ្ទះ ហើយលើកដៃគ្រវីជាលើកចុងក្រោយ រួចដើរចូលក្នុងផ្ទះវិញ។

◈◈◈

សូរិយាកំពុងតែរង់ចាំអ្នកនៅឯម្ខាងផ្លូវ។

នាងសួរថា "យ៉ាងម៉េចទៅហើយ?"

អ្នកតបថា "ដូចជាមិនសូវល្អសោះ។"

នាងនិយាយថា "ពួកយើងមិនត្រូវយំទេណា! គ្មានហេតុផលអីដែលត្រូវយំផង ព្រោះឯងទៅតែមួយខែហ្នឹង។ បន្តិចទៀតឯងនឹងដឹងថាគំនិតមួយនេះមិនល្អឡើយ។"

អ្នកញញឹមទាំងទឹកភ្នែក ហើយនិយាយថា "ឯងប្រហែលជានិយាយត្រូវ។" អ្នកកៀកដៃគ្នា ហើយដើរតាមផ្លូវចុះទៅទន្លេ។

◈◈◈

ដេវីកំពុងតែរង់ចាំអ្នកនៅលើទូក។ គាត់យកកាបូបរបស់អ្នក ហើយហុចទៅម្ចាស់ទូក។ មានអ្នកដំណើរប្រាំអ្នកផ្សេងទៀតដែលកំពុងអង្គុយនៅលើទូក និងមានកាបូបជាច្រើននៅជុំវិញពួកគេ។

ដេវីនិយាយថា “ទុកចេញនៅពេលដែលមេឃងងឹត។”

សូរិយានិយាយថា “ចុះលោកមិនមែនជាអ្នកនាំនាងទៅទីក្រុងធំទេហ្អេស?”

ដេវីតបដោយញញឹមថា “អត់ទេ! អ្នកធ្វើការជាមួយខ្ញុំនឹងមកយកនាងនៅត្រើយម្ខាង ហើយនាំនាងទៅ។” ពេលនោះដេវីអាចមើលដឹងពីការព្រួយបារម្ភរបស់សូរិយា ហើយដេវីបានបន្ថែមថា “កុំព្រួយអី! នាងមិនអីទេ!”

ឥឡូវនេះដេវីបានឱ្យលិខិតឆ្លងដែនឱ្យអ្នក។ អ្នកព្យាយាមទាញវាមកជិតដើម្បីមើល តែគេប្រាប់ឱ្យអ្នកទុកនៅកន្លែងដែលមានសុវត្ថិភាពអញ្ចឹង ហើយទើបអ្នកយកវាទុកក្នុងហោប៉ៅរបស់អ្នក។

◈◈◈



កន្លះម៉ោងក្រោយមក អ្នកក៏បានមកដល់លើទូកដែលកំពុងតែរំកិលសន្សឹមៗទៅក្នុងភាពងងឹត។ អ្នកពិបាកនឹងងាកក្រោយសម្លឹងមើលផ្ទះរបស់អ្នកដោយសារមានក្មេងស្រីម្នាក់ និងបុរសម្នាក់នៅកៀបអ្នកជាប់។ អ្នកងាកករបស់អ្នកបន្តិចដើម្បីមើលទៅសូរិយាដែលឈរនៅច្រាំង។ នៅពីក្រោយសូរិយា អ្នកឃើញស្រមោលរបស់ដេវីដែលកំពុងតែដើរចូលក្នុងកន្លែងងងឹត។

មានគំនិតចម្លែកៗជាច្រើនដែលអ្នកកំពុងតែស្រមើស្រមៃ៖ *ពេលនេះខ្ញុំនៅតែម្នាក់ឯង។ នេះជាការចាប់ផ្ដើមនៃមេរៀនជីវិត។ ពេលនេះខ្ញុំត្រូវប្រើទ្រឹស្ដីខ្លួនទីពឹងខ្លួន។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចលាយរំភើប។ តែខ្ញុំត្រូវតែធ្វើដើម្បីខ្លួនឯងនិងក្រុមគ្រួសាររបស់ខ្ញុំ។*

◈◈◈

អ្នកក៏បានទៅដល់ច្រាំងក្រោមការដឹកនាំរបស់បុរសវ័យក្មេងម្នាក់ដែលមិនបានណែនាំខ្លួន។ គេនាំអ្នកនិងក្មេងស្រីពីរអ្នកទៀតចេញពីទូក ហើយធ្វើសញ្ញាឱ្យអ្នកឡើងឡានតូចផ្នែកខាងក្រោយ។ គេមើលចុះឡើងៗហើយក៏ទៅអង្គុយជិតអ្នកបើកបរឡាន។

ពេលដែលអ្នកនៅលើឡាន មានក្មេងស្រីម្នាក់សួរបុរសម្នាក់នោះថាតើនៅឆ្ងាយប៉ុណ្ណាទៀតទើបទៅដល់។ តែគាត់ដូចជាមិនយល់នូវអ្វីដែលនាងសួរឡើយ។ គេលើកដៃឡើងប្របហែលជាមានន័យថាមិនឱ្យនាងសួរទៀត។

◈◈◈

ព្រះអាទិត្យក៏ចាប់ផ្ដើមរះស្របពេលដែលអ្នកចូលមកដល់ទីក្រុង។ តាំងពីកើតមកអ្នកមិនដែលបានឃើញឡានច្រើនបែបនេះឡើយ។ នេះជាការធ្វើដំណើរផ្លូវឆ្ងាយដែលធ្វើឱ្យអ្នកមិនបានគេងគ្រប់គ្រាន់។ អ្នកស្រមៃថាអ្នកបានសណ្ដូកជើង ហើយងូតទឹក។ ចំណែកអ្នកបើកបរឡានក៏មើលទៅអស់កម្លាំង ហើយព្រួយបារម្ភដែរ។ គាត់កំពុងជេរអ្នកបើកឡានផ្សេងទៀតហើយចុចស៊ីផ្លេឡានសឹងតែមិនដកដៃទៅហើយ។

ទីបំផុតអ្នកក៏បានមកដល់ខាងមុខផ្ទះមួយ។ អ្នកឃើញទ្វារមុខផ្ទះបើកស្រាប់ហើយមានក្មេងពីរនាក់ទៀតស្លៀកឯកសណ្ឋានសាលាកំពុងតែឈរនៅខាងមុខទ្វារនោះ។ បុរសមុខមាំម្នាក់ស្លៀកពាក់អាវធំកំពុងតែកៀងក្មេងទាំងនោះឱ្យទៅឈរលើចិញ្ចើមផ្លូវ តែពេលដែលគាត់បានឃើញឡានតូច គាត់ស្រាប់តែនៅស្ងៀម។ អ្នកបើកបរឡានបានចុះទៅរាក់ទាក់ជាមួយគាត់។ បុរសទាំងពីរបានចាប់ដៃគ្នាហើយនិយាយគ្នា ក្រោយមកអ្នកបើកបរក៏មកបើកទ្វារឡានហើយធ្វើសញ្ញាឱ្យអ្នកចុះពីលើឡាន។

រំពេចនោះស្រាប់តែបុរសដែលពាក់អាវធំហៅអ្នកឱ្យចូលក្នុងផ្ទះ ហើយអ្នកបានឃើញស្ត្រីម្នាក់(អ្នកសន្មត់ថាគាត់ជាប្រពន្ធរបស់បុរសម្នាក់នោះ)លេចឡើងនៅក្បែរទ្វារដោយមានបីកូននឹងដៃ។ គាត់ហាក់ដូចជាមិនសូវរីករាយសោះពេលដែលបុរសម្នាក់នោះប្រាប់គាត់ឱ្យចេញក្រៅ។

អ្វីដែលកើតឡើងបន្ទាប់រឹតតែចម្លែកសម្រាប់អ្នក។ អ្នកបើកបរឡានប្រាប់អ្នកនិងក្មេងស្រីដទៃទៀតឱ្យតម្រង់ជួរនៅលើចិញ្ចើមផ្លូវ។ ក្រោយមកប្ដីប្រពន្ធនោះដើរមករកពួកអ្នក ហើយមកជិត រួចមើលម្នាក់ម្ដងៗ។ ពេលដែលប្ដីប្រពន្ធនោះសម្លឹងពួកអ្នករួចពួកគេក៏ពិភាក្សាគ្នា។ ប្ដីប្រពន្ធគាត់ប្រៀបដូចជាដែលកំពុងតែនៅក្នុងផ្សារសម្រេចចិត្តថាម្ហូបអ្វីដែលពួកគេត្រូវតែទិញសម្រាប់អាហារពេលល្ងាច។ ចុងក្រោយបុរសម្នាក់នោះឈប់នៅខាងមុខអ្នកហើយ សួរអ្នកជាភាសារបស់គាត់។ អ្នកមិនដឹងថាគាត់និយាយពីអ្វីឡើយ។ បន្ទាប់មកគាត់ក៏សួរអ្នកជាភាសារបស់អ្នក។ អ្នកពិតជាពិបាកស្ដាប់មែនទែនព្រោះមិនដឹងថាគាត់ចង់សួរអ្វីឱ្យប្រាកដ។ តែអ្នកគិតថាប្រហែលគាត់ចង់ដឹងពីអាយុរបស់អ្នក ហើយចង់ដឹងថាតើអ្នកធ្លាប់មើលក្មេងៗ ឬធ្វើការងារផ្ទះដែរឬអត់។ អ្នកប្រាប់គាត់ថាអ្នក

ថ្មីកនឹងការងារទាំងអស់នោះ រួចហើយអ្នកក៏បានលើកម្រាមដៃរបស់អ្នកបញ្ជាក់ប្រាប់គាត់ពីអាយុរបស់អ្នក។

បុរសម្នាក់នោះពិតជាពេញចិត្តនឹងអ្នកណាស់។ គាត់ងក់ក្បាលហើយទៅនិយាយជាមួយអ្នកបើកបរឡាន។

មើលទៅស្ត្រីជាប្រពន្ធដូចជាមិនសប្បាយចិត្តទាល់តែសោះ។ គាត់បាននិយាយជាមួយអ្នកតែអ្នកមិនយល់ឡើយ។ ក្រោយមកគាត់ធ្វើកាយវិការប្រាប់អ្នកឱ្យទៅយកកាបូបរបស់អ្នកពីឡានតូចនោះ។

ពេលដែលអ្នកកំពុងតែអូសកាបូបរបស់អ្នក អ្នកបានឃើញបុរសជាប្ដីហុចលុយឱ្យទៅអ្នកបើកបរ។ ទើបតែពេលនេះទេដែលអ្នកមានអារម្មណ៍ថាអ្នកទើបតែសម្ភាស៍ការងារសោះ ឥឡូវអ្នកបានការងារធ្វើហើយ។

តែអ្វីៗហាក់ដូចជាកើតឡើងរហ័សដល់ហើយ រហូតទាល់តែអ្នកមានសំណួរជាច្រើនដែលត្រូវសួរ “តើខ្ញុំបានប្រាក់ខែប៉ុន្មាន? តើខ្ញុំឈប់បានប៉ុន្មានថ្ងៃ? តើខ្ញុំត្រូវស្នាក់នៅឯណា? តើឥឡូវខ្ញុំកំពុងតែនៅឯណា?” អ្នកចង់សួរសំណួរទាំងអស់នេះទៅពួកគេ តែមើលទៅពួកគេដូចជាកំពុងរវល់និយាយគ្នា។ កំពុងតែគិតស្រាប់តែស្ត្រីជាប្រពន្ធធ្វើកាយវិការពីទ្វារមុខផ្ទះប្រាប់អ្នកឱ្យប្រញាប់ចូលក្នុងផ្ទះ។ អ្នកគ្មានជម្រើសឡើយ។ អ្នកដើរតាមគាត់ចូលទៅក្នុងផ្ទះ។

ពេលចូលដល់ក្នុងផ្ទះ អ្នកព្យាយាមនិយាយជាមួយគាត់ តែគាត់បែរជាធុញទ្រាន់ហើយគ្រវីក្បាលរបស់គាត់ទៅវិញ។ នេះបង្ហាញឱ្យឃើញថាគាត់ពិតជាមិនយល់ពីអ្វីដែលអ្នកបាននិយាយឡើយ។ បន្ទាប់មកអ្នកក៏បានធ្វើកាយវិការដែលមើលទៅដូចជាធម្មតា តែរីកធំបន្តិចម្តងៗពីសប្តាហ៍ទៅខែ។ ស្ត្រីនោះក៏បានចាក់សោរទ្វារមុខ ហើយយកសោរទុកក្នុងហោប៉ៅរបស់គាត់។

◈◈◈

នៅថ្ងៃបន្តបន្ទាប់ជាថ្ងៃដែលអ្នកត្រូវប្តូរខោទឹកនោមជូតឥដ្ឋ រៀបចំម្ហូប ហើយនឹងបោកខោអាវមិនចេះអស់។ អ្នកត្រូវចាប់ផ្តើមធ្វើការទាំងអស់នេះពីព្រឹកព្រលឹមរហូតដល់យប់អាធ្រាត្រ។ អ្នកឈប់ទំនាក់ទំនងជាមួយស្ត្រីជាប្រពន្ធព្រោះឱ្យតែអ្នកប្រឹងនិយាយជាមួយគាត់គាត់បែរជាដើរចេញហើយគ្រវីក្បាល។ អ្នកក៏ពិបាកនឹងទំនាក់ទំនងជាមួយប្តីនៅពេលដែលស្ត្រីជាប្រពន្ធនៅក្បែរដែរព្រោះឱ្យតែគាត់ឃើញអ្នកទំនេរគាត់តែងតែជេរស្តីហើយរអ៊ូរទាំ។ ពីរបីថ្ងៃក្រោយ អ្នកព្យាយាមនិយាយជាមួយបុរសជាប្តីពីប្រាក់ខែរបស់អ្នក។ ចំនួន

ប្រាក់ខែដែលគាត់បានប្រាប់កាលពីដំបូងដូចជាសមរម្យតែពេលដែលគាត់និយាយថាគាត់កាត់ថ្លៃធ្វើដំណើរថ្លៃស្នាក់នៅ និងថ្លៃអាហារខ្លះ។ អ្នកស្រម៉ៃថាប្រហែលជាគេមិនកាត់ប្រាក់ខែរបស់អ្នកច្រើនលើថ្លៃស្នាក់នៅនិង ថ្លៃអាហារឡើយ ព្រោះអ្នកគិតថាអ្នកគេនៅកន្លែងតូចចង្អៀត គេងលើគ្រែរឹងនៅជិតកន្លែងបោកខោអាវ ជាពិសេសគឺអ្នកញ៉ាំអាហារដែលនៅសល់ពីពួកគេ។

◈◈◈

ពេលវេលាចេះតែកន្លងផុតទៅ អ្នកចេះតែបារម្ភពីរឿងជាច្រើន។ រឿងទីមួយដែលអ្នកបារម្ភគឺការងារដែលអ្នកត្រូវធ្វើគ្មានពេលនឹងសម្រាក។ ស្ត្រីជាប្រពន្ធតែងតែឱ្យអ្នកធ្វើនេះធ្វើនោះមិនចេះឈប់ ហើយតែងតែស្តីបន្ទោសអ្នកសឹងតែគ្រប់ពេល។ នៅល្ងាចមួយពេលដែលប្តីប្រពន្ធនោះកំពុងតែមើលទូរទស្សន៍អ្នកក៏សុំពួកគេឈប់មួយថ្ងៃ។ ពេលដែលបុរសជាប្តីបកប្រែឱ្យប្រពន្ធរបស់គាត់ស្តាប់នូវសំណើរបស់អ្នក គាត់ស្រាប់តែស្រែកដោយកំហឹងហើយតម្លើងសម្លេងទូរទស្សន៍។ បុរសជាប្តីនិយាយថាចាំអាទិត្យក្រោយ ហើយលើកដៃជាសញ្ញាឱ្យអ្នកចេញ។

រឿងមួយទៀតដែលធ្វើឱ្យអ្នកបារម្ភនោះ គឺអ្នកមិនអាចចេញទៅណាបានក្រៅពីនៅតែក្នុងផ្ទះ។ ទ្វារមុខ និងទ្វារក្រោយជាប់សោរចំណែកបង្អួចវិញមានសុទ្ធតែចម្រឹងដែក។ អ្នកអាចមើលមេឃបានតែនៅពេលអ្នកហាលខោអាវនៅក្នុងទីធ្លាដ៏សែនតូច។ ពេលវេលាចេះតែកន្លងទៅ ហើយអ្នកមានអារម្មណ៍ថាអ្នកដូចជានៅក្នុងគុកអញ្ចឹង។

ម៉្យាងទៀតបញ្ហារបស់អ្នកគឺទូរសព្ទ។ ទូរសព្ទរបស់អ្នកមិនដំណើរការក្នុងប្រទេសនេះឡើយ ព្រោះអ្នកត្រូវទិញស៊ីមរបស់ប្រទេសគេប្រើ។ អ្នកគិតថាអ្នកត្រូវទិញស៊ីមភ្លាម ពេលមកដល់តែជាអកុសលម្ចាស់ផ្ទះមិនឱ្យអ្នកចេញក្រៅផ្ទះឡើយ កុំថាឡើយកន្លែងលក់ក្បែរនោះ។ អ្នកបានសុំបុរសជាប្តីឱ្យទិញស៊ីមឱ្យ (ទាំងដែលអ្នកឱ្យប្រាក់ដែលអ្នកមានបន្តិចបន្តួចឱ្យទៅទិញ) តែគាត់តែងតែភ្លេចទិញ ឬដោះសាររហូត។

អ្នកចង់ទាក់ទងទៅសូរិយានិងម្តាយរបស់អ្នកជាងអ្វីៗទាំងអស់។ អ្នកបានសន្យានឹងសូរិយាថាអ្នកនឹងផ្ញើរសារទៅសូរិយាឱ្យបានរាល់ថ្ងៃ ហើយមានរឿងជាច្រើនដែលអ្នកចង់ប្រាប់នាង។ អ្នកចាំសម្តីរបស់នាងថា “ទោះបីជាឯងទៅដល់ស្រុកគេក៏កុំបំភ្លេចយើងអីណា!”។ អ្នកស្រមៃមិនចេញឡើយថាពេលនេះនាងកំពុងតែគិតអ្វី។

ហើយចុះអ្នកម្តាយកំសត់របស់អ្នកវិញ! ច្បាស់ណាស់គាត់ប្រាកដជាកាន់ទូរសព្ទជាប់នឹងដៃគ្រប់ពេលហើយមើលទៅ! គាត់ប្រហែលជាសាកថ្មពេញៗ

ហើយមើលទៅ!គាត់ប្រហែលជាគិតថាទូរសព្ទមានបញ្ហាហើយ បានជាមិនឃើញអ្នកទូរសព្ទទៅ។ អ្នកស្រមៃថារាល់ថ្ងៃពេលត្រលប់មកពីសាលាស៊ីតាច្បាស់ជាសួរម្តាយរបស់អ្នកពីដំណឹងរបស់អ្នកហើយមើលទៅ!

អ្នកគេងយំរាល់យប់។ តើនេះជាជីវិតថ្មីរបស់អ្នកហ្មែស? នេះជាអ្វីដែលជីវិតត្រូវតែជួបហ្មែស? មានរឿងតែមួយគត់ដែលអាចធ្វើឱ្យអ្នកមានអារម្មណ៍ល្អវិញបាននោះគឺប្រាក់ខែដែលគេជិតបើកឱ្យអ្នក។

អ្នកស្រមៃឃើញទឹកមុខម្តាយរបស់អ្នកពេលដែលគាត់បានលុយនោះ។ អ្នកសង្ឃឹមយ៉ាងមុតមាំថាគាត់ច្បាស់ជាយកលុយនោះទៅសងលោក ស្នេកគី ព្រមទាំងប្រាប់ថាចាប់ពីខែនេះទៅគាត់នឹងសងលុយឱ្យបានទៀងទាត់ អញ្ចឹងម្ចាស់បំណុលមិនបាច់មកទារលុយដល់ផ្ទះទៀតឡើយ។ បើសិនជាម្ចាស់បំណុលមិនមកទារលុយដល់ផ្ទះរបស់អ្នកពុករបស់អ្នកច្បាស់ជាមិនខឹងទៀតឡើយ។ គាត់ច្បាស់ជាមិនផឹកស្រាបៀរហើយផ្ទះរបស់អ្នកច្បាស់ជាក្លាយទៅទីកន្លែងដែលមានតែសេចក្តីស្ងប់ ហើយមានតែសម្លេងសើចរបស់ស៊ីតាដូចកាលពីមុន។

អ្នកក៏លង់លក់ក្នុងដំណេកដោយស្រមៃថាឪពុករបស់អ្នកលេងហ្គីតាសារជាថ្មី ហើយស៊ីតាដែលជាអ្នកដែលតែងតែធ្វើឱ្យពុកអ្នកសើច កំពុងរាំយ៉ាងសប្បាយ។

◈◈◈

ទីបំផុតថ្ងៃដែលកំនត់ថាអ្នកមកបានមួយខែក៏បានមកដល់។ បុរសជាប្តីក៏បានចេញទៅធ្វើការទាំងព្រឹកដោយមិនបាននិយាយពីប្រាក់ខែរបស់អ្នកឡើយ អញ្ចឹងអ្នកត្រូវរង់ចាំរហូតដល់ពេលដែលគាត់ត្រឡប់មកផ្ទះវិញ។ តែនៅល្ងាចនោះគាត់មិនបាននិយាយអ្វីទាំងអស់។ អ្នកប្រហែលជាត្រូវរំឭកគាត់ហើយទើបបាន។

ពេលដែលអ្នករៀបចំអាហារពេលល្ងាចឱ្យពួកគេ អ្នកក៏បាននិយាយថាអ្នកធ្វើការបានមួយខែហើយ។ ដំបូងគាត់សម្លឹងអ្នកធ្វើដូចជាមិនដឹងអីតែគាត់និយាយតិចៗថាចាំថ្ងៃសុក្រ។ អ្នកចង់និយាយបន្ថែមទៀត តែស្ត្រីជាប្រពន្ធកំពុងតែសម្លក់អ្នកហើយប្រាប់អ្នកឱ្យចេញពីទីនោះ។ ពាក្យថា *ចេញទៅ* ដែលនិយាយជាភាសារបស់ប្រទេសគេជាពាក្យដំបូងដែលអ្នកចេះ ព្រោះចៅហ្វាយស្រីតែងតែនិយាយពាក្យនេះដាក់អ្នក។ ពាក្យមួយទៀតដែលអ្នកចេះគឺ *ធ្វើការឱ្យលឿនហើយទៅរៀបអាហារ*។ ពេលដែលអ្នកដើរទៅផ្ទះបាយវិញអ្នកដកដង្ហើមធំ ហើយប្រាប់ខ្លួនឯងថាថ្ងៃសុក្រជិតមកដល់ហើយ។

ពេលដែលថ្ងៃសុក្រចូលមកដល់ អ្នកនិយាយពីរឿងប្រាក់ខែទៅកាន់បុរសជាប្តីពេលដែលគាត់រៀបចេញទៅធ្វើការ។ គាត់ក៏និយាយម៉ាត់ៗថាគាត់ភ្លេចបាត់

ហើយ។ គាត់ប្រាប់អ្នកឱ្យជួយរំឭកគាត់ពេលដែលគាត់មកដល់ផ្ទះ។ ក្រោយមកគាត់ក៏ឮគាត់និយាយជាមួយប្រពន្ធរបស់គាត់។ បន្តិចក្រោយមកគាត់ក៏ដើរទៅផ្ទះបាយ ហើយគប់ក្រដាសអ្វីម្យ៉ាងដែលមានសរសេរលេខនៅលើនោះ ហើយគាត់ក៏ប្រាប់ថានេះជាប្រាក់ខែរបស់អ្នក។ ហើយគាត់ចង្អុលលើលេខនៅខាងលើ ហើយប្រាប់ថានេះជាថ្លៃចំណាយលើការធ្វើដំណើរថ្លៃស្នាក់នៅ និងថ្លៃអាហារ។ នៅចុងក្រដាសអ្នកឃើញគាត់សរសេរលេខហើយគូសជុំវិញលេខនោះ។ អ្នកសម្លឹងទៅលេខក្នុងរង្វង់នោះដែលជាលុយដែលអ្នកត្រូវទទួលបានពីប្រាក់ខែរបស់អ្នក។ ចំនួនលុយនោះពិតជាតិចតួចស្តួចស្តើងមែនទែន។ ផ្ញើរទៅផ្ទះក៏មិនគ្រាន់ដែរ។ អ្នកសម្លឹងទៅថៅហ្វាយប្រុសនោះសឹងតែមិនជឿថា គាត់ទុកប្រាក់ខែនៅលើតុទៅតាមតួរលេខដែលគាត់បានសរសេរហើយក៏ដើរចេញទៅ។

អ្នកទាញអាវគាត់មិនឱ្យទៅហើយនិយាយថា “កុំអី! សូមអង្វរ! វាមិនស្មើនឹងការងារដែលខ្ញុំបានធ្វើឡើយ។ កុំអញ្ចឹងអី! ខ្ញុំសូមអង្វរ!"



ចៅហ្វាយស្រីដូចជាដឹងមុនថានឹងមានអ្វីកើតឡើង ព្រោះពេលនេះគាត់កំពុងដើរទៅផ្ទះបាយ។ គាត់គោះក្រដាសនោះហើយស្រែកដោយកំហឹង។ អ្នកមិនដឹងថាគាត់កំពុងតែនិយាយអ្វីឡើយ តែប្តីរបស់គាត់បានបកប្រែថាថ្លៃធ្វើដំណើរក៏ថ្លៃ ថ្លៃស្នាក់នៅក្នុងទីក្រុងរឹតតែថ្លៃ ហើយអ្នកហូបអាហាររបស់យើងដែលសុទ្ធតែជាអាហារថ្លៃៗ។

អ្នកមិនអាចតបតអ្វីបានព្រោះចៅហ្វាយស្រីកំពុងតែស្រែកដាក់មុខរបស់អ្នក។ អ្នកមានអារម្មណ៍ថា កំហឹងរបស់អ្នកកំពុងតែខ្លាំងឡើងៗប្រៀបដូចជាចង្ក្រានអញ្ចឹង។

អ្នកស្រែកវិញថា “ទេ!!! លុយនេះតិចពេកហើយ!!”

អ្នកមានអារម្មណ៍ថាមានអ្វីម្យ៉ាងប៉ះថ្ពាល់របស់អ្នក ហើយអ្នកក៏យកដៃខ្ទប់ថ្ពាល់។ គឺចៅហ្វាយស្រីទះកំភ្លៀងអ្នក។ គាត់លើកដៃរៀបនឹងទះអ្នកទៀតតែត្រូវប្តីរបស់គាត់ឃាត់ ហើយយកគាត់ចេញពីផ្ទះបាយ។ គាត់ចេញទៅហើយក៏នៅតែស្រែកដាក់អ្នកទៀត។

អ្នកអង្គុយលើកៅអីមើលទៅលុយដែលនៅលើតុ។ ថ្ពាល់របស់អ្នកនៅតែក្រហម។

មួយសន្ទុះក្រោយមក ចៅហ្វាយប្រុសត្រលប់មកវិញ ហើយស្ដីបន្ទោសឱ្យអ្នកពីរឿងដែលអ្នកធ្វើឱ្យប្រពន្ធរបស់គាត់មនសប្បាយចិត្ត។ អ្នកគ្រាន់តែដឹងថាបប្ដូរមាត់របស់គាត់កម្រើក តែអ្នកមិនដឹងថាគាត់និយាយអ្វីឡើយ។ អ្នកកំពុងតែគិតពីវិធីរំដោះខ្លួនចេញពីផ្ទះមួយនេះ។

◈◈◈

អ្នកបានសម្រេចចិត្តថាអ្នកនឹងរត់ចេញពីកន្លែងនេះ។

សំណួរដែលអ្នកត្រូវសួរខ្លួនឯងពេលនេះគឺ “អ្នកចេញបានដោយវិធីណា?” វាពិតជាមិនងាយស្រួលឡើយ តែប្រាកដជាមានវិធីណាមួយ។ អ្នកត្រូវតែប្រាកដចិត្តថាប្ដីប្រពន្ធមិនដឹងពីអ្វីដែលអ្នកកំពុងតែគ្រោងទុកឡើយ។

អ្នកមានជម្រើសពីរដែលសុទ្ធតែមានគ្រោះថ្នាក់ហើយងាយនឹងភ្លាត់ស្នៀត។

ជម្រើសទីមួយពាក់ព័ន្ធនឹងទូរសព្ទរបស់ចៅហ្វាយស្រី។ ទូរសព្ទរបស់អ្នកមិនដំណើរការក្នុងប្រទេសមួយនេះឡើយ អញ្ចឹងអ្នកត្រូវតែព្យាយាមប្រើទូរសព្ទចៅហ្វាយស្រីព្រោះពេលខ្លះគាត់សាកថ្មចោលក្នុងផ្ទះបាយពេលគាត់ចូលទៅសម្រាន្តពេលថ្ងៃត្រង់ឬពេលគាត់រវល់ក្នុងបន្ទប់មួយទៀត។ ប្រហែលវិធីនេះអាចឱ្យអ្នកទាក់ទងទៅសូរិយា ឬម្ដាយរបស់អ្នកបាន។ យ៉ាងហោចណាស់ក៏អ្នកអាចឱ្យពួកគេដឹងថាអ្នកមានសុវត្ថិភាពទេ។ តែពួកគេអាចជួយអ្នកបានឬអត់? អ្នកមិនស្គាល់ពីទីតាំងច្បាស់លាស់ដែលអ្នកកំពុងតែនៅក្នុងទីក្រុងផងហ្នឹង។ ថ្វីត្បិតតែអ្នកព្យាយាមរកអាសយដ្ឋាននៅលើស្រោមសំបុត្រដែលមានក្នុងប្រអប់សំបុត្រតែអ្នករកមិនឃើញឡើយព្រោះតែគេសរសេរជាភាសាគេ។ អ្នកពិតជាមិនដឹងថាអ្នកកំពុងតែនៅទីណាឡើយ។ តែអ្នកប្រហែលជាអាចទាក់ទងទៅដេវី ហើយគេអាចជួយឱ្យសូរិយានិងម្ដាយរបស់អ្នករកអ្នកឃើញឬអត់ហ្ន៎?

វិធីមួយទៀតគឺពាក់ព័ន្ធនឹងបង្អួចដ៏សែនតូចដែលអ្នកបានឃើញនៅជាន់លើក្រោមដំបូលផ្ទះ។ អ្នកដឹងថាមានបង្អួចតូចនេះនៅពេលដែលអ្នកយកប្រអប់ចាស់ៗទៅទុកនៅទីនោះ។ ប្រហែលជាអ្នកត្រូវប្រជ្រៀតចូលតាមបង្អួចតូចនោះ ទើបអ្នកអាចឡើងដល់ដំបូលផ្ទះ។ តែមិនថាមានអ្វីកើតឡើងឡើយនេះជាឱកាសតែមួយគត់ដែលអ្នកអាចចេញពីផ្ទះនេះបាន។ ប្រាកដណាស់ជាមួយនឹងលុយតិចតួចស្ដួចស្ដើងរបស់អ្នក អ្នកច្បាស់ជាអាចចេញផុតពីផ្ទះនេះ ហើយអ្នកអាចឈរនៅចំកណ្ដាលទីក្រុងធំដែលឆ្ងាយសែនឆ្ងាយពីផ្ទះរបស់អ្នក។ ក៏ប៉ុន្តែបើសិនជាអ្នកបានទាក់ទងជាមួយអ្នកណាម្នាក់ គេប្រហែលជាអាចជួយអ្វីអ្នកបាន។

◈◈◈

នៅថ្ងៃន្ទាប់បុរសជាប្ដីព្យាយាមធ្វើឱ្យអ្នកមានអារម្មណ៍ល្អឡើងវិញដោយប្រាប់អ្នកថាខែក្រោយអ្នកនឹងបានប្រាក់ខែច្រើនជាងនេះ។ គាត់ថែមទាំងណែនាំអ្នកកុំឱ្យធ្វើមុខក្រញ៉ូវពេលនៅជិតប្រពន្ធរបស់គាត់ ព្រោះវារឹតតែធ្វើឱ្យប្រពន្ធរបស់គាត់កាន់តែមិនសប្បាយចិត្ត។

ក្រោយមកគាត់បានធ្វើអ្វីម្យ៉ាងដែលធ្វើឱ្យអ្នកមិនអាចកម្រើកបាន។ **គាត់ស្រាប់តែចាប់អ្នកឱប!**

អ្នករាប់រហូតទាល់តែគាត់លែង។ គាត់ញញឹមហើយរង់ចាំអ្នកឱ្យងក់ក្បាលជាសញ្ញាថាអ្នកព្រម។ អ្នកបង្ខំចិត្តញញឹមតែធាតុពិតអ្នកឈឺចាប់ណាស់។ អ្នកគិតថាអ្នកត្រូវតែចេញពីទីនេះឱ្យបានឆាប់បំផុត។ នៅពេលនេះអ្នកកំពុងតែសម្រេចចិត្តថាតើជម្រើសណាមួយដែលអ្នកគួរតែប្រើ។ ទូរសព្ទរបស់ចៅហ្វាយស្រី ឬក៏បង្អួច?



**បើអ្នកសម្រេចចិត្តថាអ្នកនឹងប្រើទូរសព្ទរបស់ចៅហ្វាយស្រី សូមទៅកាន់ទំព័រទី៣៥**

៣៥



**បើអ្នកសម្រេចចិត្តថាអ្នកឡើងតាមបង្អួចនៅក្រោមដំបូល សូមទៅកាន់ទំព័រទី ៤២**

៤២

# ទឹកដោះគោ ទឹកឃ្មុំ ប្រាក់



អ្នកកំពុងដើរទៅសាលាជាមួយសូរិយា។ អ្នកដឹងថាអ្នកត្រូវប្រាប់រឿងនេះដល់សូរិយា តែអ្នកមិនប្រាកដថា ត្រូវប្រាប់នាងយ៉ាងម៉េចឡើយ។ អ្នកនិយាយថា"រឿងនៅផ្ទះកាន់តែយ៉ាប់ហើយ។" "រឿងដែលកើតឡើងកាលពីយប់មិញពិតជាមិនល្អទាល់តែសោះតែយើងត្រូវធ្វើអ្វីម្យ៉ាងហើយទើបបាន។"

សូរិយាសួរថា "ធ្វើអី?" ពេលនោះនាងសម្លឹងអ្នកដោយអាការៈព្រួយបារម្ភហាក់ដូចជានាងកំពុងដឹងថាអ្នកនឹងឆ្លើយយ៉ាងម៉េច។

អ្នកមិនតបតែនាងអាចមើលដឹងពីការសម្រេចចិត្តរបស់អ្នកដោយគ្រាន់តែមើលតាមទឹកមុខរបស់អ្នក។

នាងដើរចេញដោយស្ងៀមស្ងាត់។

អ្នកក៏ស្រែកតាមក្រោយនាងថា "យើងអត់ធ្វើអញ្ចឹងទេ!"
តែសូរិយាមិនព្រមឈប់ឡើយ។ អ្នកនិយាយតែម្នាក់ឯងថា
"តើខ្ញុំមានជម្រើសអ្វីខ្លះ?"

◈◈◈

នៅពេលចេញលេងនៅសាលា អ្នកឃើញសូរិយាអង្គុយនៅលើកៅអីតែម្នាក់ឯងហើយញ៉ាំបាយថ្ងៃត្រង់។

អ្នកសួរនាងថា "យើងសុំអង្គុយដែរបានអត់?"

នាងតបថា "មិនបាច់សុំទេ! អង្គុយចុះមក។"

អ្នកអង្គុយចុះហើយអ្នកទាំងពីរញ៉ាំអាហារដោយភាពស្ងៀមស្ងាត់។

ទីបំផុតអ្នកក៏និយាយមុនថា "ឯងដឹងអត់ថាយើងចង់ឱ្យឯងជួយ។"

សូរិយាមើលមកអ្នកទាំងមិនគួរឱ្យជឿ ហើយគ្រវីក្បាល។ នាងនិយាយថា "ឯងនិយាយមែនហ៎ ? ឯងចាំបានអត់ថាយើងមិនចង់ឱ្យឯងទៅទេ។ អញ្ចឹងហេតុអីយើងត្រូវជួយឯង ?"

អ្នកក៏តបវិញថា "ព្រោះឯងជាមិត្តល្អរបស់យើងហើយយើងក៏ជាមិត្តល្អរបស់ឯង។ យើងស្រលាញ់ឯង ហើយឯងក៏ស្រលាញ់យើង។ ឯងចង់ឱ្យយើងដើរផ្លូវត្រូវព្រោះបើសិនជាយើងដើរផ្លូវខុសហើយមានរឿងមិនល្អកើតឡើងក៏ឯងមិនព្រមលើកលែងទោសឱ្យខ្លួនឯងដែរ ហើយយើងក៏ដូចគ្នា។"

អ្នកសង្ឃឹមថាអ្វីដែលអ្នកនិយាយនឹងធ្វើឱ្យនាងញញឹម ហើយអ្នកក៏ឃើញនាងញញឹមច្រើនដង។

នាងនិយាយថា "ថ្កាល់ឯងស្អាតណាស់ មានដឹងខ្លួនអត់ ?"

អ្នកក៏និយាយថា "មិនមែនយើងទៅរហូតឯណា។ គ្រាន់តែទៅសន្សំលុយឱ្យបានច្រើន ហើយយើងនឹងត្រលប់មកវិញ មិនឱ្យឯងដឹងមុនឡើយ។"

"ឯងប្រហែលជាមិនត្រលប់មកវិញឡើយ។"

"មែនហើយ!"

"អញ្ចឹងឯងចង់ឱ្យយើងជួយធ្វើអី ?"

"គ្រប់បែបយ៉ាងហ្នឹង! យើងចង់ធ្វើលិខិតឆ្លងដែន។ យើងត្រូវតែចាត់ចែងការងារ។ យើងត្រូវការលុយខ្លះដើម្បីធ្វើដំណើរចំណាយលើការស្នាក់នៅ និងចំណាយផ្សេងទៀត។"

សូរិយាសម្លឹងអ្នកហើយគ្រវីក្បាលព្រមទាំងនិយាយថា "បើគ្មានខ្ញុំតើឯងអាចចាត់ការរឿងទាំងអស់នេះបានយ៉ាងម៉េច ?"

អ្នកក៏និយាយទាំងញញឹមថា "យើងមិនដឹងទេ។ ចង់ទៅដែរមែន ?" សូរិយា "អត់ទេ!"

ឥឡូវនេះអ្នកនិយាយបែបប្រាកដប្រជាថា "គ្រាន់តែពិនិត្យមើលសិនតើ! យើងគិតថា អ្វីដែលយើងត្រូវធ្វើដំបូងគេគឺសន្សំលុយសិន។ យើងមិនអាចសុំលុយពីម្តាយយើងឡើយ។ មានគំនិតអ្វីអត់ ?"

សូរិយាតបវិញថា "ទេ! បើសិនជាសន្សំលុយអាចឱ្យយើងមានលុយ យើងនឹងជួយសងលុយដែលគ្រួសារឯងជំពាក់គេ ហើយឯងក៏មិនបាច់ទៅណាដែរ។"

អ្នកក៏ចាប់ដៃរបស់សូរិយាហើយនិយាយថា "តើមានអ្នកណាធ្លាប់និយាយថាឯងគួរឱ្យស្ញើច សរសើរណាស់?"

សូរិយា "ម៉េចមិនធ្លាប់? លឺតែរហូតហ្នឹង។ តែមិនបាច់បញ្ជោរយើងទេ។"

អ្នកពិតជារីករាយនៅពេលដែលបានឃើញនាងញញឹមម្តងទៀត។

◈◈◈

ពីរបីថ្ងៃក្រោយមក អ្នកចាំសូរិយានៅផ្លូវម្ខាងនៅពេលដែលអ្នកឃើញនាងកំពុងដើរតាមផ្លូវ។ មើលទៅនាងហាក់ដូចជារំភើបហើយមានអ្វីចង់ប្រាប់អ្នក។

អ្នកសួរ "មានរឿងអី?"

នាងធ្វើជាតបថា "សុំទោស! អត់ដឹងថាឯងចង់និយាយពីអីទេ?"

អ្នកនិយាយថា"និយាយលឿនឡើង។ យើងដឹងថាឯងមានអ្វីចង់និយាយ។"

នាងតបថា "មែន! យើងមានដំណឹងខ្លះៗ។"

អ្នកស្រែកថា "ប្រាប់ភ្លាមមក!"

ពេលនោះនាងក៏ផ្អែកទៅលើជញ្ជាំងនៅក្បែរអ្នកហើយចាប់ផ្តើមនិយាយរឿងរបស់នាង។

"អញ្ចឹងយើងនិយាយហើយណា!! កាលពីព្រឹកមិញ យើងទៅកន្លែងរបស់ពូយើងជួយរឹតទឹកដោះគោដូចសព្វដង ហើយយើងក៏បានប្រាប់គាត់ថាពួកយើងកំពុងតែរកវិធីដើម្បីរកលុយ។ ទាំងពូទាំងមីងនាំគ្នាចាប់អារម្មណ៍នូវអ្វីដែលយើងនិយាយ។ គាត់ឱ្យយើងអង្គុយចុះហើយប្រាប់យើងថាពួកគាត់មានគំនិតមួយដែលគាត់ចង់ប្រាប់យើង។ ជារៀងរាល់ថ្ងៃពួកគាត់ផលិតទឹកដោះគោបានច្រើនជាងមុនហើយយកទៅលក់។ អញ្ចឹងហើយទើប......"

សូរិយាក៏ឈប់និយាយត្រឹមនេះ។ អ្នកសួរដោយចង់ដឹងថា "សូរិយា!! អញ្ចឹងយ៉ាងម៉េច?"

នាងញញឹមហើយនិយាយថា "អីគេ?"

"អញ្ចឹងហើយទើបពួកគាត់ចង់បើកកន្លែងលក់មួយនៅឯផ្សារភូមិ ដើម្បីលក់ទឹកក្រឡុកការ៉េមនិងភេសជ្ជៈផ្សេងៗទៀត។មីងរបស់យើងនឹងមើលការខុសត្រូវកន្លែងនោះតែកន្លះថ្ងៃទេ ព្រោះគាត់ត្រូវទៅជួយការងារនៅកសិដ្ឋាន អញ្ចឹងហើយ

ទើបគាត់ត្រូវការមនុស្សម្នាក់ដើម្បីមើលការខុសត្រូវកន្លែងលក់ នៅពេលថ្ងៃនិងពេលល្ងាច។”

អ្នកស្រាប់តែបើកភ្នែកធំៗដោយក្ដីរីករាយ ព្រោះអ្នកសឹងតែមិនជឿអ្វីដែលអ្នកបានលឺ។ សូរិយាញញឹមហើយនិយាយថា៖ យើងថាហើយប្រាកដជាមានអ្នកដែលអាចជួយយើងបាន។

◈◈◈

ប្រហែលជាប្រាំមួយអាទិត្យក្រោយមក ទ្វារកន្លែងលក់លក់ទឹកដោះគោនិងទឹកឃ្មុំក៏បានបើកជាសាធារណៈ។ និយាយតាមត្រង់កន្លែងលក់នោះដូចជាតូបលក់ឥវ៉ាន់នៅផ្សារអញ្ចឹង។ ពូរបស់សូរិយាឈ្មោះ សំរិន បានទិញប្រដាប់ក្រឡុក និងទូទឹកកកដើម្បីដាក់ទឹកដោះគោ និងការ៉េម។ គាត់បានចូលហ៊ុនគ្នាជាមួយអ្នកស្គាល់គ្នាឈ្មោះ លោកតាវិច្ឆូ ដែលជាអ្នកចិញ្ចឹមឃ្មុំ ហើយគាត់អាចផលិតទឹកឃ្មុំដែលមានរសជាតិឆ្ងាញ់បំផុតប្រចាំតំបន់។ គ្មានអ្វីចម្លែកឡើយដែលការ៉េមរសជាតិទឹកឃ្មុំ និងទឹកដោះគោក្រឡុកក្លាយជាភេសជ្ជៈពេញនិយមប្រចាំកន្លែងលក់ ចំណែកឯទឹកឃ្មុំក្រឡុករបស់លោកតាវិច្ឆូក៏មានដាក់លក់ផងដែរ។

អ្នកជួយគូស្លាកសញ្ញាកន្លែងលក់លក់ទឹកដោះគោ និងទឹកឃ្មុំ សូរិយានិងមីងជា ដោយមានពូ សំរិនជាអ្នកព្យួរស្លាកសញ្ញានោះ។ អ្នកនិងសូរិយាដើរបិទខិតប័ណ្ណនៅជុំវិញនិងក្នុងភូមិស្ដីពីការបើកសម្ពោធកន្លែងលក់ ដោយមានការផ្ដល់បញ្ចុះតម្លៃពាក់កណ្ដាលលើការទិញទឹកក្រឡុកទឹកដោះគោ និងការ៉េមរសជាតិទឹកឃ្មុំ។ នេះជាគំនិតរបស់ពូ សំរិន ព្រោះគាត់ចង់ឱ្យអ្នកភូមិភ្លក់រសជាតិទឹកក្រឡុក និងការ៉េមថាតើវាឆ្ងាញ់កម្រិតណា!

មើលទៅដូចជាបានការ។ នៅយប់បើកសម្ពោធកន្លែងលក់អ្នកមានអារម្មណ៍ថាភូមិទាំងមូលបានមកជួយទិញទំនិញពីកន្លែងលក់របស់យើង។ អ្នកធ្វើការនៅពីក្រោយពូសំរិន មីងជា និងសូរិយា។ អ្នកមានអារម្មណ៍ថាមានគេគ្រវែងអ្នកឱ្យទៅដល់ត្រើយប្រៀបបានទៅនឹងករណីលង់ទឹក ឬក៏ហែលទឹកអញ្ចឹង។



បីម៉ោងក្រោយមក ទឹកដោះគោ និងទឹកឃ្មុំលក់ដាច់អស់គ្មានសល់ឡើយ។ ពូសំរិន និងមីងជាដូចជាសប្បាយចិត្តនឹងអ្វីដែលគាត់បានធ្វើ។ ប៉ុន្តែ ដូចដែលពួកគេរំលឹកអ្នក ភស្តុតាងជាក់ស្តែង នៃជោគជ័យពិតប្រាកដជាលទ្ធផលល្អនៅតែបន្តមានបើកាលណាតំលៃនៅធម្មតា ហើយអតិថិជនទិញហើយត្រលប់មកម្តងទៀត។

◈◈◈

ពីរបីអាទិត្យដំបូង លក់មិនសូវជាដាច់ប៉ុន្មានទេព្រោះអ្នកភូមិមិនទាន់ទម្លាប់។ អ្នកឃើញថា ពូសំរិនថាកំពុងចាប់មានមន្ទិលសង្ស័យចំពោះគម្រោងនោះ។ ប៉ុន្តែយូរៗទៅ ការលក់ក៏កាន់តែប្រសើរឡើង ពេលរដូវក្តៅចូលមកដល់ ។

អ្នក និងសូរិយាប្តូរវេនគ្នាម្នាក់លក់ពេលរសៀល ម្នាក់លក់ពេលល្ងាច។ ការប្តូរវេននេះដំណើរការយ៉ាងរលូនព្រោះវាធ្វើឱ្យអ្នកទាំងពីរមានការតាំងចិត្ត។ សូរិយាត្រូវទៅប្រជុំក្រុមយុវជនមួយអាទិត្យពីរដង ហើយអ្នកក៏ត្រូវជួយមើលស៊ីតានិងការងារផ្ទះពេលដែលម្តាយរបស់អ្នកទៅរកត្រី។

មានថ្ងៃខ្លះម្តាយរបស់អ្នកនិងស៊ីតាទៅលក់ត្រីនៅផ្សារដែលនៅមិនឆ្ងាយ

ពីកន្លែងដែលអ្នកលក់ប៉ុន្មានឡើយ។

ប៉ុន្មានថ្ងៃនេះស៊ីតាចំណាយពេលនៅកន្លែងលក់ជាមួយអ្នកច្រើនជាងនៅជាមួយម្ដាយអ្នក។ អ្នកតែងគិតថានេះជាការស្រលាញ់គ្នារវាងបងប្អូនស្រីតែការពិតនាងគ្រាន់តែចង់បានទឹកក្រឡុកទឹកដោះគោតែប៉ុណ្ណោះ។ ពេលនាងបានហើយនាងក៏ទៅបាត់។ ពេលដែលអ្នកកំពុងតែហុចទឹកក្រឡុកទឹកដោះគោឱ្យទៅអតិថិជនរបស់អ្នក អ្នកមានអារម្មណ៍ថាដូចជាមានវត្ថុមានរបស់អ្នកណាម្នាក់។ អ្នកសម្លឹងមើលទៅក្រោមក៏ឃើញស៊ីតាកំពុងសម្លឹងមកអ្នក។

អ្នកសួរនាងថា "ត្រូវការកម្មង់អ្វីដែរ?"

នាងគ្រាន់តែញញឹមហើយសម្លឹងទៅប្រដាប់ក្រឡុកទឹកដោះគោ។ គ្រាន់តែនាងក្រឡេក នាងអាចដឹងថាទឹកដោះគោជិតអស់ហើយ។ បន្តិចក្រោយមកនាងក៏ចង្អុលទៅវ៉ានីឡានិងទឹកឃ្មុំ។

អ្នកមិនប្រកាន់នឹងការងារនេះឡើយព្រោះអ្នកអាចជួបមនុស្សថ្មីៗជាច្រើននាក់។ ពូសំរិនបានដាក់កូនកៅអីពីរបីបន្ថែមទៀតនៅកន្លែងលក់ ហើយធ្វើឱ្យអ្នកមានឱកាសនិយាយលេងជាមួយភ្ញៀវនៅពេលដែលពួកគេអង្គុយញ៉ាំទឹកក្រឡុកទឹកដោះគោ និងការ៉េម។

លុយដែលអ្នកទទួលបានមិនសូវជាច្រើនប៉ុន្មានទេ ព្រោះពូសំរិនមិនសូវជាបានប្រាក់ចំណេញដែរ។ អ្វីដែលអ្នកទទួលបានពីការងារនេះគឺការសន្សំអ្វីម្យ៉ាងនិងយកវាទុកបានរៀងរាល់សប្ដាហ៍។

◈◈◈

ជាអកុសលជីវិតនៅផ្ទះមិនសូវជាល្អប៉ុន្មានឡើយ។ ស្ថានភាពរបស់ពុកអ្នកកាន់តែយ៉ាប់ឡើង។ សូម្បីតែដើរទៅមករោងដាំបន្លែក៏ជាឧបសគ្គសម្រាប់ពុកអ្នកដែរ ព្រោះធ្វើឱ្យគាត់ក្អកកាន់តែខ្លាំង។ ទោះជាជម្ងឺរបស់ពុកអ្នកកាន់តែដុនដាប ក៏គាត់នៅតែចង់បង្ហាញថាគាត់នៅតែអាចទៅរកត្រីបានច្រើនជាងម្ដាយរបស់អ្នករកបាន។ គាត់នៅតែខឹងក្រេវក្រោធទាំងដែលការពិត គាត់មិនមានសូម្បីតែកម្លាំងជួសជុលសំណាញ់។

រឿងម្យ៉ាងដែលគាត់មិនស្រេកស្រុតនោះគឺចំនួនស្រាបៀរដែលគាត់ពិសារ។ ពេលដែលគាត់កាន់តែឈឺគឺគាត់កាន់តែផឹក។សំណាងដែរ ឱ្យតែគាត់ពិសារស្រាបៀរបានពីរបីកំប៉ុងគឺគាត់សម្រាន្តមុខទូរទស្សន៍ហើយ។ អញ្ចឹងហើយបានម្ដាយរបស់អ្នកតែងតែឱ្យគាត់ពិសារស្រាបៀរជារៀងរាល់យប់។ ការពិតគ្រួសារសឹងតែមិនអាចរកលុយទិញស្រាបៀរឱ្យគាត់ពិសារបាន តែក៏ល្អម្យ៉ាងសម្រាប់អ្នក

រាល់គ្នានៅក្នុងគ្រួសារ (បូករួមទាំងស្ថានភាពក្នុងផ្ទះផងដែរ) ពេលដែលពុកអ្នកសម្រាន្តលក់បាត់។ តែធ្វើបែបនេះក៏មិនបានផលគ្រប់ពេលដែរ ព្រោះគាត់ប្រាប់ផ្តើមខឹងហើយគំរាមម្តាយអ្នក។ ដូច្នេះគ្រប់គ្នាត្រូវតែប្រយ័ត្នមាត់ពេលដែលនិយាយជាមួយពុកអ្នកក្នុងពេលដែលគាត់ខឹង ឬនៅពេលដែលពុកអ្នកនៅជិត។

តែគ្មានអ្វីអាចទប់បានឡើយនៅពេលដែលម្ចាស់បំណុលស្នេកគី មកទារលុយនៅពេលយប់។

កាលពីប៉ុន្មានខែមុខ គ្រួសារអ្នករកត្រីមិនបានឡើយ។ ហើយនេះជាហេតុផលដែលធ្វើឱ្យម្តាយរបស់អ្នកមិនអាចសងបំណុលគេបានទាន់ពេល។ ពេលដែលម្តាយរបស់អ្នកយកលុយទៅសងលោក ស្នេកគី គាត់ប្រាប់ថាគាត់មិនយកលុយនោះឡើយព្រោះវាមិនគ្រប់។ ប៉ុន្តែម្តាយអ្នកគ្មានអ្វីនិយាយក្រៅពីសន្យាថានឹងសងបន្ថែមនៅខែក្រោយៗទៀត។

នៅយប់នោះពេលដែលអ្នកលឺសម្លេងគោះទ្វារអ្នកមានអារម្មណ៍ថាខ្លាចបំផុត។ ម្តាយរបស់អ្នកបើកទ្វារហើយឃើញលោក ស្នេកគីឈរនៅពីមុខទ្វារ។ គ្រាន់តែឃើញទឹកមុខរបស់គាត់ ក៏អ្នកអាចដឹងថាគាត់មកទារលុយ។ គាត់ប្រាប់ថាគាត់គ្មានជម្រើសអ្វីក្រៅពីរឹបអូសយកផ្ទះរបស់អ្នកឡើយ។

ពុកអ្នកដែលកំពុងតែសម្រាន្តស្រមុកនៅពីមុខទូរទស្សន៍ព្រោះតែឥទ្ធិពលស្រាបៀរនោះ ស្រាប់តែភ្ញាក់ឡើងនៅពេលដែលលឺសម្លេងជេរប្រមាថលឺៗរបស់លោក ស្នេកគី ហើយពុកអ្នកក៏ងើបទៅមើលថាមានរឿងអ្វីកើតឡើង។

នេះជាអ្វីដែលម្តាយរបស់អ្នកតែងតែព្យាយាមការពារមិនឱ្យកើតមានឡើង។ ម្តាយរបស់អ្នកព្យាយាមឃាត់លោក ស្នេកគី នៅខាងមុខទ្វារមិនឱ្យចូល។ តែគាត់នៅតែចូលក្នុងផ្ទះដើម្បីមកយករបស់ដែលមានតម្លៃ។

ពេលដែលម្ចាស់បំណុលចូលក្នុងផ្ទះដើរកាត់ពុករបស់អ្នក ហើយដកឌុយខ្សែទូរទស្សន៍បម្រុងនឹងលើកយកទៅ ស្រាប់តែពុករបស់អ្នកចាប់ផ្តើមផ្ទុះកំហឹងហើយគ្រាប់ភ្នែកគាត់សឹងតែធ្លាយចេញមកក្រៅ។ ពុកចាប់ផ្តើមវាយម្ចាស់បំណុលហើយគប់គ្រឿងសង្ហារឹមទៅលើគេ និងបុរសពីអ្នកទៀតដែលដើរកាត់បន្ទប់។ ហេតុការណ៍ពេលនោះពិតជាអាក្រក់មែនទែនពេលដែលមានបុរសពីរនាក់ជេរគ្នាព្រមទាំងប្រតាយប្រតប់គ្នា ។

ពេលនោះអ្នកប្រាប់ខ្លួនឯងថាអ្នកត្រូវតែធ្វើអ្វីម្យ៉ាង។ អ្នករត់ចូលទៅក្នុងបន្ទប់របស់អ្នកហើយយកអ្វីពីក្នុងហឹបហើយក៏ប្រញាប់រត់ចេញមកវិញ។ ពេលអ្នកត្រលប់មកដល់បន្ទប់ទទួលភ្ញៀវវិញ លោក ស្នេកគី កំពុងតែនៅលើពុករបស់អ្នក

ហើយប្រុងវាយអ្នកនឹងកៅអីបាក់។

អ្នកស្រែកថា "កុំ!!! យកអានេះទៅ!"

ម្ចាស់បំណុលងាកមើលហើយឃើញអ្នកកំពុងហុចលុយទៅឱ្យគេ។ គេក៏ងើបចេញពីពុករបស់អ្នកហើយដើរមករកអ្នក។ គាត់យកលុយហើយសម្លឹងលុយនោះ។ វាជាលុយដែលអ្នកសន្សំតាំងពីអ្នកចូលធ្វើការនៅកន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំ។

ម្ចាស់បំណុលនិយាយថា៖ខែក្រោយយើងត្រូវការច្រើនជាងនេះ។និយាយរួចក៏ដើរចេញទៅ។

◈◈◈

នៅយប់បន្ទាប់ អ្នកត្រូវពិចារណាឡើងវិញ។ គ្រួសាររបស់អ្នកពិតជាត្រូវការលុយខ្លាំងហើយត្រូវការប្រញាប់ទៀតផង។ អ្នកគិតថាបើសិនជាអ្នកទូរសព្ទទៅដេវីជារឿងដែលល្អបំផុត ព្រោះគេធ្លាប់ប្រាប់អ្នកថាគេអាចរកការងារឱ្យអ្នកបានតែក្នុងពេលមួយអាទិត្យទេ។

ឬមួយអ្នកត្រូវទៅធ្វើការនៅកន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំធម្មតាតែរៀបចំលិខិតឆ្លងដែនសម្រាប់ការងារឆ្លងដែននោះ?

រឿងតែម្យ៉ាងដែលអ្នកកំពុងតែគិតគឺធ្វើការសម្រេចចិត្តដ៏សែនពិបាក ហើយអ្វីដែលកាន់តែពិបាកនោះគឺអ្នកត្រូវសម្រេចចិត្តឥឡូវនេះ។



**បើអ្នកសម្រេចចិត្តទូរសព្ទទៅដេវី សូមទៅកាន់ទំព័រទី១២**

១២



**បើសិនអ្នកសម្រេចចិត្តនៅធ្វើការទោរដដែលសូមទៅកាន់ទំព័រទី ៥៥**

៥៥

# ទូរសព្ទ



អ្នកគិតថាវាជាឱកាសល្អបំផុតដើម្បីយកទូរសព្ទរបស់ថៅហ្វាយស្រីទូរសព្ទទៅរកជំនួយនៅពេលដែលគាត់កំពុងតែសម្រាន្តពេលថ្ងៃត្រង់។ ឱកាសមិនមែនមានរហូតទេ ព្រោះយូរៗម្ដង ទើបគាត់សាកថ្មទូរសព្ទរបស់គាត់ចោលនៅក្នុងផ្ទះបាយពេលដែលគាត់សម្រាកកន្លះម៉ោង។

ពេលដែលគាត់សម្រាកគាត់តែងទុកកូនគាត់ឱ្យអ្នកមើលហើយគាត់តែងបិទទ្វារបន្ទប់ ព្រោះមិនចង់ឮសម្លេងកូនរំខានដំណេករបស់គាត់។

អ្នកសម្រេចចិត្តពេលដែលមានឱកាសល្អមកដល់ ជម្រើសដែលល្អបំផុតគឺអ្នកត្រូវទាក់ទងទៅសូរិយា។ អ្នកខ្លាចថាពេលដែលអ្នកទូរសព្ទទៅម្ដាយរបស់អ្នកគាត់ចុចច្រឡំប៊ូតុង ហើយរំខានដល់ការងាររបស់អ្នកទើបអ្នកមិនទូរសព្ទទៅរកគាត់។ អ្នកច្បាស់ក្នុងចិត្តថា សូរិយាប្រាកដជាធ្វើសកម្មភាពចំពោះព័ត៌មានដែលអ្នកបានផ្ដល់ឱ្យនាង ហើយបញ្ជូនព័ត៌មាននេះទៅប្រាប់គ្រួសាររបស់អ្នក។ មុនពេលដែលអ្នកចាកចេញមកសូរិយា(មនុស្សដែលម៉ត់ចត់)បានប្រាប់លេខទូរសព្ទរបស់នាងព្រមទាំងដាក់លេខកូដប្រទេសនៅខាងមុខផងដែរ។ ដូច្នេះអ្នកគ្រាន់តែចុចលេខទូរសព្ទដែលនាងបានប្រាប់នោះជាការស្រេច។ អ្នកចាប់ផ្ដើមកាន់ទូរសព្ទ ហើយចាំឱកាសល្អនឹងអាលវាយលេខសូរិយាចូល។

◈◈◈

ពេលដែលអ្នកកំពុងតែរង់ចាំឱកាសល្អ ស្ថានភាពនៅក្នុងផ្ទះនៅតែតានតឹង។ អ្នកព្យាយាមមិនប្រឆាំងនឹងថៅហ្វាយស្រីមិនថាក្នុងកាលៈទេសៈណាក៏ដោយ។ ធ្វើបែបនេះមានន័យថាអ្នកមិនត្រូវធ្វើទឹកមុខមិនសប្បាយចិត្តនៅពេលធ្វើការ ហើយអ្នកត្រូវធ្វើតាមបញ្ជារបស់គាត់។ តែមានស្ថានភាពផ្សេងទៀតដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អទាល់តែសោះគឺពេលដែលថៅហ្វាយប្រុសឱបអ្នក។ តាំងពីពេលនោះមកគាត់តែងតែព្យាយាមករកឱកាសល្អដើម្បីចូលមកជិតអ្នក។

អ្នកចាប់ផ្តើមភ័យព្រួយនៅពេលដែលចៅហ្វាយស្រីទៅលេងមិត្តរបស់គាត់។

ជាធម្មតាគាត់តែងតែឱ្យកូនៗរបស់គាត់នៅជាមួយអ្នក។ នៅពេលមួយនោះ ចៅហ្វាយប្រុសហៅអ្នកឱ្យចូលក្នុងបន្ទប់ធ្វើការរបស់គាត់ តែអ្នកប្រាប់គាត់ថាអ្នកមិនអាចទុកក្មេងៗចោលបានឡើយ។ គាត់និយាយថាតែមួយភ្លែតទេ។ ពេលដែលអ្នកចូលក្នុងបន្ទប់ធ្វើការរបស់គាត់ គាត់បិទទ្វារហើយព្យាយាម អ្នកគ្រវីក្បាលហើយនិយាយថា "កុំអី!! ខ្ញុំសូមអង្វរ។"

គាត់និយាយថា "សុំថើបតែមួយខ្សឺតទេ! ថើបហើយនាងចេញទៅវិញបានហើយ។"

គាត់ព្យាយាមថើបថ្ពាល់របស់អ្នក តែអ្នកព្យាយាមរត់ទៅវិញសារជាថ្មី។

គាត់និយាយទាំងញញឹមថា "អេ! នាងនិងខ្ញុំជាមិត្តនឹងគ្នាហើយណា។ នាងត្រូវតែមានមិត្តម្នាក់នៅក្នុងផ្ទះនេះ។ ចំណែកប្រពន្ធរបស់ខ្ញុំមិនមែនជាមិត្តរបស់នាងឡើយ។ ខ្ញុំនឹងធ្វើឱ្យអ្វីៗប្រសើរឡើង។ យើងជាមិត្តនឹងគ្នាបានអត់?"

អ្នកមិនឆ្លើយតបឡើយ។

គាត់និយាយថា "ប្រសើរឡើងបែបនេះ។ នាងឃើញទេ?" បន្ទាប់មកគាត់ក៏ញញឹមម្តងទៀតហើយលែងអ្នកឱ្យទៅវិញ។ អ្នកក៏ប្រញាប់ចេញពីទីនោះហើយត្រលប់ទៅមើលក្មេងៗ។

ក្រោយពីមានការប្រែប្រួល អ្នកសម្រេចចិត្តច្បាស់ជាងមុនថាអ្នកត្រូវតែចេញពីទីនេះឱ្យបានឆាប់ ហើយអ្នកគិតថាការចាប់ផ្តើមមានទំនាក់ទំនងជាមួយពិភពខាងក្រៅជារឿងដែលល្អបំផុត។

◈◈◈

ចុងក្រោយវាក៏កើតឡើងមែន។

នារសៀលមួយ ចៅហ្វាយស្រីហុចកូនគាត់ឱ្យអ្នកហើយប្រាប់ថាគាត់ចូលទៅសម្រាក។ អ្នកសម្លឹងទៅលើតុ ហើយឃើញទូរសព្ទរបស់គាត់កំពុងតែសាកថ្មចោលនៅលើនោះ។ បេះដូងរបស់អ្នកកំពុងលោតញាប់។ នេះជាពេលដែលអ្នកតែងតែទន្ទឹងរង់ចាំ។ ចៅហ្វាយស្រីកំពុងចុះទៅក្រោមតម្រង់ទៅបន្ទប់គេងរបស់គាត់។ អ្នករង់ចាំឱ្យទ្វារបន្ទប់បិទ ហើយរង់ចាំបន្តិចសិនដើម្បីឱ្យប្រាកដចិត្តថាគាត់សម្រាន្តលក់ហើយ។ អ្នកបានដាក់កូនរបស់គាត់លើកៅអីរុញហើយលួងគេឱ្យគេង។ ពីរបីនាទីក្រោយមកគ្មានសម្លេងចេញពីបន្ទប់គេងរបស់ចៅហ្វាយស្រីឡើយ ចំណែកកូនរបស់គាត់ក៏គេងលក់ដែរ។

អ្នកត្រៀមលេខទូរសព្ទរបស់សូរិយារួចហើយ។ អ្នកដើរទៅយកទូរសព្ទរបស់ថៅហ្វាយស្រី។ អ្នកកាន់ទូរសព្ទនោះទាំងញ័រដៃ។ អ្នកដកដង្ហើមវែងៗហើយចុចលេខទូរសព្ទរបស់សូរិយា។ ពីមុនមកបេះដូងរបស់អ្នកមិនដែលលោតញាប់បែបនេះឡើយ។

អ្នកបិទភ្នែក ហើយស្តាប់ដោយយកចិត្តទុកដាក់។ មានសម្លេងតិចៗ ក្រោយមកក៏គ្មាន។ តែចេញមិនកើតឡើយ។ ពេលដែលអ្នករៀបនឹងចុចម្តងទៀត ស្រាប់តែកូនរបស់ថៅហ្វាយស្រីភ្ញាក់ហើយចាប់ផ្តើមយំ។ អ្នកដឹងថាម្តាយរបស់គេប្រាកដជាភ្ញាក់ដែរបើសិនជាអ្នកមិនលួងក្មេងឱ្យបាត់យំ។ អ្នកលើកក្មេងហើយអង្រួនតិចៗ។ ពេលដែលអ្នកច្បាស់ថាក្មេងនោះគេងលក់អ្នកក៏តេទៅសូរិយាម្តងទៀត។

ពេលនេះអ្នកលឺសម្លេងទូរសព្ទរោទិ៍។ ពេលដែលអ្នកលើកទូរសព្ទអ្នកក៏បានឮសម្លេងរបស់សូរិយានិយាយថា "អាឡូ!"

អ្នកនិយាយខ្សឹបទៅវិញថា "សូរិយា!"

សូរិយាស្តាប់អ្នកមិនលឺទេ។ នាងក៏និយាយម្តងទៀតថា "អាឡូ!"

អ្នកនិយាយខ្សឹបលឺជាងមុនថា "សូរិយា! គឺយើងណា។"

ពេលនេះនាងស្តាប់បានហើយ។ អ្នកលឺនាងស្រែកយំ។

អ្នកក៏និយាយថា "សូរិយា! ស្តាប់ខ្ញុំសិន"

តែនាងមិនព្រមស្តាប់ឡើយ។ នាងសួរអ្នកជាច្រើនសំនួរ។ "ឯងនៅឯណា? ម៉េចបានជាឯងមិនទាក់ទងមកពួកយើង? តើឯងដឹងថាគ្រប់គ្នាបារម្ភពីឯងប៉ុណ្ណាទេ? ម៉ែរបស់ឯងកំពុងតែពិបាកចិត្ត។"

អ្នកចង់តែស្រែកឱ្យនាង។ អ្នកចង់ប្រាប់នាងឱ្យបិទមាត់ ហើយស្តាប់សិន។ តែអ្នកមិនអាចធ្វើបានឡើយ។ អ្នកត្រូវរង់ចាំទាល់តែនាងឈប់និយាយ។

បន្ទាប់មកអ្នកក៏នៅស្ងៀម។ អ្នកបានឮសម្លេងចេញពីបន្ទប់ដេក។ ថៅហ្វាយស្រីដែលនៅខាងលើដើរចុះឡើង។ ពេលនេះ ទ្វារបន្ទប់ដេកក៏បើក ហើយអ្នកបានឮសម្លេងគាត់ដើរចេញមកទីធ្លាខាងមុខ។



សូរិយាកំពុងហៅឈ្មោះអ្នកតាមទូរសព្ទ ប៉ុន្តែអ្នកមិនអាចឆ្លើយមកវិញបានទេ។ ពេលនេះ ចៅហ្វាយស្រីកំពុងចុះមកទីធ្លាខាងមុខ។ អ្នកក៏បិទទូរសព្ទ ហើយប្រញាប់ដាក់ទូរសព្ទទៅកន្លែងដើមវិញ។

បន្តិចក្រោយមកចៅហ្វាយស្រីក៏ចូលទៅក្នុងផ្ទះបាយ។មើលទៅគាត់ដូចជាកំពុងសង្ស័យពីរឿងអីមួយ ដូចជាថា គាត់បានឮសម្លេងអ្វីក៏មិនដឹង។អ្នកធ្វើដូចជាកំពុងនិយាយជាមួយក្មេងនោះចឹងនៅពេលអ្នកបីរលាក់គាត់នៅក្នុងដៃ ប៉ុន្តែអ្នកត្រូវងាកមុខចេញ ព្រោះអ្នកមានអារម្មណ៍ថា មានទឹកភ្នែកនៅលើថ្ពាល់របស់អ្នក។

បន្ទាប់ពីបានសង្កេតហេតុការណ៍នោះពីរបីនាទីហើយ ចៅហ្វាយស្រីក៏គិតថា គ្មានអ្វីកើតឡើងទេ ហើយក៏ត្រឡប់ទៅវិញ។

បន្ទាប់មក ទូរសព្ទគាត់ក៏ចាប់រោទិ៍។

បេះដូងរបស់អ្នករន្ធត់ណាស់។ អ្នកដឹងថាអ្នកណាកំពុងទូរសព្ទមក ។

នៅពេលចៅហ្វាយស្រីទៅលើកទូរសព្ទ គាត់ឃើញលេខទូរសព្ទមកពីក្រៅប្រទេស ហើយក៏មើលមកអ្នកភ្លាម។ បន្តិចក្រោយមក គាត់ស្ទាក់ស្ទើរ ហាក់បីដូចជាគាត់មិនដឹងថា គួរលើទូរសព្ទនោះឬអត់នោះទេ។

អ្នកបានបន់ស្រន់ថា សូមកុំឱ្យគាត់លើកទូរសព្ទនោះអី! កុំអី!

បន្ទាប់ពីទូរសព្ទរោទិ៍ច្រើនដងហើយនោះគាត់ក៏ចុចទទួលតែមិននិយាយអីទេ។ សូម្បីតែអ្នកកំពុងឈរនៅឆ្ងាយពីទូរសព្ទប៉ុណ្ណឹងហើយ អ្នកអាចឮសម្លេងរំជួលចិត្តរបស់ស្ត្រីសួរិយា នៅចុងម្ខាង ហៅឈ្មោះរបស់អ្នក និងនិយាយថា "អាទ្បូ! អាទ្បូ!"។ ថៅកែស្រីស្ដាប់ដោយកែវភ្នែកសម្លឹងជាប់មករកអ្នក។ បន្ទាប់មក គាត់ក៏ចុចបិទ ហើយបិទទូរសព្ទតែម្ដង។

អ្នកដឹងថា នឹងមានរឿងកើតឡើងនៅពេលបន្ទាប់ពីនោះ។ អ្នកមិនសម្លឹងមើលទៅគាត់ទេ ប៉ុន្តែអ្នកអាចមានអារម្មណ៍ដឹងថា កែវភ្នែករបស់គាត់សម្លឹងមកអ្នកពោរពេញដោយកំហឹង។ គាត់បានមកយកកូនរបស់គាត់ទៅដាក់ក្នុងកៅអីរុញ បន្ទាប់មក ទាញអ្នកទៅទល់មុខគាត់ ហើយងក់ក្បាលដោយដឹងពីមូលហេតុនៅពេលឃើញថ្ពាល់របស់អ្នកជាប់ដាមដោយទឹកភ្នែក។

នៅពេលនោះ គាត់ក៏ទះកំផ្លៀងអ្នក។

◈◈◈

បន្ទាប់មក នៅពេលប្ដីគាត់មកដល់ផ្ទះ អ្នកក៏ឮប្រពន្ធគាត់និយាយខ្លាំងៗដោយកំហឹងអំពីហេតុការណ៍ទាំងមូល។

មិនយូរប៉ុន្មាន គាត់ក៏ចូលទៅក្នុងផ្ទះបាយ ហើយនិយាយម៉ាត់ៗជាមួយអ្នកឱ្យអ្នកចូលទៅក្នុងការិយាល័យរបស់គាត់។

នៅពេលអ្នកចូលទៅដល់ គាត់បានទាញទ្វារបិទឮសូរគ្រាំងពីក្រោយអ្នក ហើយក៏ចាប់ផ្ដើមស្រែកខ្លាំងៗឮពេញផ្ទះ។ រឿងដែលចម្លែកនោះគឺ គាត់ហាក់ដូចជាមិនខឹងសោះ ហើយគាត់បែរជាខំមិចភ្នែកដាក់អ្នកទៅវិញ។ បន្ទាប់មក គាត់ក៏ខំធ្វើរឿងដែលកាន់តែគួរឱ្យភ្ញាក់ផ្អើល។ គាត់លើដៃរបស់គាត់ ហើយអ្នកគិតថា គាត់នឹងទះកំផ្លៀងអ្នក តែផ្ទុយទៅវិញ គាត់វាយលើខ្នងដៃរបស់គាត់សោះ គឺគាត់វាយយ៉ាងខ្លាំង។ នៅពេលនេះ អ្នកក៏ដឹងថា សម្លេងស្រែកឱ្យខ្លាំងៗនោះ គឺដើម្បីឱ្យប្រពន្ធគាត់នៅខាងក្រៅអស់ចិត្តឈប់ខឹងប៉ុណ្ណោះ។ គាត់ធ្វើបែបនេះពីរបីដង បន្ទាប់មកគាត់ឱ្យអ្នកខ្ទប់មុខខ្លួនឯងដើម្បីឱ្យឃើញថាអ្នកត្រូវគាត់ទះកំផ្លៀង។

មុនពេលចាកចេញ គាត់ញញឹម ហើយមិចភ្នែកដាក់អ្នកម្ដងទៀត។ ការព្រមព្រៀងរបស់អ្នកនេះក៏ត្រូវលាក់ទុកជាការសម្ងាត់។

គាត់ក៏ស្រែកដោយពាក្យគ្រោតគ្រាតថា "ថ្ងៃក្រោយ មិនត្រូវធ្វើចឹងទៀតទេ!" បន្ទាប់មក គាត់កន្ត្រាក់បើកទ្វារ ហើយក៏ស្ទុះចេញទៅក្រៅ។

ចៅហ្វាយស្រីកំពុងសម្លឹងទៅអ្នក នៅពេលអ្នកខ្ទប់មុខរត់ចូលទៅផ្ទះបាយ។

◈◈◈

ចាប់តាំងពីថ្ងៃនោះមក អ្វីៗមួយចំនួននៅក្នុងផ្ទះក៏មានការប្រែប្រួល។ ចៅហ្វាយស្រីពុំដែលទុកទូរសព្ទចោល និងផុតពីភ្នែករបស់ខ្លួនឡើយ ហើយគាត់ហាក់ដូចជាប្រាប់ទៅអ្នកដោយក្ដីរីករាយថា គាត់បានប្ដូរលេខទូរសព្ទរបស់ខ្លួនហើយ។

ហេតុការណ៍នោះក៏បានធ្វើឱ្យប្ដីប្រពន្ធពីរនាក់នោះបានដឹងខ្លួនថា អ្នកប្រហែលជាកំពុងតែចង់រត់គេចខ្លាំងណាស់ ហើយរឿងនេះបានធ្វើឱ្យគាត់ទាំងពីរកាន់តែមានការប្រុងប្រយ័ត្នលើអ្វីគ្រប់យ៉ាងជាងមុន។ អ្វីដែលគួរឱ្យរន្ធត់ចំពោះអ្នកនោះគឺ រឿងនេះបានធ្វើឱ្យប្ដីប្រពន្ធពីរនាក់នេះរាំងខ្ទប់បង្អួចតូចដែលនៅខាងលើជាប់ដំបូលផ្ទះ។ នៅពេលអ្នកបានឮសម្លេងញញួរដំនៅជាន់លើ អ្នកមានអារម្មណ៍ថាផ្លូវចុងក្រោយបំផុតដែលអាចឱ្យអ្នករត់គេចខ្លួនបាននោះទើបត្រូវបានគេដំដែកគោលភ្ជិតអស់ហើយ។

នៅពេលនេះ ក្ដីសង្ឃឹមតែមួយគត់របស់គាត់ គឺពឹងផ្អែកលើពិភពលោកខាងក្រៅ និងការដែលស្វាមីយា និងគ្រួសាររបស់នាងបានដឹងថា អ្នកនៅមានជីវិតនៅឡើយទេ។ លើសពីនេះ ពួកគាត់ប្រាកដជាបានដឹងតាមរយៈទំនាក់ទំនងតាមទូរសព្ទ ដែលធ្វើឱ្យអ្នកមានរឿងបែបនេះនោះ។ ជាការពិត នៅពេលនេះពួកគេនឹងបង្ខំដេវីឱ្យជួយតាមស៊ើបរកអ្នក ឬបើមិនដូច្នេះទេ ពួកគាត់ប្រហែលជានឹងប្ដឹងប៉ូលីស ដែលនឹងគំរាមចាប់ដេវីដាក់គុកប្រសិនបើដេវីមិនប្រាប់រឿងរ៉ាវគ្រប់យ៉ាងដល់ពួកគាត់ទេ។

ប៉ុន្តែ តើនឹងមានរឿងអីកើតឡើង ប្រសិនបើដេវីពិតជាមិនបានដឹងថាអ្នកនៅទីណាទេនោះ? តើនឹងមានរឿងអីកើតឡើង បើគាត់មិនបានដឹងអ្វីទៀតអំពីអ្នកទេ បន្ទាប់ពីបានដាក់អ្នកលើទូករួចហើយ?

ទេ! អ្នកមិនអាចឱ្យខ្លួនឯងគិតបែបនេះទេ។ អ្នកត្រូវតែមានសង្ឃឹមជានិច្ច។ ប្រាកដជាមានផ្លូវដែលអាចឱ្យពួកគាត់រកអ្នកឃើញ។ ពួកគាត់នឹងមិនបោះបង់ការខិតខំតាមស្វែងរកអ្នកឡើយ។

◈◈◈

ប៉ុន្តែនៅពេលផុតពីច្រើនសប្ដាហ៍រហូតដល់ជាច្រើនខែក្ដីសង្ឃឹមរបស់អ្នកក៏កាន់តែពិបាកនឹងស្ថិតនៅបានយូរណាស់។ គំនិតផ្សេងៗក៏ចូលមកក្នុងខួរក្បាលអ្នកគឺ ៖ តើពួកគាត់ប្រើអស់មធ្យោបាយហើយមែនទេ? តើពួកគាត់បានបោះបង់ខ្ញុំចោលហើយមែនទេ? តើអាចទេថា តើខ្ញុំពិតជាត្រូវគេមិនអើពើ ហើយត្រូវបាត់

ខ្លួនដោយគ្មានអ្នកណាតាមរកនោះ?

ប្រសិនបើនោះគឺជាការពិត ដែលអ្នកនៅតែមិនអាចជឿថាពិតនោះ អ្នកត្រូវតែគិតថា ជីវិតថ្មីរបស់អ្នកគឺអាចទៅជាបែបនេះឯង ហើយប្រសិនបើដូច្នេះមែននោះ អ្នកត្រូវមានជម្រើសកាន់តែធ្ងន់មួយចំនួនបន្ថែមទៀត។ ឧទាហរណ៍ តើអ្នកនឹងប្រាប់ថៅហ្វាយស្រីទេថាប្ដីគាត់ប្រុងធ្វើអ្វីខ្លះ? តើនឹងមានរឿងអ្វីខ្លះកើតឡើង ប្រសិនបើអ្នកប្រាប់ប្ដីគាត់?

តើពួកគេនឹងនៅតែទុកអ្នកឱ្យធ្វើការនៅទីនោះទៀតទេ? មែន! ប្រហែលជាទុក ព្រោះពួកគេមិនចង់ឱ្យអ្នកទៅប្ដឹងប៉ូលីសឡើយ។ ប៉ុន្តែ តើថៅហ្វាយស្រីជឿអ្នកឬទេ? ឬតើគាត់នឹងគិតថា អ្នកបានជំរុញគាត់ដោយប្រការណាមួយឬទេ? ហើយអ្នកនឹងក្លាយជាមនុស្សម្នាក់ដែលពួកគាត់ទាំងពីរនាក់មិនចូលចិត្ត។ មិនថាមានរឿងអ្វីកើតឡើងក៏ដោយ អ្នកដឹងហើយថា ថៅកែប្រុសនឹងគិតដល់គ្រួសារគាត់មុនមិនខាន ហើយអ្នកខ្លាចនូវអ្វីដែលបង្កប់នៅក្នុងស្នាមញញឹម និងក្ដីសង្ឃឹមរបស់គាត់។

ដូច្នេះតើអ្នកត្រូវនៅស្ងៀមធ្វើជាជឿឬធ្វើឱ្យគាត់សប្បាយចិត្ត? តើអ្នកទទួលអំណោយស្ករ សូកូឡាសម្ងាត់របស់គាត់ និងវត្ថុអនុស្សាវរីយ៍តូចៗដទៃទៀតឬទេ? តើអ្នកធ្វើជាចូលចិត្តគាត់ឬទេ? ប៉ុន្តែ បើអ្នកកាន់តែធ្វើជាជឿ គាត់កាន់តែចង់បាននិងកាន់តែទាមទារហើយកាន់តែទទួលរងគ្រោះថ្នាក់ត្រូវគេចាប់។ បើថៅហ្វាយស្រីដឹង តើនឹងមានរឿងអ្វីកើតឡើង? ...មែន! ចំពោះអ្វីដែលថៅហ្វាយស្រីនឹងធ្វើនោះឡើយ សូម្បីតែគិតក៏អ្នកមិនចង់គិតដល់ដែរ។

◈◈◈

ដូច្នេះហើយ នៅក្នុងរាត្រីស្ងាត់ ពេលគ្រប់គ្នានៅក្នុងផ្ទះកំពុងដេក អ្នករង់ចាំសម្លេងផ្សេងៗ គឺសម្រឹបជើងដើរ សម្លេងលាន់រនាបក្ដារ និងការនិយាយខ្សឹបៗអំពីឈ្មោះរបស់អ្នក។

ហើយនៅពេលនេះ ដល់ពេលដែលអ្នកត្រូវរត់គេចចេញពីផ្ទះនេះហើយវិលត្រឡប់ទៅភូមិរបស់ខ្លួនវិញហើយ។ ហើយនៅទីនោះ អ្នកឃើញនាងស៊ីតាកំពុងរាំធ្វើឱ្យឪពុករបស់អ្នកសើច ឃើញសូរិយា (នៅពេលនេះ ជាប្រធានសិស្សប្រចាំសាលា) ដែលកំពុងរៀបចំការរស់នៅរបស់អ្នកគ្រប់គ្នាមិនថាពួកគេចូលចិត្តឬអត់ និងឃើញម្ដាយរបស់អ្នកកំពុងអង្គុយនៅមាត់ទន្លេអូសសំណាញ់ ភ្នែកសម្លឹងមើលទូកបើកកាត់ក្រែងមានដំណឹងអីអំពីអ្នក។

**ចប់**

# ផ្លូវពិបាក



ក្រោយមក គេបានបញ្ជូនអ្នកទៅនៅក្នុងបន្ទប់លើជាប់ដំបូល ដែលអ្នកអាចមើលឃើញបង្អួចតូចកាន់តែជិត។ មានរឿងពីរដែលធ្វើឱ្យអ្នកបារម្ភអំពីវា។ ទីមួយគឺ នៅទីនោះខ្ពស់ណាស់ គឺនៅក្នុងកន្លែងស្តួចនៃដំបូលផ្ទះដែលធ្វើឱ្យពិបាកក្នុងការទៅឱ្យដល់។ អ្នកពិតជាត្រូវឡើងទៅលើកំពូលអ្វីមួយ ដើម្បីឡើងទៅដល់ទីនោះ។ សំណាងល្អមានឡាំងជាច្រើននៅជុំវិញហេតុនេះសង្ឃឹមថា អ្នកគួរតែអាចគរឡាំងទាំងនោះលើគ្នាបាន។

ក្តីបារម្ភទីពីរ គឺមើលទៅបង្អួចហាក់ដូចជាមិនធ្លាប់បានបើកយូរហើយ ហេតុនេះអ្នកសង្ឃឹមថាបង្អួចនោះ មិនមែនគាំងបើកមិនរួចនោះឡើយ។ ដើម្បីដឹងពីរឿងនេះអ្នកគ្រាន់តែឡើងទៅទីនោះ ហើយសាកល្បងបើកវាមើលប៉ុណ្ណោះ ប៉ុន្តែក្នុងពេលឥឡូវនេះមិនអាចធ្វើបែបនេះបានទេ បើមិនដូច្នេះទេថៅហ្វាយស្រីនឹងចាប់ផ្តើមឆ្ងល់ថាតើអ្នកឡើងទៅទីនោះធ្វើអីមិនខាន។

អ្នកសម្រេចថា ពេលវេលាល្អបំផុតដើម្បីប៉ងរត់គេចខ្លួនគឺនៅវេលាយប់ជ្រៅ ពេលគ្រប់គ្នាកំពុងដេកលង់លក់។ សំណាងល្អ ជណ្តើរឡើងទៅកាន់បន្ទប់ខាងលើជាប់ដំបូលនោះស្ថិតនៅមិនឆ្ងាយពីគ្រែរបស់អ្នកប៉ុន្មានឡើយ ហេតុនេះប្រសិនបើអ្នកមានការប្រុងប្រយ័ត្នជាងនេះនោះ ប្តីប្រពន្ធពីរនាក់នោះមិនគួរឮសម្រឹបជើងរបស់អ្នកពីបន្ទប់ដេករបស់ពួកគាត់ទាំងពីរឡើយ។

រឿងមួយដែលមានលក្ខណៈច្បាស់លាស់បំផុតនោះគឺថា អ្នកកំពុងធ្វើការចាកចេញកាន់តែឆាប់ គ្រាន់បើជាងនៅបង្អង់យូរទៀត ហើយមូលហេតុសំខាន់ដែលត្រូវធ្វើដូច្នេះគឺប្តីរបស់ថៅហ្វាយស្រី។ គាត់កំពុងព្យាយាមចាប់រូបអ្នកពេលនៅតែម្នាក់ឯងនៅពេលគាត់មានឱកាស ដូចជាឡើងមកពីក្រោយខ្នងអ្នក និងឱបរូបកាយអ្នកនៅពេលអ្នកកំពុងបោកគក់ខោអាវ។ អ្នកមានអារម្មណ៍ថាគ្មានអ្នកណាជួយឡើយនៅក្នុងស្ថានភាពបែបនេះ ព្រោះអ្នកបារម្ភថា ប្រសិនបើអ្នកប្រកែកប្រពន្ធគាត់នឹងឮ ហើយអ្នកដឹងថា បើសិនជាគាត់ដឹងថាមានអ្វីកើតឡើង អ្នកនឹង

ក្លាយជាមនុស្សម្នាក់ដែលត្រូវគេស្តីបន្ទោស។

អ្នកបានសម្រេចចិត្តព្យាយាមរត់គេចនៅយប់ថ្ងៃសៅរ៍។ ជាធម្មតា នៅយប់ថ្ងៃនោះប្តីប្រពន្ធពីរនាក់នោះតែងទទួលទានស្រាបៀរ និងស្រាជបគ្រាន់ជាការកំសាន្តជាមួយគ្នា ហេតុនេះ អ្នកសង្ឃឹមថា វានឹងធ្វើពួកគាត់ទាំងពីរដេកលង់លក់ស្កប់ស្កល់។

◈◈◈

មុនថ្ងៃសៅរ៍ អ្នកមានអារម្មណ៍ភ័យព្រួយ។ អ្នកដឹងថា ផែនការនេះអាចនឹងមានការភ្លាំងភ្លាត់បានយ៉ាងងាយ។ អ្នកក៏សម្រេចចិត្តយកទៅតាមខ្លួនតែសាក់កាដូរតូចមួយ ដែលមានសម្ភារចាំបាច់មួយចំនួនដូចជាលិខិតឆ្លងដែន (ដែលអ្នកទទួលបានពីដេវី) និងប្រាក់មួយចំនួនតូច ដែលអ្នកអាចលាក់ទុកតាមខ្លួនបាន។ អ្នកដឹងថា ខ្លួននឹងត្រូវការប្រើប្រាស់ប្រាក់នេះ នៅពេលចេញដល់ខាងក្រៅ។ ទោះបីអ្នកមិនមានគម្រោងច្បាស់លាស់នៅខាងក្រៅក៏ដោយ។ អ្នកបានសម្រេចចិត្តថា អ្វីដែលត្រូវធ្វើជាដំបូងគឺគិតតែពីរឿងចាកចេញពីផ្ទះនេះប៉ុណ្ណោះ។ បន្ទាប់មកអ្នកអាចគិតពីវិធីចាកចេញពីក្រុងនេះ ហើយវិលត្រឡប់ទៅភូមិរបស់ខ្លួនវិញ។

នៅល្ងាចនោះ អ្នកមានចិត្តរីករាយណាស់ ដោយបានឃើញថៅហ្វាយប្រុសកំពុងផឹកស្រាបៀរ ហើយរៀបគាស់ដបស្រាឱ្យប្រពន្ធគាត់ទៀត។ ពេលអ្នកកំពុងចំអិនអាហារលើចង្ក្រាន គាត់ក៏ចូលទៅដល់ផ្ទះបាយរកប្រដាប់គាស់ឆ្នុកដប។ គាត់ចេះតែប៉ះត្រូវអ្នកពេលគាត់ដើរឆ្លងទៅមក។ អ្នកអាចឃើញគាត់កំពុងសប្បាយចិត្ត ហើយខំធ្វើយ៉ាងណាឱ្យអ្នកមានប្រតិកម្មតបកមវិញ ប៉ុន្តែអ្នកតាំងចិត្តថាមិនបង្ហាញប្រតិកម្មអ្វីមួយតបទៅគាត់វិញឡើយ។

អ្នកកំពុងគិតក្នុងចិត្តថា៖នេះគឺជាលើកចុងក្រោយហើយ ដែលអ្នកនឹងប៉ះខ្ញុំ។ អ្នកគឺជាមនុស្សដែលគួរឱ្យអាណិត។

ទីបំផុត ដល់ពាក់កណ្តាលយប់ ពីរនាក់ប្តីប្រពន្ធក៏នាំគ្នាទៅដេក។ នៅពេលនោះ អ្នករង់ចាំនៅគ្រែរបស់អ្នក អស់ជាងមួយម៉ោង ហើយរឿងនេះមិនបានធ្វើឱ្យអ្នកបាត់ភ័យព្រួយនោះឡើយ។ អ្នកស្ទើរតែនឹងសម្រេចចិត្តលុបផែនការនោះចោលជាច្រើនដងទៅហើយ តែតាមពិត អ្នកដឹងថា អ្នកត្រូវតែសាកល្បងនៅក្នុងរឿងនេះ។

អ្នកចាំរៀងយូរបន្តិចគឺដើម្បីទុកឱ្យគ្រប់គ្នាបានគេលក់ស្កប់ស្កល់ហើយសិន។ បន្ទាប់មក អ្នកក៏ក្រោកអង្គុយ ហើយទាញយកសាក់កាដូរចេញពីក្រោមគ្រែរបស់អ្នក ។

◈◈◈



នៅពេលអ្នកឡើងលើនោះ សម្រឹបកាំជណ្តើរឈើនីមួយៗហាក់ដូចជាមានសូរខ្សាវ នៅពេលផ្ទះកំពុងមានសភាពស្ងប់ស្ងាត់។ អ្នកចេះតែស្រមៃជានិច្ចថា ចៅហ្វាយប្រុស ឬចៅហ្វាយស្រីស្រាប់តែលេចចេញមកពីក្នុងទីងងឹត ហើយចាប់កជើងរបស់អ្នក។

នៅទីបំផុត អ្នកបានទៅដល់ច្រកនោះ ហើយឡើងទៅក្នុងទីងងឹតក្នុងបន្ទប់លើជាប់ដំបូល។ ប្រភពពន្លឺតែមួយគត់គឺពន្លឺផ្កាយនៅលើមេឃ ដែលអ្នកអាចមើលឃើញតាមបង្អួចដ៏តូច។

ដើម្បីទៅឱ្យដល់បង្អួចនោះ អ្នកដឹងថា អ្នកត្រូវលើកឡាំងខ្លះ ប៉ុន្តែឡាំងទាំងនោះធ្ងន់ណាស់ ហើយឱ្យតែអ្នកលើកឡាំងមួយកាលណា អ្នកដឹងថា សម្លេងនេះត្រូវធ្វើឱ្យភ្ញាក់ដល់អ្នកនៅក្នុងផ្ទះទាំងមូល។ នៅពេលឡាំងទីមួយដាក់ត្រូវកន្លែងហើយ អ្នកក៏ខំសម្លឹងមើលទៅក្រោមតាមច្រកនោះ ដើម្បីពិនិត្យមើលក្រែងមានសកម្មភាពអ្វី ។ គ្រប់យ៉ាងនៅស្ងៀមស្ងាត់ ហើយគ្មានអ្វីកម្រើកឡើយ។

ពេលឈរលើឡាំងទីមួយ អ្នកអាចប៉ះតែត្រឹមបង្អួចប៉ុណ្ណោះ ប៉ុន្តែវានៅខ្ពស់ណាស់មិនអាចឱ្យអ្នករំកិលខ្លួនឡើងតាមនោះបានឡើយ។ អ្នកត្រូវការឡាំង

មួយទៀត។ អ្នកដើរស្ទៀបនៅក្នុងទីងងឹត ហើយទីបំផុតក៏ប៉ះត្រូវឡាំងមួយតូចជាងនោះ ដែលអ្នកអាចលើកវាបាន។ អ្នកខំលើកវាឡើងដាក់បន្ថុបលើឡាំងមួយទៀត។

ឥឡូវនៅពេលអ្នកឡើងទៅលើ អ្នករីករាយណាស់ ដោយដឹងថា អ្នកអាចឈោងដល់គន្លឹះបើកបង្អួចបានយ៉ាងងាយ។ ដូចការរំពឹងទុកមែន វាពិតជាតឹងណាស់ ហើយអ្នកត្រូវច្រានលើវាឱ្យខ្លាំងដើម្បីឱ្យរបើក។ រំពេចនោះវាក៏របើកមែន ហើយអ្នកដឹងថាមានខ្យល់ត្រជាក់កំពុងបក់ចូលតាមបង្អួចនោះ។

បង្អួចនោះតូចណាស់ អ្នកត្រូវដោះសាក់កាដូរអ្នកចេញ មុនពេលខំលូនចេញតាមនោះ។ អ្នកបានដាក់ដាក់កាដូរនៅលើដំបូលផ្ទះខាងក្រៅ ហើយក៏រំកិលខ្លួនឡើង។ អ្នកអាចលូនចូលបានពាក់កណ្តាល តែបន្ទាប់មកអ្នកត្រូវទាត់អង្រួនជើងចុះឡើងបន្តិចដើម្បីអូសខ្លួនអ្នកឡើងទៅលើ។ នៅពេលអ្នកទាត់អង្រួនជើងនោះ ប្រអប់ជើងអ្នកក៏ប៉ះត្រូវឡាំងតូចនោះ ហើយអ្នកក៏មានអារម្មណ៍ថាបាស់បើកៗ។ អ្នកព្យាយាមទប់វា តែហួសពេលហើយឡាំងតូចនោះខ្ទាតធ្លាក់ទៅលើកម្រាលបន្ទប់លើជាប់ដំបូលផ្ទះ។

អ្នកក៏ចាប់វាឡើងលើដំបូល។ អ្នកមិនជឿថារឿងនេះអាចកើតឡើងដូច្នេះទេ។ នៅពេលនេះអ្នកអាចឮអ្នកផ្ទះដែលនៅខាងក្រោមអ្នកចាប់ដឹងខ្លួនហើយ។

អ្នកឆក់យកសាក់កាដូររបស់អ្នក ហើយទម្លាក់ខ្លួនទៅក្រោមខ្នងរអិលចុះទៅក្រោមតាមដំបូលស័ង្កសី។ នៅពេលអ្នករអិលធ្លាក់ដល់ទបង្ហូរទឹកនៅតាមគែមដំបូលនោះ អ្នកបានឮសម្លេងស្រែកពីក្រោយអ្នក។ អ្នកក្រឡេកមកក្រោយ ឃើញក្បាលចៅហ្វាយប្រុសអើតចេញមកតាមបង្អួច។ អរគុណព្រះជាម្ចាស់ ខ្លួនគាត់ធំមិនអាចលូនចូលតាមប្រហោងនោះបានទេ។ គាត់ស្រែកខ្លាំងម្តងទៀត បន្ទាប់មកក៏ត្រឡប់ក្រោយចូលទៅក្នុងវិញ។

អ្នកខំសម្លឹងមើលតាមគែមដំបូលផ្ទះ។ មើលទៅដូចជាផ្លូវចង្អៀងនៅខាងក្រោម តែវាងងឹតខ្លាំងពេកធ្វើឱ្យអ្នកពិបាកមើលអ្វីនៅខាងក្រោមនោះណាស់។ អ្នកសម្រេចថា គ្មានជម្រើសអ្វីទេត្រូវតែលោត។ អ្នកដកដង្ហើមវែងៗ ហើយក៏ចាប់ផ្តើម។

អ្នកបានធ្លាក់ចុះឮសូរប្រោកក្នុងគំនរសម្បកកំប៉ុងនិងសំរាម។អ្នកខំប្រឹងក្រោកឈរឡើងប៉ុន្តែចុកត្រគាកមួយរំពេចធ្វើឱ្យអ្នកឈឺស្រៀវហើយអង្គុយចុះទៅវិញ។ អ្នកបានធ្លាក់បះត្រូវអ្វីមួយក្រឡាច់ធ្វើឱ្យចុកត្រង់ត្រគាក។ អ្នកក៏ទម្រេតខ្លួននៅទីនោះបន្តិច ដើម្បីឱ្យបាត់ឈឺ ខំឈ្លីដើម្បីឱ្យជើងមានកម្លាំងឡើងវិញ។ នៅពេលអ្នកកំពុងឈ្លី អ្នកក៏ចាប់ផ្តុំក្លិនអ្វីកខ្វក់នៅក្បែរៗនោះ ហើយនៅពេលនេះអ្នក

ក៏ដឹងថាអ្នកកំពុងនៅលើក្បែរគំនរបន្លែដ៏ធំមួយដែលនៅសេសសល់រលួយចោល។

អ្នកដឹងថាអ្នកត្រូវតែទៅមុខទៀត ហើយនៅពេលអ្នកហៀងនឹងក្រោកឡើងទៀតនោះ អ្នកក៏សង្កេតឃើញខ្លួនមនុស្សស្ងង់ៗក្នុងទីងងឹតកំពុងតែចុះមកតាមផ្លូវចង្អៀង។ ទោះបីអ្នកអាចមើលឃើញតែស្រមោលគាត់ក៏ដោយ អ្នកប្រាកដក្នុងចិត្តថា គឺជាចៅហ្វាយប្រុស។ អរគុណព្រះជាម្ចាស់ គាត់អត់មានពិលទេ ប៉ុន្តែគាត់កំពុងដើរលបៗដោយវាងវៃ ខំសម្លឹងមើលទៅស្រមោលផ្សេងៗ និងខំផ្ទៀងស្ដាប់សម្លេងផ្សេងៗដែលលាន់ឮចេញមក។

អ្នកក៏ទម្រេតចុះវិញខំរិះរកមធ្យោបាយ។ផ្លូវចង្អៀងងងឹតសូន្យសុងចំណែករូបអ្នកកំពុងស្ថិតនៅបាំងស្រមោល ប៉ុន្តែអ្នកដឹងថា អ្នកត្រូវតែធ្វើអ្វីម្យ៉ាងល្អជាងការលាក់ខ្លួនបែបនេះ។ អ្នកមើលទៅគំនរបន្លែដែលស្អុយរលួយ ហើយក៏គិតថាខ្លួនគ្មានជម្រើសទៀតទេ។អ្នកក៏វាចូលទៅក្នុងគំនរបន្លែរលួយនោះហើយក៏ទាញយកបន្លែរលួយៗនោះមកគ្របលើខ្លួន និងមុខឱ្យជិត។

បន្ទាប់មក អ្នកដេកស្ងៀមដូចគេស្លាប់ និងបួងសួងសុំកុំឱ្យគេឃើញអ្នក។

អ្នកអាចឮសម្លេងសម្រឹបជើងចៅហ្វាយប្រុសកំពុងតម្រង់មកយឺតៗ ប៉ុន្តែក៏មានសម្លេងមួយទៀត ដែលសំដៅមកកាន់តែជិត សូរប្រោកៗ។ អ្នកមិនចង់មើលទេ តែនៅជ្រុងម្ខាង អ្នកឃើញអ្វីកំពុងកម្រើក។ វារាងងងឹត ហើយចូលមកកាន់តែជិត។ ឥឡូវនេះឃើញហើយ គឺសត្វកណ្ដុរដ៏ធំមួយ។ អ្នកបានខាំបបូរមាត់អ្នកដើម្បីកុំឱ្យស្រែកខ្លាចសត្វកណ្ដុរ។

ចៅហ្វាយប្រុសក៏ទៅហួសកន្លែងដែលអ្នកកំពុងនៅ ហើយចេះតែឆ្ពោះទៅមុខ។អ្នកមិនហ៊ានកម្រើកឡើយរហូតទាល់តែអ្នកដឹងច្បាស់ថាគាត់បានទៅបាត់ហើយ។ នៅពេលនោះ កណ្ដុរក៏ធុំក្លិនអ្វីមួយនៅជុំវិញ ហើយបានចូលមកកាន់តែជិតទៅៗ។ អ្នករើសបានដំឡូងរលួយមួយកំណាត់ ហើយក៏គប់ពីមុខកណ្ដុរនោះ។ កណ្ដុរក៏រត់បាត់។

អ្នកក៏ក្រោកអង្គុយយឺតៗហើយពិនិត្យមើលផ្លូវចង្អៀង។គ្មានឃើញសម្រុយអីអំពីចៅហ្វាយប្រុសអ្នកឡើង។ អ្នកខំប្រឹងក្រោកឈរឡើងអស់ពីកម្លាំង អ្នកមានអារម្មណ៍ថាត្រគាករបស់អ្នកឡើងជាំយ៉ាងដំណំ។

អ្នកដើរទាំងប្រថុយទៅចុងម្ខាងនៃផ្លូវចង្អៀង ហើយខំសម្លឹងមើលទៅលើផ្លូវ។ អ្នកឃើញផ្ទះយ៉ាងច្បាស់។ អ្នកដើរចូលទៅក្នុងស្រមោលនៃម្លប់ ហើយក៏ចេញដំណើរនៅយប់នោះទៅ។

◈◈◈

នៅពេលព្រះអាទិត្យរះ នៅតាមផ្លូវមានមនុស្សច្រើនទៅៗ។ អ្នកមិនដឹងថាខ្លួនកំពុងនៅទីណា ឬទៅទីណាទេ។ មនុស្សម្នារជាច្រើនហាក់បីដូចជាកំពុងធ្វើដំណើរទៅធ្វើការ ហើយអ្នកឃើញគេនាំគ្នាគេចចេញឆ្ងាយពីអ្នកនៅពេលឃើញអ្នកដើរចូលទៅ។ អ្នកសម្លឹងមើលទៅលើសម្លៀកបំពាក់ដ៏កខ្វក់ និងប្រឡាក់ដោយកំទេចបន្លែរបស់អ្នកហើយក៏ដឹងខ្លួនថាខ្លួនឯងកខ្វក់ (និងធុំក្លិនអាក្រក់) ខ្លាំងណាស់។ មានជាប់សម្បកដំឡូងនៅលើសក់របស់អ្នកផង ហើយអ្នកក៏យកម្រាមដៃរបស់ខ្លួនទៅច្បូតចេញ។



ឥឡូវ អ្នកដើរកាត់ហ្វូងមនុស្សម្នាជាច្រើន ដែលកំពុងរង់ចាំនៅឯចំណតរថយន្តក្រុង។ អ្នកឈរតម្រង់ជួរនៅខាងក្រោយគេ ហើយខំធ្វើជាព្រងើយនឹងក្រសែភ្នែករបស់គេដែលមើលមកថាអ្នកថាជាមនុស្សចម្លែក។

នៅពេលរថយន្តក្រុងមកដល់អ្នកខំទំនាក់ទំនងទៅកាន់អ្នកបើកបរ ដោយខំប្រាប់ថា អ្នកត្រូវការរថយន្តក្រុងនៅក្រៅក្រុង។ គាត់បានសួរសំណួរមួយចំនួនដែលអ្នកមិនយល់ អ្នកបើកបរស្ទើរតែដេញអ្នកចុះពីលើរថយន្តទៅហើយ។ នៅពេលនោះអ្នកបង្ហាញប្រាក់ទៅគាត់ ហើយគាត់ក៏បន្ទន់ឥរិយាបទ។ គាត់យកប្រាក់ពីក្នុងដៃអ្នក ហើយឱ្យលុយអាប់ខ្លះទៅអ្នក។

នៅពេលអ្នកដើរទៅតាមច្រករបាររថយន្តក្រុង អ្នកមានអារម្មណ៍ថាពុំមានអ្នកណាម្នាក់ចង់ឱ្យអ្នកទៅអង្គុយជិតពួកគេឡើយ។

◈◈◈

បន្ទាប់ពីបានបើករថយន្តពេញទាំងទីក្រុងហើយនោះ ទីបំផុតអ្នកបើកបរក៏ដាក់អ្នកនៅចំណតធំនៃរថយន្តក្រុង។

នៅខាងក្នុងអ្នកឃើញក្ដាអេឡិចត្រូនិចដ៏ធំមួយសរសេរថា មានរថយន្តក្រុងទៅព្រំដែនប្រទេសរបស់អ្នក។ អ្នកក៏ចូលទៅបញ្ជរលក់សំបុត្រ ហើយសួរតម្លៃសំបុត្ររថយន្ត។ ដំបូង អ្នកមិនយល់នូវអ្វីដែលបុរសម្នាក់នៅខាងក្រោយបញ្ជរនោះកំពុងនិយាយទេ បន្ទាប់មកគាត់ក៏សរសេរតួលេខថ្លៃសំបុត្រនៅលើក្រដាសសំណល់មួយសន្លឹក។ គួរឱ្យរន្ធត់ចិត្តណាស់ គឺអ្នកខ្វះប្រាក់ជាច្រើនសម្រាប់ទិញសំបុត្រនោះ។

អ្នកក៏មិនដឹងថាត្រូវធ្វើដូចម្ដេចដែរ។ អ្នកទៅបន្ទប់ទឹក ហើយព្យាយាមសម្អាតខ្លួនឱ្យស្អាតបន្តិច។ បន្ទាប់មក អ្នកក៏ទៅអង្គុយលើបង់ ហើយរាប់ប្រាក់របស់ខ្លួនម្ដងទៀត។ អ្នកឃ្លានណាស់ តែអ្នកមិនចង់ចំណាយប្រាក់នោះទេ។ នៅទីបំផុតអ្នកក៏ទិញបាយខ្លះ ព្រោះវាថោកជាងគេបំផុតហើយនៅទីនោះ។

អ្នកក៏រងចាំនៅម៉ុំៗចំណតរថយន្តក្រុងនោះពេញមួយព្រឹក មើលរថយន្តក្រុងទៅមក។ រំពេចនោះ អ្នកមានការភ្ញាក់ផ្អើល ព្រោះបានឮមនុស្សខ្លះនិយាយភាសារបស់អ្នក។ អ្នកសម្លឹងមើលទៅគាត់មួយស្របក់ហើយក៏គិតចង់ទៅនិយាយជាមួយពួកគាត់ ប៉ុន្តែអ្នកមិនដឹងថា ត្រូវនិយាយអ្វីនោះទេ ហេតុនេះអ្នកចេះតែសម្លឹងមើលពួកគេជានិច្ច។

បន្តិចក្រោយមក អ្នកចាប់អារម្មណ៍ឃើញថា មនុស្សទាំងនេះដែលមកពីប្រទេសរបស់អ្នក កំពុងសំដៅទៅរករថយន្តក្រុងមួយគ្រឿង។ អ្នកក៏ដើរតាមពួកគេហើយឃើញស្លាកដាក់នៅខាងមុខរថយន្តក្រុងនោះ សរសេរថាទៅព្រំដែននៃប្រទេសរបស់អ្នក។

អាក្រក់ណាស់ ចង់ឡើងលើរថយន្តនេះជាមួយពួកគាត់ ប៉ុន្តែមានបុរសម្នាក់ចាំពិនិត្យនៅមាត់ទ្វារ។

អ្នកក៏រឹតតែមិនដឹងធ្វើម៉េចទេ ហើយមនុស្សកាន់តែច្រើនទៅៗបានឡើងជិះរថយន្ត ហើយនៅទីបំផុត អ្នកក៏សម្រេចចិត្តធ្វើអ្វីមួយ។ អ្នកតាំងចិត្តក្លាហានហើយដើរសំដៅទៅគ្រួសារមួយដែលកំពុងរៀបចំឡើងជិះរថយន្ត។ ដំបូង អ្នកព្យាយាមពន្យល់នូវអ្វីដែលបានកើតឡើងចំពោះអ្នក ប៉ុន្តែឃើញថា ភ្លាមនោះពួកគេមិនចាប់អារម្មណ៍ឡើយ ហើយបែបនេះបានជំរុញឱ្យពួកគេប្រញាប់ឡើងរថយន្តកាន់តែខ្លាំង។ ហេតុនេះ អ្នកក៏សុំខ្ចីប្រាក់ពួកគាត់ខ្លះ ហើយសន្យាសងប្រាក់វិញទាំងអស់យ៉ាងឆាប់បំផុត ពេលត្រឡប់មកប្រទេសខ្លួនវិញ។ ប៉ុន្តែនៅតែពុំមានអ្នកចាប់អារម្មណ៍ទៀត។ ក្មេងៗសម្លឹងមើលមកអ្នកនៅពេលឪពុកម្ដាយពួកគេរុញឱ្យឡើងរថយន្ត។

អ្នកក៏ព្យាយាមទៅរកប្ដីប្រពន្ធមួយគូទៀត តែចម្លើយនៅតែដដែល។

ឥឡូវនេះ រថយន្តក្រុងជិតពេញហើយ ហើយអស់មនុស្សដែលអ្នកត្រូវទៅរកទៀតហើយ។ អ្នកឃើញបុរសម្នាក់ប្រញាប់ប្រញាល់ឆ្ពោះទៅរថយន្តក្រុង។ នេះជាឱកាសចុងក្រោយហើយសម្រាប់អ្នក។

អ្នករត់ទៅក្បែរគាត់ ហើយសុំឱ្យគាត់ជួយ ប៉ុន្តែសូម្បីតែមើលអ្នកក៏មិនមើលផង ។ គាត់គិតតែរឿងឡើងជិះរថយន្តក្រុងប៉ុណ្ណោះ។

"សូមមេត្តាផងចុះ" អ្នកក៏យំ ដោយមិនបានតាំងចិត្ត ហើយចាប់ដៃអាវរបស់គាត់។ បុរសនោះមានប្រតិកម្មដោយកំរោលចំពោះរឿងនេះ ដោយរលាក់ដៃរបស់អ្នកចេញ ហើយស្រែកខ្លាំងៗ។ រំពេចនោះ អ្នកក៏ចេញ ប៉ុន្តែការធ្វើឱ្យភ្ញាក់ផ្អើលនេះបានទាញអារម្មណ៍ប៉ូលីសពីរនាក់ ដែលកំពុងល្បាតនៅក្បែរនោះ។

អ្នកព្យាយាមដើរចេញឱ្យឆ្ងាយ ប៉ុន្តែមុនពេលអ្នកដឹងខ្លួននោះ ប៉ូលីសបានមកជិតអ្នកទៅហើយ ហើយប៉ូលីសម្នាក់បានមកកាន់ដៃរបស់អ្នក។ ពួកគាត់ក៏ចាប់ផ្តើមសួរសំណួរមួយចំនួន មានតែពាក្យមួយម៉ាត់គត់ ដែលអ្នកស្តាប់យល់នោះគឺ លិខិតឆ្លងដែន។ អ្នករកមើលក្នុងសាក់កាដូររបស់អ្នក ដើម្បីរកលិខិតឆ្លងដែនរបស់ខ្លួន ហើយបានហុចទៅឱ្យប៉ូលីស។ បន្ទាប់មក អ្នកសម្លឹងមើលនៅពេលប៉ូលីសពិនិត្យពិច័យទៅលើលិខិតឆ្លងដែនរបស់អ្នក ថែមទាំងលើកផ្ទៀងមើលជិតភ្លើងទៀតផង។ ចំពោះលិខិតឆ្លងដែននោះ មិនបានធ្វើឱ្យប៉ូលីសសប្បាយចិត្តឡើយ។

អ្នកបានសួរប៉ូលីសថា តើមានរឿងអ្វីកើតឡើង ហើយប៉ូលីសម្នាក់បានចង្អុលទៅលិខិតឆ្លងដែន ហើយគ្រវីក្បាលរបស់ខ្លួន។ នៅពេលប៉ូលីសឃើញអ្នកមានការងឿងឆ្ងល់បែបនេះ គាត់ក៏ធ្វើឱ្យអ្នកភ្ញាក់ផ្អើល ដោយនិយាយពាក្យមួយម៉ាត់ជាភាសារបស់អ្នក។

គាត់និយាយថា "ក្លែងក្លាយ"។

អ្នកសម្លឹងមើលទៅប៉ូលីសដោយក្តីរន្ធត់។ អ្នកព្យាយាមនិយាយ ប៉ុន្តែអ្នកមិនអាចទេ។ អ្នកក៏ចាប់ផ្តើមតវ៉ា។ អ្នកប្រាប់ប៉ូលីសថា "មិនអាចទៅរួចទេ! ប្រាកដជាច្រឡំហើយ! ស្តាប់ខ្ញុំនិយាយសិន!។

ប៉ុន្តែប៉ូលីសមិនព្រមស្តាប់ឡើយ។ គាត់និយាយជាមួយមនុស្សម្នាក់តាមវិទ្យុរបស់គាត់។

◈◈◈

នៅថ្ងៃបន្ទាប់ អ្នកត្រូវឈរបង្ហាញខ្លួននៅចំពោះមុខចៅក្រមម្នាក់។ ចៅក្រម

សួរសំណួរមួយចំនួន ដែលមានស្ត្រីម្នាក់អង្គុយនៅតុមួយកំពុងបកប្រែ។ សំណួរទី១ចៅក្រមបានសួរថា តើអ្នកចូលមកប្រទេសនេះដោយរបៀបណា? អ្នកបានប្រាប់គាត់អំពីទូក និងបានបន្ថែមថា អ្នកគិតថានោះគឺស្របច្បាប់ ព្រោះអ្នកមានលិខិតឆ្លងដែន។ បន្ទាប់មកចៅក្រមបានសួររកទីកន្លែងដែលអ្នកទទួលបានលិខិតឆ្លងដែននេះ។ នៅពេលអ្នកឆ្លើយថាបានមកពីដេវីខ្លះនាំគ្នាសើចខ្សឹបខ្សួលនៅពេញសាលជំនុំជម្រះ។



ក្រោយពេលសួរចប់ពីរបីសំណួរបន្ថែមទៀត តុលាការបានជម្រាបអ្នកថា អ្នកត្រូវមានទោសចូលមកប្រទេសនោះដោយខុសច្បាប់ ដោយប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ។ គេប្រាប់អ្នកថា អ្នកអាចបង់ប្រាក់ពិន័យ ប៉ុន្តែទឹកប្រាក់នេះមានតម្លៃហួសពីលទ្ធភាពរបស់អ្នក។ នៅពេលចៅក្រមបានឮរឿងនេះ គាត់ក៏និយាយអ្វីផ្សេង បន្ទាប់មកក៏គោះញញួរឈើរបស់គាត់។

អ្នកមិនយល់ទេ អ្នកក៏សម្លឹងមើលទៅអ្នកបកប្រែដើម្បីសុំឱ្យគាត់ជួយ។

នាងនិយាយថា “ពីរខែ” ។ អ្នកនៅតែមិនយល់

នាងនិយាយថា “ត្រូវជាប់គុកពីរខែ”។

◈◈◈

អ្នកត្រូវគេយកទៅដាក់ក្នុងមន្ទីរឃុំឃាំងជាមួយស្ត្រី២០នាក់ទៀត។ បន្ទប់ឃុំឃាំងនោះតូចណាស់ ហើយមិនស្រួលឡើយ មានបន្ទប់ទឹកតែមួយនៅកាច់ជ្រុងដែលគ្រប់គ្នាអាចមើលឃើញច្បាស់។ គេឱ្យអ្នកចេញក្រៅតែមួយម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ដើម្បីហាត់ប្រាណ នៅក្នុងទីធ្លាចាក់បេតុងដ៏តូចមួយ។ ពេលដែល

នៅសល់ អ្នកមានតែត្រូវអង្គុយនៅក្នុងទ្រុងនេះ ស្តាប់ស្ត្រីទាំងឡាយនិយាយភាសាដែលខ្លួនស្តាប់មិនយល់ប៉ុណ្ណោះ។

នៅពេលថ្ងៃអាកាសធាតុក្តៅមិនសូវមានខ្យល់ដកដង្ហើម ប៉ុន្តែនៅពេលយប់សីតុណ្ហភាពធ្លាក់ចុះ ហើយសម្ភារសម្រាប់ជួយឱ្យរាងកាយមានភាពកក់ក្តៅ គឺមានតែភួយមួយគគ្រាតធុំក្លិនញើស និងធ្វើឱ្យអ្នករមាស់ប៉ុណ្ណោះ។

អ្នកក៏ដឹងឆាប់រហ័សថា តើស្ត្រីមួយណារួសរាយ និងមួយណាមិនគួរសេពគប់ជាមួយ។ ស្ត្រីខ្លះជាប់ឃុំឃាំងនៅទីនេះអស់ជាច្រើនឆ្នាំ ខ្លះទៀតហាក់ដូចជាវង្វេងស្មារតី។ ប្រហែលជា នេះគឺជាវិធីតែមួយគត់ដែលពួកគាត់បានធ្វើដើម្បីរស់នៅទីនោះប៉ុណ្ណោះ។ អ្នកមិនដឹងថា ខ្លួនអាចទៅជាឆ្កួតដូចគាត់ទាំងនោះឬអត់នោះទេ។

ចំពោះអាហារវិញគួរឱ្យខ្ពើម ធ្វើឱ្យអ្នកមិនអាចហូបបាន។ ពីរបីថ្ងៃដំបូង អ្នកមិនហូបអីទេ ហើយអ្នកមានអារម្មណ៍ថា ខ្លួនកាន់តែខ្សោយទៅៗ។ សូម្បីដើរហាត់ប្រាណមួយម៉ោងនៅក្នុងទីធ្លានោះក៏ធ្វើឱ្យអ្នកប្រឹងយ៉ាងខ្លាំងដែរ។ ស្ត្រីចិត្តល្អជាងគេម្នាក់ក្នុងចំណោមនោះបានចាប់អារម្មណ៍លើស្ថានភាពរបស់អ្នក។គាត់បានជំរុញអ្នកឱ្យខំបរិភោគអាហារ។ អ្នកចង់ក្អួត នៅពេលសាកហូបបបរាវដូចទឹក (អ្នកមិនដឹងច្បាស់ថានោះជាស្អីផង) ប៉ុន្តែប៉ុន្មានថ្ងៃកន្លងផុតទៅ អ្នកក៏អាចហូបបាន។

ពេលវេលាមួយថ្ងៃកន្លងទៅមួយថ្ងៃ អ្នកគិតដល់ផ្ទះជានិច្ច ងឿងឆ្ងល់ណាស់ថាតើសូរិយាមានផែនការអ្វី។ អ្នកស្តាយព្រោះគួរតែឱ្យគេទៅនិយាយជាមួយម្តាយអ្នក។អ្នកមានអារម្មណ៍ថា គ្រប់យ៉ាងនៅឆ្ងាយពីគ្នាណាស់ ហើយអ្នកក៏ចាប់គិតថា មិនដឹងថាខ្លួននឹងអាចជួបអ្នកទាំងអស់នោះទៀតឬយ៉ាងណាទេ។

រស់នៅទីនោះបានមួយខែ អ្នកក៏ធ្លាក់ខ្លួនឈឺ។ ប្រាកដជាជំងឺគ្រុនក្តៅហើយ។ អ្នកគ្រុន ហើយខ្សោយទៅៗអស់កម្លាំងរលីងពីខ្លួន។ តែប៉ុន្មានថ្ងៃសោះសូម្បីក្រោកឈរឡើងក៏មិនអាចក្រោកបានដែរ។ អ្នកដេករងារញ័រនៅក្នុងភួយដេកមិនស្ងៀម។ ជួនកាល អ្នកមិនអាចដឹងថាតើសុបិនអាក្រក់របស់អ្នក និងជីវិតនៅក្នុងបន្ទប់ឃុំឃាំងមានភាពខុសគ្នាយ៉ាងណានោះទេ។ អ្នកក៏ចាប់ផ្តើមគិតច្រើនអំពីការស្លាប់។ អ្នកជឿថា ជីវិតដ៏ខ្លីរបស់អ្នកនេះនឹងត្រូវបញ្ចប់នៅទីនេះហើយ។

ជីវិតរបស់អ្នកស្ថិតនៅក្នុងការគ្រប់គ្រងរបស់ស្ត្រីចិត្តល្អរូបនោះដែលនៅក្នុងបន្ទប់ឃុំឃាំងដែលចេះតែខំឱ្យអ្នកបរិភោគ និងផឹក សូម្បីនៅពេលដែលអ្នកស្ទើរតែមិនអាចទ្រាំបានក៏ដោយ។ប៉ុន្មានថ្ងៃកន្លងផុតអ្នកក៏ចាប់មានកម្លាំងនៅក្នុងខ្លួនវិញ។

ថ្ងៃមួយ មានស្ត្រីម្នាក់លេចមុខនៅមាត់ទ្វារនៃបន្ទប់ឃុំឃាំង ហើយសួររកឈ្មោះរបស់អ្នក។ អ្នកដើរតាមស្ត្រីនោះទៅបន្ទប់សម្ភាសន៍តូចមួយ ហើយភ្ញាក់ផ្អើលសប្បាយចិត្តណាស់នៅពេលគាត់និយាយភាសារបស់អ្នក។ ស្ត្រីនោះប្រាប់អ្នកថា គាត់មកពីស្ថានទូតនៃប្រទេសរបស់អ្នក ហើយថាពួកគេបានតាមរកអ្នកចាប់តាំងពីគ្រួសារអ្នកបានរាយការណ៍ពីការបាត់ខ្លួនរបស់អ្នក ប្រាប់អាជ្ញាធរ។ នៅពេលនោះនាងបានសួរសំណួរជាច្រើនទាក់ទងទៅនឹងរឿងរ៉ាវរបស់អ្នក។នៅពេលគាត់បានកត់ត្រាចម្លើយគ្រប់យ៉ាងហើយនោះ ស្ត្រីរូបនោះក៏រៀបចំកាបូបរបស់ខ្លួនដើម្បីចេញទៅវិញ។

អ្នកសុំឱ្យគាត់ជួយ ដោយនិយាយថា "សូមជួយឱ្យខ្ញុំបានត្រឡប់ទៅផ្ទះវិញផងបានទេ?

គាត់ឆ្លើយបញ្ជាក់ថា "យើងនឹងប្រឹងប្រែងឱ្យអស់ពីលទ្ធភាព"។

ពេលត្រឡប់មកបន្ទប់ឃុំឃាំងវិញ អ្នកអាចគ្រាន់តែគិតដល់ក្តីបារម្ភពីគ្រួសាររបស់អ្នកដែលប្រាកដជាកំពុងខ្វល់ខ្វាយពីអ្នក។ អ្នកបួងសួងសុំឱ្យបានជួបជុំគ្រួសារវិញក្នុងពេលឆាប់ៗខាងមុខនេះ។

មួយសប្តាហ៍ក្រោយមក ពេលអ្នកកំពុងអង្គុយនៅក្នុងបន្ទប់ឃុំឃាំង មានគេមកយកកែងដៃមករុញអ្នក។ អ្នកងើយមុខមើលទៅ ក៏ឃើញស្ត្រីស្ថានទូតនោះឈរនៅមាត់ទ្វារបន្ទប់ឃុំឃាំងទៀត។ ក្នុងរយៈពេលមួយដ៏តានតឹង អ្នកខ្លាចមានដំណឹងអាក្រក់ តែបន្ទាប់មក ស្ត្រីនោះក៏ញញឹម។

គាត់និយាយថា "យករបស់របរឯងមក ឯងបានត្រឡប់ទៅផ្ទះវិញហើយ"។

នៅពេលអ្នកចាកចេញពីបន្ទប់ឃុំឃាំង អ្នកបានងាកមើលក្រោយសម្លឹងទៅស្ត្រីចិត្តល្អដែលបានជួយដល់រូបនាងជាច្រើន។អ្នកហាមាត់និយាយថា "អរគុណ" ហើយទោះបីជាអ្នកនិយាយភាសាខុសគ្នាក៏ដោយ អ្នកដឹងច្បាស់ថា គាត់ប្រាកដជាយល់។ គាត់ងក់ក្បាលដាក់អ្នក ហើយក៏ញញឹម។

◈◈◈

អ្នកត្រូវជិះរថយន្តប៉ូលីសទៅកាន់ព្រំដែន ជាមួយនឹងស្ត្រីមួយចំនួនទៀត។

នៅព្រំដែន អ្នកទាំងអស់គ្នាត្រូវរងចាំនៅក្នុងបន្ទប់តូចមួយបិទជិត រីឯមន្ត្រីអន្តោប្រវេសន៍ជាអ្នករត់ការឯកសាររបស់អ្នក។ បន្ទាប់មក គេហៅឈ្មោះម្តងមួយៗ ហើយឱ្យឆ្លងដែនទៅស្រុកវិញ។

នៅម្ខាងទៀតនោះ គេបានប្រាប់អ្នកថា អ្នកនឹងត្រូវធ្វើដំណើរទៅផ្ទះវិញដោយ

ខ្លួនឯង។ អរគុណព្រះជាម្ចាស់ ភូមិរបស់នាងនៅមិនឆ្ងាយប៉ុន្មានពីព្រំដែនឡើយ ប៉ុន្តែដូចគ្នាទាំងអស់ គឺអ្នកត្រូវចំណាយប្រាក់របស់ខ្លួនអស់រលីងដើម្បីជិះរថយន្តក្រុង។

នៅពេលអ្នករុញអីវ៉ាន់នៅក្នុងរថយន្តក្រុង អ្នកនឹកឃើញដល់រឿងពិតគួរឱ្យសោកសៅអំពីអ្វីដែលកើតឡើងចំពោះអ្នក។ អ្នកបានចេញពីផ្ទះជិតបួនខែ ហើយនៅពេលនេះត្រឡប់មកផ្ទះវិញមានប្រាក់តិចជាងមុនពេលចាកចេញពីផ្ទះ។

◈◈◈

អ្នកពុំមានឱកាសទូរសព្ទទៅអ្នកណាម្នាក់ឡើយ ហេតុនេះពុំមានជួបអ្នកណាម្នាក់មកជួបអ្នកនៅចំណតរថយន្តក្រុងក្នុងភូមិឡើយ។ ពេលដើរទៅផ្ទះអ្នកសង្ឃឹម និងបន់ស្រន់សុំកុំឱ្យជួបអ្នកស្គាល់អី។ ចំណុចចុងក្រោយបំផុតដែលគាត់ចង់ធ្វើនោះគឺ ត្រូវឆ្លើយសំណួរជាច្រើន។

អ្នកបានទៅដល់ផ្ទះ ហើយឈប់បន្តិចនៅច្រកចូលផ្ទះ។ ផ្ទះរបស់អ្នកដូចជាស្ងាត់ និងហាក់ដូចជាត្រូវគេបោះបង់ចោល។ អ្នកដឹងថា ស៊ីតាប្រហែលជាទៅរៀនបាត់ហើយ។ ប៉ុន្តែអ្នករំពឹងខ្លះថានឹងឃើញឪពុកគាត់កំពុងអង្គុយនៅខាងក្រៅផ្ទះជាមួយនឹងសំណាញ់របស់គាត់។

បន្ទាប់មក នៅពេលអ្នកហៀបនឹងចុះទៅតាមផ្លូវលំ ទ្វារមុខផ្ទះក៏បើក ហើយម្ដាយអ្នកក៏លើកកាធុនគក់ខោអាវដើរចេញមក។ គាត់ឃើញអ្នក ហើយក៏ឈប់។

ម្ដាយអ្នកស្រែកថា "សួរស្ដី! អ្នកមានការអី?"

អ្នកខំទប់ទឹកភ្នែក ម្ដាយអ្នកចំណាំអ្នកមិនបានឡើយ។

អ្នកហៅគាត់ដោយសម្លេងស្រួយ "ម៉ែ! គឺខ្ញុំណា!"

គាត់សម្លឹងមើលម្ដងទៀត។ បន្ទាប់មក គាត់ក៏ស្រែកយំ ហើយទុកកាធុនចោល។ អ្នករត់ទៅរកគាត់ អ្នកទាំងពីរឱបគ្នាយូរណាស់ ទឹកភ្នែកហូរចេញមកលើផ្ទៃមុខរបស់អ្នក។

គាត់និយាយថា "ម៉ែគិតថា ម៉ែបាត់បង់កូនហើយ!"

នៅក្នុងផ្ទះ គាត់អង្អែលមុខ និងសក់របស់អ្នកដោយក្ដីស្រឡាញ់។

គាត់សួរថា "មានរឿងអីកើតឡើង កូន?"

◈◈◈



ទាល់តែនៅពេលអ្នកមើលខ្លួនឯងក្នុងកញ្ចក់ ទើបអ្នកដឹងច្បាស់នូវអ្វីដែលម្ដាយអ្នកកំពុងចង់និយាយ។ អ្នកមិនដែលបានឆ្លុះកញ្ចក់ជាច្រើនខែហើយ ហើយនៅពេលនេះអ្នកស្ទើរតែមិនអាចចំណាំមនុស្សដែលតាមសម្លឹងមកអ្នកវិញបាន។ អ្នកស្គមស្រកទម្ងន់ខ្លាំងណាស់។ មុខរបស់អ្នកឡើងស្លេកស្លាំងស្ដើង ហើយសក់របស់អ្នក ដែលធ្លាប់តែស្រស់ស្អាត ឥឡូវនេះឡើងរឹង ហើយស្រអាប់។

អ្នកសួរថា "ពុកទៅណាហើយ?" ។

ម្ដាយរបស់អ្នកក៏ទម្លាក់មុខចុះ ហើយអ្នកក៏ដឹងច្បាស់ថា ជាដំណឹងមិនល្អ។

គាត់ប្រាប់កូនថា "គាត់ទៅបាត់ហើយ! គាត់ស្លាប់កាលពីខែមុន"។

អ្នកបានសួរគាត់ថា "ហេតុអីគាត់ស្លាប់?"

"គាត់បានជិះទូកទៅបង់សំណាញ់ យើងគិតថាគាត់ខំរកត្រីណាស់។ គេបានប្រទះឃើញទូកគាត់អណ្ដែត។ គ្មានតម្រុយអីអំពីគាត់ និងសំណាញ់របស់គាត់ឡើយ។

នៅពេលស៊ីតាមកដល់ផ្ទះ នាងមិនអាចលាក់ក្តីរន្ធត់របស់ខ្លួនបានទេ។

អ្នកនិយាយថា "ខ្ញុំដឹងហើយ មិនបាច់និយាយអីទេ?"

នាងក៏រត់មកឱ្យអ្នកឱប ទឹកភ្នែកក៏ឈ្លួលចេញមកម្តងទៀត។

បន្ទាប់មកម្តាយអ្នកចូលមកក្នុងបន្ទប់ដែលអ្នកកំពុងនៅជាមួយស៊ីតា។គាត់កំពុងកាន់ទូរសព្ទរបស់គាត់។ គាត់និយាយថា "ម៉ែនឹងទូរសព្ទទៅសូរិយា"។

អ្នកតបថា "ម៉ែ! កុំអី! កុំអាលទូរសព្ទនៅពេលនេះអីម៉ែ។ ខ្ញុំចង់ដេក។"

តាមពិត អ្នកមិនចង់ឱ្យសូរិយាឃើញអ្នកក្នុងសភាពបែបនេះទេ។

យូរបន្តិច អ្នកក៏ភ្ញាក់ពីដេកភ្លាម ហើយមានអារម្មណ៍ថា មានគេកំពុងអង្គុយនៅលើគ្រែ។ អ្នកគិតភ្លាមថា គឺជាចៅហ្វាយប្រុស។

អ្នកនិយាយដោយដង្ហក់ថា "អត់ទេ! ចេញទៅ!"

បន្ទាប់មក អ្នកក៏ឃើញថាជាសូរិយាទេ។ អ្នកមានអារម្មណ៍អាម៉ាស់ ហើយមិនចូលចិត្តការសម្លឹងមើលរបស់សូរិយាមកលើរូបអ្នកឡើយហើយអ្នកក៏ងាកមុខចេញ។

អ្នកស្រែកឡើងថា "ទុកឱ្យខ្ញុំនៅម្នាក់ឯងបានទេ!"

សូរិយាចប់និយាយ តែអ្នកក៏កាត់ភ្លាម និងនិយាយដោយបង្ខំថា "ខ្ញុំសូមអង្វរ"។

"បាន" សូរិយាឆ្លើយតប។ ស្តាប់ទៅ សូរិយាដូចជារន្ធត់ចិត្ត ហើយក្រៀមក្រំ។

អ្នកឮនាងចេញពីបន្ទប់ អ្នកយកខ្នើយគ្របមុខរបស់ខ្លួន ហើយយំ។ អ្នកពុំដែលស្រមៃថាវិលមកផ្ទះវិញក្នុងស្ថានភាពបែបនេះទេ។

បន្ទាប់មក អ្នកឮសម្លេងនៅជាប់ទ្វារ ។ អ្នកងាកមើលក៏ឃើញថាជាសូរិយា។ នាងកំពុងឈរនៅទីនោះដោយទឹកមុខម៉ឺងម៉ាត់ គ្រវីក្បាលរបស់ខ្លួន។

នាងនិយាយថា "ទេ! ខ្ញុំសូមទោស! ខ្ញុំនឹងមិនទៅណាទេ។ ខ្ញុំបានរងចាំឯងបួនខែហើយ។ ខ្ញុំគិតថាអ្នកបានស្លាប់បាត់ហើយ។

នាងក៏ចូលមកវិញ ហើយទៅអង្គុយលើកៅអី។

ឯងមិនបាច់និយាយជាមួយខ្ញុំទេ ហើយក៏មិនបាច់ងាកមើលខ្ញុំដែរ។ ប៉ុន្តែឯងត្រូវដឹង ខ្ញុំនៅទីនេះ ខ្ញុំមិនទៅណាទេ។ ខ្ញុំមិនខ្វល់ទោះឯងមិននិយាយរកខ្ញុំបីខែ

ហើយក៏ដោយ ខ្ញុំក៏មិនខ្វល់ថាឯងនឹងប្រាប់រឿងដែលបានកើតឡើងចំពោះ ឯងដល់ខ្ញុំឬក៏អត់ទេ។ គឺខ្ញុំមិនខ្វល់អ្វីទាំងអស់។ ប៉ុន្តែ ខ្ញុំនៅជាមួយឯង ព្រោះមិត្តល្អត្រូវធ្វើបែបនេះឯង។

ខ្មើយនៅគ្រប់លើមុខរបស់អ្នក អ្នកលាតដៃចេញមកទៅរកនាង ហើយនាងក៏ចាប់ដៃអ្នក។

◈◈◈

បន្ទប់ជួបប្រជុំនោះ ក៏មានមនុស្សចូលពេញ។ អ្នកកំពុងឈរនៅខាងក្រោយ ហើយអ្នកច្បាស់ជាឆ្ងួតមិនខាន។ ប្រាំមួយខែកន្លងទៅចាប់តាំងពីអ្នកបានត្រឡប់មកផ្ទះវិញ អ្នកមិនដែលឃើញមនុស្សច្រើនជុំគ្នាយ៉ាងនេះទេ។ មិនអីទេ ទាំងអស់គ្នានៅក្នុងបន្ទប់តែមួយ! អ្នកមិនជឿថា ខ្លួនបានអនុញ្ញាតឱ្យសូរិយាបញ្ចុះបញ្ចូលអ្នកបានយ៉ាងនេះសោះ។

ឥឡូវ ពេលគ្រប់គ្នាអង្គុយចុះ សូរិយាបានឈានជើងឡើងទៅកាន់ក្បាលមេក្រូនៅខាងមុខ។

"មួយឆ្នាំមុន មិត្តល្អបំផុតម្នាក់របស់ខ្ញុំបានធ្វើអ្វីម៉្យាងដើម្បីជួយដល់គ្រួសារនាង។ គ្រួសារនាងបានជួបប្រទះនឹងការលំបាកជាច្រើន ហើយនាងបានសម្រេចចិត្តថា ត្រូវតែជួយគ្រួសារទោះត្រូវយ៉ាងម៉េចក៏ដោយ។ នាងមានសេចក្តីក្លាហានណាស់។អ្វីៗមិនដូចដែលបានរំពឹងទុកឡើយ។ ទីបំផុតនាងបានបានដើរទៅដល់ផ្លូវមួយ ដែលពុំមានអ្នកណាធ្លាប់ជួបប្រទះ។ ឥឡូវនេះ មិត្តដ៏ស្រស់ស្អាតរបស់ខ្ញុំនៅទីនោះ បានយល់ព្រម (ដោយមានការបញ្ចុះបញ្ចូលពីខ្ញុំបន្តិចផងនោះ) ធ្វើអ្វីម៉្យាង ដែលខ្ញុំគិតថា ត្រូវការសេចក្តីក្លាហានច្រើន។ នាងនឹងប្រាប់អ្នកទាំងអស់គ្នា អំពីបទពិសោធន៍របស់នាង។ ហើយនាងធ្វើបែបនេះគឺរំពឹងថា នឹងអាចការពារអ្នកដទៃទៀតកុំឱ្យជួបប្រទះការឈឺចាប់ដូចនាង។ សូមស្វាគមន៍មិត្តរបស់ខ្ញុំ! សូមអញ្ជើញ!"

## ចប់

# ជំហានដំបូង



តើធនធានតូចមួយជួយឲ្យអ្នកចេះគិតហ៊ុំ? សម្លេងរបស់សូរិយាបានជំរុញឱ្យអ្នកភ្លេចនូវគំនិតរវើរវាយរបស់អ្នកនៅក្នុងពេលនេះ។ នាងបានដើរចូលមកតាមក្រោយរបារដាក់ទឹកដោះគោនិងទឹកឃ្មុំ មិនឱ្យអ្នកចាប់អារម្មណ៍ ហើយបានឃើញអ្នកកំពុងសម្លឹងមើលគ្មានគោលដៅ។

អ្នកត្រឡប់ទៅសម្អាតបញ្ជរវិញ។ ចុងក្រោយនេះគឺដល់វេនអ្នកហើយ ចំណែកសូរិយានៅទីនេះ ដើម្បីសម្របសម្រួល។

នាងសួរអ្នកថា "ឯងមិនអីទេមែនទេ ?"

អ្នកតបថា "ទេ មិនអីទេ! ល្ងាចយប់មិញនេះ គឺជាវេលាមួយមិនល្អទាល់តែសោះសម្រាប់ខ្ញុំ"។

អ្នកប្រាប់នាងទាំងអស់អំពីបញ្ហាលំបាកដែលខ្លួនបានជួបប្រទះ រវាងឪពុកអ្នក និងលោក ស្នេកគី និងប្រាប់ពីលក្ខណៈដែលអ្នកបានចាយវាយប្រាក់ទាំងអស់ដែលខ្លួនបានសន្សំទុក។

អ្នកនិយាយថា "យើងមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទេ។ យើងជិតនឹងបានទូរសព្ទទៅដេវីទៅហើយកាលពីព្រឹកមិញនេះ។"

សូរិយានិយាយថា "នែ! ក្រែងឯងកំពុងរកប្រាក់ជួយដល់គ្រួសារមែនទេ ?"

អ្នកនិយាយថា "យើងដឹង..............ប៉ុន្តែយើងត្រូវរកប្រាក់ឱ្យច្រើនទៀត។ កុំយល់ខុសចំពោះយើង។ យើងចូលចិត្តធ្វើការនៅទីនេះ ប៉ុន្តែ................"

សូរិយាងក់ក្បាល ដូចជានាងបានដឹងនូវអ្វីដែលអ្នកកំពុងនិយាយដូច្នេះដែរ។ សូរិយានិយាយថា "យើងដឹង យើងពិតជាមិនអាចក្លាយជាសេដ្ឋីក្នុងពេលដ៏ឆាប់

នោះទេ មែនទេ?”

អ្នកទាំងពីរសើច ហើយភ័យតិចៗចំពោះរឿងនេះ តែបន្ទាប់មក អ្នកសម្លឹងមើលមិត្តរបស់អ្នកដោយលក្ខណៈកាន់តែម៉ឺងម៉ាត់។

“យើងត្រូវធ្វើអ្វីម្យ៉ាង។ យើងគ្មានជម្រើសទេ។”

អ្នកអាចឃើញថា សូរិយាកំពុងគិតអំពីរឿងនេះ នៅពេលគាត់ពាក់អៀមពីមុខ។ នៅទីបំផុត នាងក៏បែរមុខមករកអ្នក។

នាងនិយាយថា“បានមិនអីទេ!ឯងនិយាយចុះថាឯងត្រូវធ្វើអ្វីម្យ៉ាង ហេតុនេះ តើអ្នកមានផែនការណាមួយឬទេ?

អ្នកតបថា “ពិតមែន! យើងមានគម្រោងរកប្រាក់មួយចំនួន ដើម្បីឱ្យយើងអាចបានលិខិតឆ្លងដែន និងរកការងារបានធ្វើ។ ប៉ុន្តែយើងបានត្រឹមតែចាយប្រាក់របស់ខ្លួនអស់ប៉ុណ្ណោះ។

សូរិយាងក់ក្បាល “ត្រឹមត្រូវ! មែន! ឯងនឹងរកប្រាក់នោះបានមកវិញ។ នៅពេលដំណាលគ្នាក្នុងគ្រាកន្លងទៅនោះ ប្រហែលជាអ្នកត្រូវស្វែងរកព័ត៌មានមួយចំនួននិងរកឱ្យឃើញថា តើអ្នកត្រូវធ្វើអ្វីពិតប្រាកដ។ យ៉ាងហោចណាស់នៅពេលនោះ អ្នកនឹងដឹងថា តើអ្នកត្រូវការប្រាក់ប៉ុន្មាន និងត្រូវការសម្ភារៈណាខ្លះ ។”

តាមធម្មតា ស្តាប់ទៅសូរិយាដូចជាកំពុងមានហេតុផលល្អណាស់ ប៉ុន្តែអ្នកពុំមានតម្រុយអ្វីដើម្បីដឹងថា តើត្រូវចាប់ផ្តើមនៅកន្លែងណានោះទេ។

អ្នកនិយាយថា “អញ្ចឹង! តើឯងមានយោបល់អីទេ?”

សូរិយាញញឹម “យើងប្រហែលជាមាន ។ តើអ្នកគិតថា អ្នកកំពុងនិយាយជាមួយនរណានៅទីនេះ?”

អ្នកទ្រាំមិនញញឹមដាក់នាងមិនបាន។ អ្នកមានសំណាងណាស់ ដែលមានមិត្តម្នាក់បែបនេះ។

“ប្រហែលជារឿងទីមួយដែលត្រូវធ្វើគឺ ត្រូវមើលតាមអ៊ីនធឺណិត និងមើលថា តើមានការងារអ្វីខ្លះនៅទីនោះ។ អ្នកអាចចូលរួមនៅក្លឹបយុវជននៅថ្ងៃសៅរ៍ ប្រសិនបើអ្នកចង់ទៅ។ នៅទីនោះ មានកុំព្យូទ័រសម្រាប់ឱ្យអ្នកប្រើប្រាស់។”

អ្នកដឹងថា អាចពិបាកចេញពីផ្ទះនៅថ្ងៃសៅរ៍ ប៉ុន្តែអ្នកប្រាប់នាងថា អ្នកនឹងប្រឹងប្រែងទៅទីនោះ។

មុនពេលចាកចេញទៅ អ្នកបានឱបកាយនាងពេញក្នុងដៃ ។

នាងនិយាយថា“ជួយយើងរឿងមួយបានទេ។សូមកុំទូរសព្ទទៅដេវីអ៊ីបានទេ?”

អ្នកឆ្លើយថា “យល់ព្រម”

◈◈◈

នៅពេលអ្នកភ្ញាក់ពីគេងនៅព្រឹកថ្ងៃសៅរ៍ ម្ដាយអ្នកចេញទៅរកត្រីបាត់ទៅហើយ។ ចំណែកពុករបស់អ្នកនៅសម្រាន្តនៅឡើយព្រោះតែមិនទាន់អស់ជាតិស្រវឹង។អ្នកផ្ញើសារទៅសូរិយាហើយរៀបចំខ្លួនដើម្បីទៅជួបគ្នានៅក្លឹបយុវជន។អ្នកមានអារម្មណ៍ថាអៀនៗពេលចូលទៅក្នុងអាគារក្លឹបយុវជនព្រោះអ្នកមិនស្គាល់អ្នកណាម្នាក់ឡើយ បើទោះជាអ្នកធ្លាប់បានទៅទីនោះពីរបីដងរួចមកហើយក្ដី។ ចំណែកសូរិយាវិញស្គាល់អ្នកគ្រប់គ្នាដែលនៅទីនោះព្រោះនាងជាប្រធានក្លឹបយុវជន។

ពេលទៅដល់ទីនោះអ្នកខំរកដើរសូរិយា ហើយក៏បានឃើញនាងកំពុងតែអង្គុយជាមួយមនុស្សស្រីម្នាក់ដែលអ្នកមិនដែលស្គាល់ឡើយ។ អ្នកក៏ដើរទៅរកពួកគេហើយសូរិយាក៏ណែនាំអ្នកឱ្យម្នាក់នោះស្គាល់។

សូរិយានិយាយថា “នេះគឺជាចន្ទលីណា។ ពួកយើងកំពុងតែជជែកគ្នាពីរឿងដែលគួរឱ្យចាប់អារម្មណ៍។ ខ្ញុំគិតថាអ្នកទាំងពីរគួរតែនិយាយគ្នា។”

អ្នកនិយាយទាំងស្ទាក់ស្ទើរថា “បានតើ!”

អ្នកឆ្ងល់ថាសូរិយាបាននិយាយអ្វីខ្លះជាមួយមនុស្សស្រីម្នាក់ដែលអ្នកមិនដែលស្គាល់នោះ។

ចន្ទលីណានិយាយថា៖ សួរស្ដី! ខ្ញុំសប្បាយចិត្តណាស់ដែលបានស្គាល់ឯង។

មើលទៅចន្ទលីណាជាមនុស្សរួសរាយគួរសម។ គេប្រហែលជាមានអាយុបងអ្នកទាំងពីរមួយឆ្នាំ។ នាងនិយាយថា៖ ខ្ញុំជឿថាឯងកំពុងតែចង់ទៅធ្វើការនៅក្រៅប្រទេស មែនអត់?

អ្នកងក់ក្បាលហើយនិយាយថា “មែនហើយ!”

ចន្ទលីណានិយាយបន្តទៀតថា“ខ្ញុំដឹងរឿងខ្លះៗពីការងារនៅក្រៅស្រុកព្រោះខ្ញុំមានបងស្រីម្នាក់ដែលធ្លាប់ជួបរឿងមិនល្អនៅទីនោះ។ ខ្ញុំអាចដឹងថាអ្វីគួរធ្វើអ្វីមិនគួរធ្វើ។ ខ្ញុំយល់ថាបើឯងចង់ទៅធ្វើការនៅក្រៅប្រទេស ឯងត្រូវតែរៀបចំ

គម្រោងនិងឯកសារឱ្យបានច្បាស់លាស់។ “

អ្នកក៏បាននិយាយតបទៅវិញបែបការពារខ្លួនថា “ខ្ញុំកំពុងតែរៀបគម្រោងនិងរត់ការចាត់ចែងរឿងនេះហើយ។ ខ្ញុំជឿថាមានសុវត្ថិភាព។”

ចន្ទណាលីននិយាយថា “ល្អហើយអញ្ចឹង។ មានរឿងខ្លះដែលឯងគិតថាត្រូវប្រុងប្រយ័ត្នដើម្បីកុំឱ្យមានគ្រោះថ្នាក់ តែក៏មានរឿងខ្លះទៀតដែលឯងស្មានមិនដល់ឡើយ។”

សូរិយាក៏បានសួរថា “រឿងអ្វីខ្លះ? ប្រាប់ពួកយើងបានអត់?”



“រឿងដំបូងនោះគឺឯងមិនគួរទៅតែម្នាក់ឯងទេ។តើមានអ្នកផ្សេងទៅជាមួយឯងឬអត់? ឬ តើឯងមានស្គាល់អ្នកណានៅទីនោះឬអត់? ចុះពេលឯងទៅដល់មានអ្នកមកយកឬអត់?”

សូរិយានិយាយទាំងញញឹមថា “ចុះណារិន?”

អ្នកក៏សម្លឹងសូរិយាដោយក្រសៃភ្នែកមុតស្រួច ហើយសង្ឃឹមថានាងមិននិយាយពីណារិនទៀតឡើយ។

សូរិយានិយាយប្រាប់ចន្ទលីណាថា “អ៎! ណារិនអាចមកយកបាន។”

អ្នកស្រែកដាក់សូរិយាថា “សូរិយា!!!” “អូយខ្មាសគេណាស់លោកអើយ។”

ចន្ទលីណាញញឹមហើយសួរថា “តើអាចទុកចិត្តគេបានឬអត់?”

សូរិយានិយាយទាំងញញឹមថា “មិនច្បាស់ដែរ។”

អ្នកបានត្រឹមតែអង្គុយគ្រវីក្បាលដាក់មិត្តរបស់អ្នក។

ចន្ទណាលីនបន្តថា “ប្រសិនបើឯងមានលេខទូរសព្ទគេច្បាស់ជាមិនពិបាកទេ។ ការពារប្រសើរជាងព្យាបាល។ កាលនោះបងស្រីខ្ញុំទៅទីនោះខ្លួនឯងហើយ

គាត់មិនស្គាល់អ្នកណាម្នាក់ឡើយ។ អញ្ចឹងហើយបានជាពេលដែលមានរឿងអីកើតឡើង គាត់គ្មានអ្នកពឹងពាក់ឡើយ។”

អ្នកសួរថា “មានរឿងអីកើតឡើងចំពោះគាត់?”

ចន្ទលីណានិយាយថា “កំហុសរបស់បងស្រីខ្ញុំគឺមកពីគាត់ជឿជាក់លើក្រុមហ៊ុនពេក។ គាត់ជឿអ្វីដែលគេប្រាប់គាត់ទាំងអស់។ គាត់អត់បានស្រាវជ្រាវពីសាវតារបស់ក្រុមហ៊ុននោះជាមុនឡើយ។ បើសិនជាឯងចង់ធ្វើការនៅក្រៅប្រទេស ឯងត្រូវឆែកព័ត៌មានដែលពាក់ព័ន្ធនឹងក្រុមហ៊ុនដែលឯងចង់ទៅធ្វើការជាមុនសិន។ ពេលឆែករួចហើយឯងអាចឱ្យអាសយដ្ឋាននិងលេខទូរសព្ទរបស់ក្រុមហ៊ុននោះទៅមិត្តភក្តិនិងគ្រួសាររបស់ឯង។ កាលនោះបងស្រីខ្ញុំធ្វើការដោយអត់បានចុះកិច្ចសន្យាឬចុះទិដ្ឋាការការងារអ្វីទេ។ អញ្ចឹងហើយទើបពេលដែលលក្ខខណ្ឌការងារនោះខុសពីអ្វីដែលគេប្រាប់ បងស្រីខ្ញុំគ្មានអ្វីទៅត៌វ៉ានឹងគេទេ។ ការងារពិបាកខ្លាំងក៏ប៉ុន្តែប្រាក់ខែដែលគាត់ទទួលបានមិនសមមូលនឹងអ្វីដែលគាត់បានធ្វើឡើយ។ ពេលនោះថៅកែមិនព្រមឱ្យគាត់ឈប់ឡើយព្រោះគាត់ថាគាត់បានចំណាយលុយច្រើនណាស់លើឈ្នួញរត់ការ។ បងស្រីខ្ញុំត្រូវទ្រាំធ្វើការនៅទៅនោះរហូតដល់ពីរឆ្នាំ។ ពិតជារឿងដែលស្មានមិនដល់មែន។”

អ្នកនិយាយថា “ពុទ្ធោអើយ។”

ពេលនេះហើយទើបអ្នកដឹងថាអ្វីៗមិនមែនសុទ្ធតែងាយដូចដែលអ្នកគិតឡើយ ហើយរឿងងាយៗអស់ទាំងនោះហើយដែលអាចក្លាយទៅជារឿងស្មានមិនដល់បាន។

អ្នកបន្តសួរថា “ចុះកាលនោះគាត់ធ្វើការអីដែរ?”

ចន្ទលីណាតបថា “គឺការងារក្នុងរោងចក្រ។ បងស្រីខ្ញុំត្រូវធ្វើការជាមួយនឹងគ្រឿងម៉ាស៊ីន។ ដូច្នេះហើយគាត់ត្រូវចំណាយកម្លាំងច្រើនហើយងាយនឹងហត់ព្រោះត្រូវធ្វើការច្រើនម៉ោង។ ពេលដែលកម្មករគ្មានកម្លាំងធ្វើការ ពួកគេងាយនឹងរងគ្រោះថ្នាក់ណាស់។ តាមបទពិសោធធ្លាប់មានគ្រោះថ្នាក់កើតឡើងជាច្រើនករណីរួចមកហើយ។ អញ្ចឹងហើយបានគេឯងត្រូវតែចុះកុងត្រាការងារមុនពេលចូលធ្វើការ។”

សូរិយានិយាយថា “ពិតជាដំបូន្មានល្អមែន!!!”

អ្នកក៏បន្ថែមថា “ខ្ញុំអរគុណច្រើនហើយ។”

ចន្ទលីណានិយាយថា “មិនអីទេ! និយាយអញ្ចឹងខ្ញុំឮថាមានភ្នាក់ងារជួយរៀបចំសម្រួលការងារចំណាកស្រុក។ ភ្នាក់ងារនោះអាចជួយរៀបចំឯកសារ សុំទិដ្ឋាការការងារ រកការងារធ្វើចចារធ្វើកិច្ចសន្យា និងអ្វីគ្រប់យ៉ាងដែលពាក់ព័ន្ធនឹង

កិច្ចការងារ។ យកល្អឯងត្រូវរកកន្លែងស្នាក់ជាមុនសិន មុនពេលឯងចេញទៅ។ អ្វីដែលសំខាន់គឺឯងត្រូវតែមានលុយគ្រប់គ្រាន់សម្រាប់រត់ការរឿងទាំងអស់នេះ បូករួមទាំងថ្លៃចំនាយលើការធ្វើដំណើរ និងថ្លៃចំណាយពេលត្រលប់មកវិញ។ សំខាន់បំផុតនោះគឺឯងត្រូវតែមានលុយបម្រុងសម្រាប់ទុករត់ការពេលដែលត្រូវការចាំបាច់។"

អ្នកនិយាយ "ខ្ញុំកំពុងតែរត់ការពីរឿងនេះ។ ឥឡូវយើងកំពុងតែធ្វើយ៉ាងណាឱ្យមានអតិថិជនមកកន្លែងលក់របស់យើងឱ្យបានច្រើន។ ដល់ពេលនោះប្រហែលជាស្ថានការអាចនឹងល្អប្រសើរ។"

ក្រោយពីចន្ទលីណាចេញទៅ អ្នកនិងសូរិយាក៏ចាប់ផ្ដើមឆែកអ៊ីនធឺណិតដើម្បីរកមើលការងារ។ នៅតាមអ៊ីនធឺណិតមានការងារច្រើនណាស់ដែលបានផ្សព្វផ្សាយនៅលើគេហទំព័រភ្នាក់ងារជ្រើសរើសបុគ្គលិក។ អ្នកធ្វើតាមដំបូន្មានរបស់ចន្ទលីណាដើម្បីឆែកមើលព័ត៌មានរបស់ក្រុមហ៊ុនដែលបានប្រកាសជ្រើសរើសបុគ្គលិក។ អ្នកក៏បានរកឃើញថាមានក្រុមហ៊ុនខ្លះមានគេហទំព័រផ្ទាល់ខ្លួន ហើយខ្លះទៀតគ្មានឡើយ។ អ្នកប្រាប់ខ្លួនឯងថាអ្នកត្រូវតែស្គាល់ក្រុមហ៊ុននោះឱ្យច្បាស់សិនមុននឹងសម្រេចចិត្តទៅធ្វើការនៅក្រុមហ៊ុននោះ។ អ្នកតាំងចិត្តថាមិនឱ្យខ្លួនឯងធ្លាក់ទៅក្នុងស្ថានភាពដូចបងស្រីរបស់ចន្ទលីណាឡើយ។

ស្របពេលសូរិយាកំពុងឆែកគេហទំព័រពីមួយទៅមួយយ៉ាងស្វាត់ជំនាញអ្នកកត់ត្រាឈ្មោះក្រុមហ៊ុនដែលអ្នកយល់ថាទំនង។ ទោះជាអ្នកមិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីធ្វើដំណើរក្ដី អ្នកនៅតែមានអារម្មណ៍ល្អព្រោះយ៉ាងហោចណាស់បានរៀបចំហើយត្រៀមខ្លួនទុកជាមុន។ ភ្លាមៗនោះអ្នកស្រាប់តែនឹកឃើញ សុភាសិតដ៏ល្បីរបស់ទស្សនវិទូចិនឈ្មោះ ឡៅជឺ ហើយអ្នកក៏បាននិយាយទៅកាន់សូរិយាថា "មួយជំហ៊ានដំបូងនាំទៅរកដំណើររាប់សិបយោជនៃភាពជោគជ័យ។"

សូរិយាតបទាំងមិនសប្បាយចិត្តវិញថា"ជំហ៊ានដំបូងដែលនាំឯងចេញពយើង!!!"

អ្នករៀបនឹងតបទៅហើយ ស្រាប់តែឮអ្នកណាម្នាក់ស្រាប់តែហៅឈ្មោះអ្នក។ អ្នកងាករកមើល ហើយឃើញស៊ីតានៅមាត់ទ្វារធ្វើទឹកមុខភិតភ័យ។ អ្នកច្បាស់ក្នុងចិត្តថាមានរឿងមិនល្អកើតឡើងទៀតហើយ។

ស៊ីតាស្រែកទាំងដង្ហក់ថា "មកតាមខ្ញុំឱ្យលឿនមកទៅរកពុកនៅទន្លេ។"

◈◈◈

ឮហើយទាំងបីនាក់ក៏ប្រញាប់រត់សំដៅទៅទន្លេ។ នៅតាមផ្លូវស៊ីតារៀបរាប់ថាពុកចេញទូកទៅរកត្រីនៅទន្លេ តែគាត់កំពុងតែមានរឿង។ ពេលអ្នកមកដល់ទន្លេ អ្នកឃើញម្ដាយរបស់អ្នកកំពុងរង់ចាំនៅមាត់ទន្លេយ៉ាងអន្ទះសារ។

អ្នកសួរទាំងដង្ហក់ថា "ម៉ែ! ពុកនៅឯណា?"



ម្ដាយរបស់អ្នកចង្អុលទៅទូកពីរបីដែលនៅឆ្ងាយពីច្រាំងហើយនិយាយថា៖ ពុកកូននៅទីនោះ។ ម៉ែមិននឹកស្មានថាពុកឯងចេញទៅរកត្រីទាំងឈឺទេ។ គាត់ចែវទូកទៅបង់សំណាញ់ដល់ទីនោះ តែពេល គាត់សារសំណាញ់មកវិញគាត់ទាញមិនរួចឡើយព្រោះគាត់ឈឺគ្មានកម្លាំងទាញ។ អរគុណព្រះដែលមានគេទៅរកត្រីដល់កន្លែងនោះដែរ ហើយបាននាំគាត់មកវិញ។

នៅពេលទូកជិតមកដល់ច្រាំង អ្នកក៏អាចមើលឃើញថាមានកាណូតមួយសណ្ដោងទូកមួយទៀតពីក្រោយ។ អ្នកឃើញពុករបស់អ្នកស្ថិតក្នុងសភាពស្លេកស្លាំង អស់កម្លាំង ហើយគ្មានកម្លាំងកំហែងក្នុងខ្លួនឡើយ។ គាត់អង្គុយនៅលើទូកសណ្ដោងពីក្រោយកាណូត។ឃើញពុកអ្នកក្នុងសភាពបែបនេះអ្នកមានអារម្មណ៍ថាបេះដូងអ្នកកំពុងតែឈឺ។ ពេលទូកមកដល់កៀកច្រាំង អ្នកក៏ចុះទៅក្នុងទឹកដើម្បីទៅយកពុកអ្នកចេញពីទូក។

អ្នកសួរពុកអ្នកថា “ពុក!! ម៉េចហើយ?”

ពុកអ្នកនិយាយខ្សាវៗថា “ពុកប្រហែលជាមិនរស់ទេ។”

◈◈◈

ច្រើនខែកន្លងផុតទៅអ្នកចាប់ផ្តើមផ្តោតសំខាន់ទៅលើរឿងពីរ។ទីមួយគឺរកលុយឱ្យបានច្រើន ចំណែករឿងមួយទៀតគឺធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។

គោលបំណងដ៏ធំបំផុតរបស់អ្នកដំបូងគេនោះគឺធ្វើលិខិតឆ្លងដែន។ អ្នកត្រូវរៀបចំឯកសារជាមុនសិន ហើយត្រូវរង់ចាំយូរបន្តិច។ថ្វីត្បិតតែអ្នកត្រូវចាំយូរតែវាមានតម្លៃនៅពេលដែលអ្នកបានលិខិតឆ្លងដែនក្នុងដៃ។ អ្នកមានអារម្មណ៍ថាអ្នកចាស់ទុំជាងមុនឯករាជ្យជាងមុន និងអ្នកដើរជិតដល់កន្លែងដែលអ្នកត្រូវទៅហើយ។

ឥឡូវអ្នកជាភ្ញៀវជាប្រចាំក្លឹប។ អ្នកតែងតែចំណាយពេលដើម្បីឆែកគេហ-ទំព័ររបស់មជ្ឈមណ្ឌលជ្រើសរើសបុគ្គលិក ហើយអ្នកក៏បានឃើញការងារមួយចំនួនដែលសមនឹងសម្ថភាពរបស់អ្នក។ ការងារមួយដែលអ្នកចង់ធ្វើគឺការងារនៅក្នុងរោងចក្រ។ មើលទៅការងារនេះមិនសូវជាគួរឱ្យចាប់អារម្មណ៍ប៉ុន្មានទេ តែអ្វីដែលសំខាន់គឺការងារនេះមិនទាមទារអ្វីច្រើនឡើយ។ អ្នកក៏បំពេញពាក្យសុំការងារ។ មិនយូរប៉ុន្មានខាងមណ្ឌលជ្រើសរើសបុគ្គលិកក៏បានទាក់ទងមកអ្នកហើយប្រាប់ថាការងារនេះ អ្នកអាចធ្វើបាន។ តែដំបូងអ្នកត្រូវធ្វើលិខិតអនុញ្ញាតការងារ និងទិដ្ឋាការ ការងារជាមុនសិន។ក្រុមការងារក៏បានផ្តល់ពាក្យសុំការងារជាផ្លូវការរបស់ក្រុមហ៊ុន ដើម្បីឱ្យអ្នកអាចដាក់ពាក្យសុំធ្វើការនៅទីនោះបាន។

រឿងមួយទៀតដែលអ្នកត្រូវធ្វើគឺការរៀនភាសាតាមអ៊ីនធឺណិត។ អ្នករៀនភាសាមិនបានលឿនទេ ព្រោះអ្នកមិនសូវជាមានទំនុកចិត្តលើខ្លួនឯងពេលនិយាយភាសានេះ(សូរិយាតែងតែសើចរាល់ពេលគាត់ឮអ្នកអនុវត្តភាសា)។ ប៉ុន្តែប៉ន្មានខែក្រោយមក អ្នកមានការភ្ញាក់ផ្អើលចំពោះខ្លួនឯងជាខ្លាំងព្រោះអ្នកចេះពាក្យបានច្រើន។

អ្នកបានចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយណារិន។ គេហាក់ដូចជាសប្បាយចិត្តខ្លាំងពេលដែលគេដឹងថានៅតែគិតដល់ការធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ហើយគេសង្ឃឹមថាគេនឹងអាចបានជួបអ្នកពេលដែលអ្នកទៅដល់។

លុយអាចធ្វើឱ្យគ្រប់យ៉ាងដំណើរការទៅយ៉ាងរលូន។ក៏ប៉ុន្តែអ្នកបានចំណាយលុយសន្សំរបស់អ្នកដើម្បីសងលោកស្នេកគឺអស់ទៅហើយ។ ម្យ៉ាងទៀតអ្នកត្រូវចំណាយលុយដើម្បីធ្វើលិខិតឆ្លងដែនទៀត។ អ្នកដូចជាត្រូវចាប់ផ្តើមសន្សំលុយសារជាថ្មីអញ្ចឹង។ អ្នកហាក់ដូចជាមានអ្វីម្យ៉ាងមកអូសទាញអ្នកឱ្យចង់ទៅធ្វើការឆ្លងដែនជាមួយនឹងលុយតិចតួចស្តួចស្តើងដែលអ្នកមាន (ជាពិសេសនៅពេលដែលណារិនកាន់តែជម្រុញអ្នកឱ្យទៅ)។ តែអ្នកដឹងច្បាស់ថាអ្នកមិនគួរទៅណាទាំងអស់។ អ្នកអាចទៅបានបើសិនជាអ្នកមានលទ្ធភាពបង់ថ្លៃស្នាក់នៅខែទីមួយ

ថ្លៃធ្វើដំណើរទៅមក និងថ្លៃចំណាយផ្សេងទៀត។

អ្នកចំណាយពេលជិតប្រាំបីខែដើម្បីសន្សំលុយឱ្យបានគ្រប់ចំនួន។ អ្នកបានសម្រេចចិត្តថាអ្នកនឹងប្រើលុយសន្សំនេះសម្រាប់ការចំណាយលើអ្វីដែលអ្នកបានគ្រោងទុកនិងការចំណាយផ្សេងទៀត។ ការពិតអ្នកសន្សំលុយបានគ្រប់ចំនួនព្រោះតែមានការជួយជ្រោមជ្រែងពីពូរបស់សូរិយាគឺលោកពូសំរិន។ អ្នកមិនដែលស្មានសោះថា លោកពូសំរិនបានផ្តល់ប្រាក់បន្ថែមទៅលើការខិតខំធ្វើការរបស់អ្នកនៅកន្លែងលក់ទឹកដោះគោនិងទឹកឃ្មុំ។ អ្នកមានអារម្មណ៍ថារំភើបលាយភ័យនៅពេលគាត់ហុចប្រាក់ខែឱ្យអ្នកព្រោះអ្នកយល់ថានៅពេលអ្នកមានលុយគ្រប់ចំនួនគឺជិតដល់ពេលដែលអ្នកត្រូវចាកចេញហើយ។

អ្នកគិតថាអ្នកនឹងប្រាប់រឿងនេះប្រាប់លោកពូសំរិននិងអ្នកមីងជាឱ្យបានឆាប់។ រឿងដែលធ្វើឱ្យអ្នកកាន់តែមិនស្រួលចិត្តគឺពួកគាត់បានអញ្ជើញអ្នក (និងសូរិយា) មកញាំបាយល្ងាចជាមួយគ្នា។ អ្នកបានសម្រេចចិត្តថានឹងប្រាប់ពួកគាត់នៅពេលញាំបាយល្ងាចនោះតែម្តង។

នាថ្ងៃដដែលនោះ អ្នកបានទទួលសារ ពីណារិន៖



នៅយប់នោះ អ្នកទៅញ៉ាំបាយល្ងាចនៅផ្ទះលោកពូសំរិននិងមីងជា។ អ្នកមិនហ៊ានប្រាប់ពួកគាត់ពីការសម្រេចចិត្តរបស់អ្នកឡើយ។ ពួកគាត់ល្អនឹងអ្នកណាស់ ហើយអ្នកពិតជារីករាយនឹងធ្វើការនៅកន្លែងលក់ទឹកដោះគោនិងទឹកឃ្មុំណាស់។

មុនពេលញ៉ាំបាយល្ងាច មីងជាបានយកទឹកតែមកឱ្យអ្នកញ៉ាំក្នុងបន្ទប់ទទួលភ្ញៀវ។ អ្នកមានអារម្មណ៍ថាសូរិយាកំពុងតែសប្បាយចិត្តនឹងរឿងអ្វីម្យ៉ាង តែអ្នកមិនដឹងថានាងរីករាយព្រោះតែរឿងអ្វីឡើយ។ អ្នកមានអារម្មណ៍ថាការសម្រេចចិត្តរបស់អ្នកអាចបំផ្លាញអារម្មណ៍ល្អរបស់សូរិយា។ ម្យ៉ាងទៀតអ្នកមិនចង់បំផ្លាញបរិយាកាសសប្បាយរីករាយនេះឡើយ។ អ្នកក៏សម្រេចចិត្តម្តងទៀតថាអ្នកមិនទាន់ប្រាប់ពួកគេឡើយ។

នៅពេលអ្នករៀបហាមាត់និយាយ ស្រាប់តែសូរិយាសម្លឹងមើលពូនិងមីងរបស់នាងហើយ និយាយថា "គួរប្រាប់នាងអត់?"

ពូសំរិននិងមីងជាងក់ក្បាល ហើយអ្នកមើលដឹងថាពួកគាត់ដូចជារំភើបអំពីរឿងអ្វីម្យ៉ាង។ អ្នកឱ្យសូរិយានិយាយមុន។

សូរិយានិយាយព្រមទាំងសម្តែងសេចក្តីសប្បាយរីករាយថា៖ ថ្មីៗនេះយើងបានពិភាក្សាជាមួយលោកពូនិងមីងអំពីកន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំ នាថ្ងៃអនាគត។ ហើយពួកយើងមានដំណឹងរីករាយដើម្បីប្រាប់ឯង។ តើអ្នកនៅចាំបានអត់ថាពួកយើងធ្លាប់និយាយថាអ្វីដែលពួកយើងត្រូវធ្វើគឺទាក់ទាញអតិថិជនឱ្យមកកន្លែងលក់ទឹកដោះគោនិងទឹកឃ្មុំរបស់យើង? ពួកយើងមានគំនិតមួយហើយពួកយើងគិតថាពួកយើងអាចសម្រេចគោលបំណងនេះបាន។ គំនិតនោះគឺបើកកន្លែងលក់ទឹកដោះគោនិងទឹកឃ្មុំព្រមទាំងមានសេវាអ៊ីនធឺណិត។ នេះជាអ្វីដែលអ្នកភូមិនេះត្រូវការ។ ពូ និង មីងបានយល់ព្រមជួយជាដើមទុនដើម្បីឱ្យពួកយើងអាចទិញទិញកុំព្យូទ័រ និងសម្ភារមួយចំនួនទៀត។ ហើយយើងចង់ឱ្យឯងក្លាយជាដៃគូជំនួញរបស់ខ្ញុំ។ តែពួកយើងទាំងពីរត្រូវរៀនឱ្យចប់សិន ហើយយើងត្រូវរៀនមួយឆ្នាំទៀតសិន។

អ្នកសម្លឹងមើលមុខអ្នកទាំងបី ចំពេលដែលពួកគេងាកមើលមុខអ្នកទាំងញញឹមវិញដែរ។ អ្នកដូចជាភ័យៗហើយមិនដឹងថាគួរនិយាយអ្វីឡើយ។

សូរិយាសួរថា "អញ្ចឹងឯងគិតម៉េចដែរ? បើយើងវិញគិតថាគំនិតនេះប្រហែលជាអាចទៅរួច។ ដល់ពេលនោះយើងអាចសន្សំលុយបានច្រើនហើយឯងមិនចាំបាច់ទៅណារកការងារផ្សេងទៀតទេ។"

អ្នកងក់ក្បាល ងក់តិចៗរហូតទាល់តែអ្នកនឹកឃើញថាអ្នកត្រូវនិយាយអ្វី។

អ្នកនិយាយថា “ខ្ញុំគិតថាគំនិតនេះពិតជាល្អមែន។ គ្រាន់តែ........ខ្ញុំបានរៀបគម្រោងផ្សេងរួចទៅហើយ ម្យ៉ាងទៀត................. “

ភ្លាមនោះអ្នកក៏បានឃើញទឹកមុខបែបខកចិត្តរបស់ពូមីង និង សូរិយា។

អ្នកនិយាយថា “ខ្ញុំទើបតែគិតពីគម្រោងនេះទេ។ សូមទុកពេលឱ្យខ្ញុំពីរបីថ្ងៃសិនបានអត់?”

អ្នកទាំងអស់គ្នាក៏បានយល់ស្របនឹងសំណើនេះ។



**បើអ្នកសម្រេចចិត្តបន្តគម្រោងរកការងារនៅទីក្រុងធំ សូមទៅកាន់ទំព័រទី ៧១**

៧១



**បើអ្នកសម្រេចចិត្តនៅទៅនេះ ហើយរកស៊ីជាមួយសូរិយា សូមទៅកាន់ទំព័រទី ៩២**

៩២

# ទីក្រុងធំ



នេះជាការសម្រេចចិត្តដែលពិបាកបំផុតសម្រាប់អ្នក។ តើមានមានមនុស្សប៉ុន្មាននាក់ទៅដែលមានឱកាសធ្វើជំនួញជាមួយមិត្តល្អរបស់គេ? អ្វីដែលពិសេសគឺមិត្តល្អម្នាក់នោះជាស្វូរិយា។

តាមដែលអ្នកស្គាល់នាងជាមនុស្សដែលឧស្សាហ៍ព្យាយាមហើយអាចពឹងពាក់បានទៀតផង។ ដោយសារតែនាងមានឧបនិស្ស័យនឹងកុំព្យូទ័រក៏ដូចជាបច្ចេកវិជ្ជា នាងសក្តិសមនឹងគ្រប់គ្រងអាជីវកម្មផ្នែកអ៊ីនធឺណិតបំផុត។ ចំណែកអ្នកវិញត្រូវមើលការខុសត្រូវកន្លែងលក់ទឹកដោះគោនិងទឹកឃ្មុំ។ អ្នក មានទំនុកចិត្តខ្ពស់ថាអ្នកពិតជាអាចធ្វើការងារនេះបាន។អ្នកតែងតែគិតក្នុងចិត្តថាការងារអ្វីក៏អាចសម្រេចបានដែរ ឱ្យតែអ្នកទាំងពីរសហការគ្នា។

ប៉ុន្តែអ្នកត្រូវចាំមួយឆ្នាំទៀត រហូតដល់អ្នករៀនចប់...? ពិតណាស់អ្នកចង់រៀនឱ្យចប់សិន ក៏ប៉ុន្តែសំពាធដែលអ្នកមាននៅផ្ទះ បង្វែរការតាំងចិត្តរបស់អ្នក។ អ្នកត្រូវតែរកលុយឱ្យច្រើន ហើយអ្នកត្រូវចាប់ផ្តើមរកលុយក្នុងឆាប់ៗនេះ។

ចំណែករឿងមួយទៀតដែលជម្រុញអ្នកឱ្យអ្នកធ្វើការសម្រេចចិត្តនោះគឺណារិន។

នៅពេលអ្នកប្រាប់ស្វូរិយាថាអ្នកសម្រេចចិត្តចាកចេញ នាងពិតជាខកចិត្តណាស់ ហើយនាងប្រាប់ថានាងក៏ធ្លាប់គិតថាអ្នកនឹងសម្រេចចិត្តបែបនេះដែរ។ នាងនិយាយថានាងមិនបោះបង់គំនិតបើកអាជីវកម្មអ៊ីនធឺណិតជាមួយអ្នកឡើយ។ ហើយនាងសុំឱ្យអ្នកសន្យាថាប្រសិនបើមួយឆ្នាំទៀតការងារនៅទីក្រុងមិនដំណើរការបានល្អ នាងនៅតែរង់ចាំអ្នកមកធ្វើជាដៃគូជំនួញរបស់នាង។ អ្នកក៏បានសន្យានឹងនាង។

ពេលនេះជាពេលដែលអ្នកត្រូវទាក់ទងទៅមជ្ឈមណ្ឌលជ្រើសរើសបុគ្គលិក ហើយប្រាប់គេថាអ្នកមានចំណាប់អារម្មណ៍នឹងការងារមួយក្នុងការងារទាំងអស់ ដែលគេបានផ្សព្វផ្សាយ។

អ្នកសឹងតែមិនជឿ។ ក្រោយពីរៀបគម្រោង ទីបំផុតអ្នកក៏ត្រៀមខ្លួនរួចរាល់ ដើម្បីចេញទៅ។

ពេលដែលអ្នកមានសំបុត្រឡានក្រុងក្នុងដៃ អ្នកក៏បានផ្ញើរសារ ទៅណារិន ៖



នៅថ្ងៃបន្ទាប់អ្នកក៏ជិះឡានក្រុងធ្វើដំណើរឆ្លងកាត់ព្រំដែនសំដៅទៅទីក្រុងធំ ហើយមានអារម្មណ៍ហាក់បីដូចជាមេអំបៅរាប់ពាន់កំពុងហោះហើរជុំវិញក្រពះរបស់អ្នក។

គ្មានអ្នកណាម្នាក់អាចហាមឃាត់អ្នកមិនឱ្យភ័យឡើយ។នេះពិតជាការចាប់ផ្ដើមទំព័រជីវិតថ្មីនៅក្នុងប្រទេសថ្មី ក្នុងទីក្រុងថ្មី ជាមួយនិងការងារថ្មី។ អ្នកពិតជាចង់ជួបណារិនម្ដងទៀតណាស់ ព្រោះអ្នកនិងគេបែកគ្នាយូរមកហើយ។ អ្នក និង គេខានជួបគ្នាជិតមួយឆ្នាំហើយ។ អ្នក និង គេបានផ្ញើសារទៅគ្នាជាច្រើន ប៉ុន្តែ វាមិនដូចការជួបគ្នាដោយផ្ទាល់នោះទេ។ ចុះអ្នកធ្វើយ៉ាងម៉េចវិញ បើគេមិនស្រលាញ់អ្នក? ហើយធ្វើយ៉ាងម៉េចវិញបើអ្នកមិនស្រលាញ់គេ? មានរឿងផ្សេងទៀតដែលប្រហែលជាមិនល្អដូចការគិត។ អ្នករៀបចំខ្លួនឱ្យរៀបរយ។

នៅពេលឡានក្រុងមកដល់បេន អ្នករកមើលគេក្នុងចំណោមហ្វូងមនុស្សទាំងឡាយ។ តែអ្នកមិនឃើញគេឡើយ ឃើញមានតែមនុស្សជាច្រើនកំពុងតែរង់ចាំ។ អ្នកចុះពីឡានក្រុង ហើយដើរទៅយកឥវ៉ាន់របស់អ្នក។ ស្របពេលដែល អ្នកកំពុងតែប្រមូលឥវ៉ាន់ អ្នកលួចរំពឹងថាណារិនប្រាកដជាមកពញ្ញាក់អ្នកពីក្រោយ តែគាត់មិនបានធ្វើអញ្ចឹងឡើយ។អ្នកនៅតែខំរកមើលគេ តែនៅតែមិនឃើញគេមក។

មានមនុស្សជាច្រើនកំពុងតែដើរចុះដើរឡើង តែអ្នកបែរជាមានអារម្មណ៍ថាអ្នកឈរតែម្នាក់ឯងទៅវិញ។ តិចលោណារិនប្ដូរចិត្តទេដឹង? ស្រាប់តែពេលនោះអ្នកមានអារម្មណ៍ថាខកចិត្តជាខ្លាំងហើយអ្នកក៏ចាប់ផ្ដើមមានអារម្មណ៍ថាឯកាណាស់។

អ្នកក៏ទៅកាន់តូបតូចមួយហើយទិញស៊ីមកាតសម្រាប់ប្រើ។ អ្នកនៅឈររេរាក្បែរតូបនោះដើម្បីដាក់ស៊ីមកាតចូលទូរសព្ទរបស់អ្នក។ កំពុងតែដាក់ស៊ីមស្រាប់តែអ្នកមានអារម្មណ៍ថាមានមនុស្សវាយស្មារបស់អ្នក។

សម្លេងចេញពីក្រោយខ្នងថា “អេ!!!”

អ្នកភ័យសឹងតែជ្រុះទូរសព្ទពីដៃទៅហើយ។ពេលដែលអ្នកងាកក្រោយស្រាប់តែអ្នកឃើញណារិនកំពុងតែឈរញញឹមពព្រាយ។ អ្នកមានអារម្មណ៍ថាធូរទ្រូងខ្យាក។ អ្នកសឹងតែយំទៅហើយ តែអ្នកព្យាយាមទប់ទឹកភ្នែកមិនឱ្យស្រក់ឡើយ។

គេនិយាយថា “ឱ្យបងសុំទោសណា!! បងមកយឺតបន្តិចហើយ ព្រោះពិបាករកកន្លែងចតឡានហ្នឹងណា!”

អ្នកក៏តបវិញថា “មិនអីទេបង!!”



ការពិតអ្នកទាំងពីរពិតជាចង់ឱបគ្នាខ្លាំងណាស់។ តែដោយសារតែគ្មានអ្នកចាប់ផ្ដើមមុន ទើបអ្នកទាំងពីរមិនបានធ្វើតាមអារម្មណ៍របស់ខ្លួនឡើយ។

ពេលនោះណារិនក៏យកកាបូបរបស់អ្នកទៅស្ពាយ ហើយប្រាប់អ្នកឱ្យចេញទៅ។

មកដល់កន្លែងចតយានយន្ត ណារិននាំអ្នកដើរទៅឡានចាស់ច្រេះចាប់របស់គេ។ គេញញឹមតិចៗពេលដែលឃើញប្រតិកម្មអ្នក។

គេនិយាយថា “អាហ្នឹងឡានតើ!!”

ដើម្បីបើកទ្វារឡាននោះ អ្នកត្រូវទាញកន្ត្រាក់បន្តិច។ ក្រោយពីកន្ត្រាក់រួចមកអ្នកបើកទ្វារឡានបាន។ អ្នកចូលទៅអង្គុយក្នុងឡាននោះ។ ណារិនបានដាក់កាបូបអ្នកនៅខាងក្រោយ រួចគេក៏ចូលមកអង្គុយកន្លែងអ្នកបើកបរ។

គេសួរអ្នកថា “តើប្អូនចង់ទៅណាវិញ?”

អ្នកក៏បង្ហាញអាសយដ្ឋានរបស់កន្លែងដែលអ្នកត្រូវស្នាក់នៅឱ្យទៅគេ។

អាសយដ្ឋានរបស់កន្លែងនោះគឺខាងមជ្ឈមណ្ឌលជ្រើសរើសបុគ្គលិលជាអ្នកផ្ញើរឱ្យអ្នក។ វាជាកន្លែងស្នាក់នៅដែលក្រុមហ៊ុនរៀបចំសម្រាប់បុគ្គលិក។ មានគេប្រាប់អ្នកថាយប់នេះអ្នកត្រូវស្នាក់នៅកន្លែងនោះ ហើយអ្នកត្រូវរាយការណ៍ទៅរោងចក្រនៅពេលព្រឹក។

◈◈◈

ការធ្វើដំណើរតាមរថយន្តឆ្លងកាត់ទីក្រុងជាមួយណារិនមិនមែនសូវជាស្រួលខ្លួនប៉ុន្មានទេ។ ចំណែកចរាចរណ៍វិញមិនសូវជាល្អឡើយ។ មានសម្លេងអ្វីប្លែកៗម៉េចមិនដឹងទេឮចេញពីឡានរបស់ណារិន។ ហើយពេលនោះហើយដែលអ្នកចាប់អារម្មណ៍ថាណារិនច្បាស់ជាមិនសូវបានជិះឡានក្នុងទីក្រុងឡើយ។អ្នកទាំងពីរមិនសូវជាបាននិយាយគ្នាឡើយ ព្រោះណារិនរវល់តែផ្តោតអារម្មណ៍ទៅនឹងកន្លែងដែលគាត់ត្រូវនាំអ្នកទៅ។

◈◈◈

ទម្រាំអ្នកមកដល់កន្លែង អ្នកមានអារម្មណ៍ថាអស់កម្លាំងរលីង។ កន្លែងស្នាក់នៅមានសភាពសាម័ញ្ញៗ។ គេឱ្យអ្នកនៅបន្ទប់តូចមួយដែលមើលទៅដូចជាប្រអប់គូបអញ្ចឹង។ កន្លែងនេះមានបន្ទប់រាងប្រអប់គូបនោះរាប់រយបន្ទប់ ហើយប្រហែលជាមានន័យថា មានក្មេងស្រីនិងស្ត្រីជាច្រើនរយនាក់ស្នាក់នៅក្នុងនោះផងដែរ។ នេះមិនមែនជាអ្វីដែលអ្នករំពឹងទុកទេ ប៉ុន្តែអ្នកបានសម្រេចចិត្តថាអ្នកត្រូវតែធ្វើដើម្បីចាប់ផ្តើមជិវិតរបស់អ្នក ហើយអ្នកនឹងធ្វើវារហូតទាល់តែជិវិតអ្នកគ្រាន់បើជាងនេះ។

ដោយសារនេះជាយប់ដំបូងរបស់អ្នកនៅទីនេះ ណារិនស្ម័គ្រចិត្តនាំអ្នកដើរមើលជុំវិញទីក្រុងបន្តិច។ អ្នកចង់ប្រកែកមិនទៅ ព្រោះតែអ្នកអស់កំលាំងខ្លាំងពេក។ តែដោយសារតែមើលទៅណារិនដូចជាចង់នាំអ្នកដើរលេងពេក អ្នកក៏សម្រេចចិត្តទៅជាមួយគេ។

អ្នកពិតជារីករាយនឹងអ្វីដែលអ្នកកំពុងតែធ្វើណាស់។ គេនាំអ្នកដើរតាមមាត់ទន្លេអមដោយ ទិដ្ឋភាពដ៏ស្រស់ស្អាតរបស់ទីក្រុង ។ នេះជាលើកដំបូងដែលអ្នកមានអារម្មណ៍ថាអ្នកអាចនិយាយទៅគាត់ដោយស្រណុកចិត្ត ហើយមានអារម្មណ៍ថាស្រស់ស្រាយណាស់ពេលដែលបាននៅជាមួយគេ។ ទីបំផុតអ្នកក៏បានមកដល់ផ្សារលក់អាហារដែលមានមនុស្សយ៉ាងច្រើនកុះករ។ ស្គរសម្លង អាំងសាច់បាបីឃ្យូរ និងក្លិនអាហារធ្វើឱ្យអ្នកចង់ស្រក់ទឹកមាត់។ ណារិនឱ្យអ្នកសាកអាហារដែលអ្នកមិនដែលបានញ៉ាំហើយវាមានរសជាតិឆ្ងាញ់។ អ្នកជាចុងក្រោយអង្គុយនៅបង់យ៉ាងយូរ ហូបអាហារ ជជែកគ្នា ស្តាប់តន្ត្រីនៅតាមផ្លូវ និងមើលមនុស្ស

ដើរទៅមកៗ។

ទីនេះប្រៀបដូចជាពិភពលោកមួយដែលខុសពីជីវិតអ្នកកាលនៅភូមិអ្នកមានអារម្មណ៍រំភើបនិងដឹងគុណដែលណារិននៅក្បែរអ្នក។ បើគ្មានគេទេ ប្រហែលជាអ្នកគ្មានពេលវេលាល្អបែបនេះឡើយ។

បន្ទាប់ពីដើរលេងពេលល្ងាចរួច ណារិនបានជូនអ្នកមកកន្លែងស្នាក់នៅ។ នៅពេលអ្នកឈរនៅពីក្រៅអាគារ អ្នកបានអរគុណគាត់សម្រាប់ពេលវេលាដ៏អស្ចារ្យនេះ។

គាត់កាន់ដៃអ្នកហើយនិយាយថា "បងចង់ជួបប្អូនម្ដងទៀត។ ជួបគ្នាយប់ស្អែកបានអត់?"

រំពេចនោះ អ្នកមានអារម្មណ៍ភ្ញាក់ៗហើយមិនច្បាស់ថាត្រូវធ្វើអ្វី។ អ្នកក៏ចង់ជួបគាត់វិញដែរ ប៉ុន្តែអ្នកត្រូវចាប់ផ្ដើមការងារនៅថ្ងៃស្អែក ហើយអ្វីដែលសំខាន់នោះគឺត្រូវគិតការងារជាធំ។

អ្នកនិយាយ "ចាំទាក់ទងគ្នាតាមសារ។ ចាំជួបគ្នានៅចុងអាទិត្យបានអត់?"

គាត់ងក់ក្បាលនិងច្របាច់ដៃរបស់អ្នក ប៉ុន្តែអ្នកដឹងថាគាត់ទំនងជាខកចិត្តបន្តិច។

អ្នកនិយាយពាក្យរាត្រីសួស្ដី បន្ទាប់មកក៏ចូលទៅក្នុងអាគារ។

នៅខាងក្នុងអាគារ អ្នកបិទភ្នែកហើយគ្រវីក្បាល។ អ្នកមានពេលដ៏អស្ចារ្យ។ អ្នកសង្ឃឹមថាអ្នកមិនធ្វើឱ្យរឿងគ្រប់យ៉ាងប្រែទៅជារញ៉េរញ៉ៃឡើយ។

◈◈◈

នៅថ្ងៃបន្ទាប់ អ្នកក៏បានរាយការណ៍ទៅខាងរោងចក្រ។ ការពិតវាគ្រាន់តែជាការយល់ឃើញរបស់អ្នកតែប៉ុណ្ណោះដែលថាអ្នកត្រូវឆ្លងកាត់ការសម្ភាសន៍មុនពេលចូលធ្វើការ។ ប៉ុន្តែអ្នកឃើញក្មេងស្រីជាច្រើនកំពុងតែរង់ចាំនៅទីនោះ ហើយគ្មានឃើញការសម្ភាសន៍ការងារអ្វីទេ។ សំនួរតែមួយគត់ដែលគេសួរគឺឈ្មោះនិងអាយុរបស់អ្នក។បន្ទាប់មកគេប្រាប់អ្នកឱ្យអង្គុយក្នុងបន្ទប់មួយជាមួយក្មេងស្រីទាំងអស់នោះ។

ទីបំផុតមានអ្នកចាត់ការម្នាក់ដែលមើលទៅទំនងជាកាច បានដើរចូលមកហើយស្នើឱ្យអ្នកទាំងអស់គ្នាផ្ចង់អារម្មណ៍ស្ដាប់គាត់និយាយ។ គាត់អត់បាននិយាយភាសារបស់អ្នកទេ ប៉ុន្តែអ្នកមានការ ភ្ញាក់ផ្អើលចំពោះខ្លួនឯងដែរព្រោះ

អ្នកយល់អ្វីដែលគាត់និយាយ។

គាត់ប្រាប់ថាអ្នកនឹងអាចចាប់ផ្តើមការងារនៅក្នុងរោងចក្រភ្លាម ហើយអ្នកត្រូវចាប់ដៃគូជាមួយកម្មករផ្សេងទៀតដែលមានបទពិសោធន៍ស្រាប់។ ដូច្នេះពួកគាត់បង្ហាញអ្នកថាត្រូវធ្វើអ្វី។ បន្ទាប់មកគាត់ប្រកាសពីចំនួនប្រាក់កំរៃដែលអ្នកអាចនឹងទទួលបាន ស្តាប់ទៅវាតិចជាងចំនួនអ្វីដែលបានផ្សាយ។ នៅពេលដែលមានអ្នកណាលើកឡើងពីបញ្ហានេះគាត់និយាយទាំងកំរោលថា គ្រប់គ្នាស្ថិតក្នុងកំឡុងពេលសាកល្បងការងារ ហើយនៅពេលអ្នកណាដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការងារគេនឹងតម្លើងប្រាក់ខែឱ្យ។

ម៉ោងធ្វើការក៏វែងជាងអ្វីដែលមជ្ឈមណ្ឌលជ្រើសរើសបុគ្គលិកប្រាប់អ្នក។

នៅពេលអ្នកចាត់ការរៀបនឹងដើរចេញ អ្នកស្រាប់តែនឹកឃើញដល់រឿងកិច្ចសន្យា។ សំដីរបស់ចន្ទលីណាបានបន្លឺឡើងពេញត្រចៀករបស់អ្នកថា “ឯងត្រូវតែចុះកិច្ចសន្យាមុនពេលចូលធ្វើការ។”អ្នកក៏បានលើកសំណួរនេះឡើង ហើយសួរអ្នកចាត់ការថាតើអ្នកនឹងមានកិច្ចសន្យាដើម្បីចុះហត្ថលេខាឬអត់។ អ្នកចាត់ការឆ្លើយតបយ៉ាងលឿនថា “ក្រុមហ៊ុនមិនដែលធ្វើកិច្ចសន្យានោះទេ។ និយាយរួចគាត់ក៏ដើរចេញពីបន្ទប់។”

អ្នកព្យាយាមគិតឱ្យយល់ពីដំណឹងថ្មីនេះ។ អ្នកទាំងអស់គ្នាត្រូវបានគេនាំចេញពីបន្ទប់នោះរួចឱ្យពួកគេចូលទៅក្នុងរោងចក្រ។ បរិវេណរោងចក្រនោះគឺធំហើយមានសម្លេងរំខានខ្លាំង។ មានម៉ាស៊ីនជាច្រើនជួរ ហើយសុទ្ធសឹងតែជាម៉ាស៊ីនយក្ស។ កម្មករម្នាក់ឬពីរនាក់ត្រូវកាន់ម៉ាស៊ីនមួយ។ គេផ្តល់អាវក្រៅឱ្យអ្នកពាក់ (ប៉ុន្តែគ្មានស្រោមដៃឬវ៉ែនតាការពារភ្នែកឡើយ ដែលនេះធ្វើឱ្យអ្នកភ្ញាក់ផ្អើលជាខ្លាំង) បន្ទាប់មកមានគេនាំអ្នកទៅកាន់ម៉ាស៊ីនមួយក្នុងចំនោមម៉ាស៊ីនទាំងអស់។ នៅទីនោះមានស្ត្រីម្នាក់កំពុងតែធ្វើប្រតិបត្តិការជាមួយម៉ាស៊ីន ហើយគាត់ជាអ្នកណែនាំការងារដល់អ្នក។

ដោយសារតែមានសម្លេងរំខានខ្លាំងពីគ្រឿងម៉ាស៊ីន អ្នកសឹងតែស្តាប់ស្ត្រីនោះនិយាយមិនឮឡើយ។ ដូច្នេះអ្វីដែលអ្នកអាចធ្វើបានគឺត្រូវមើលនិងធ្វើតាមអ្វីដែលគាត់ធ្វើ។

ម៉ាស៊ីននេះគឺកំពុងតែផលិតប្លាស្ទិចផ្នែកខាងរបស់មួកការពារសម្រាប់ប្រើប្រាស់ក្នុងការដ្ឋាន។រាល់១០វិនាទីម្តងឬប្រហាក់ប្រហែលនេះ មានប្លាស្ទិចលោតចេញពីម៉ាស៊ីន។ ម៉ាស៊ីនស្រាប់តែឈប់ដំណើរការ ដែលតម្រូវឱ្យអ្នកត្រូវយកកាំបិតទៅកាត់ត្រង់មុខកាត់របស់ម៉ាស៊ីន។ នៅពេលអ្នកបានធ្វើបែបនេះរួច អ្នកដាក់វាជាគំនរ ហើយរងចាំប្លាស្ទិចមួយផ្សេងទៀតចេញមក។ ប្លាស្ទិចនោះក្តៅ

ដែលធ្វើឱ្យអ្នកពិតជាចង់បានស្រោមដៃ ប៉ុន្តែហាក់បីជាគ្មាននរណាម្នាក់នៅក្នុងរោងចក្រពាក់វាសោះ។

អ្នកធ្វើការបែបនេះជាបន្តបន្ទាប់អស់រយៈពេល៦ម៉ោង រហូតដល់ស៊ីរ៉ែនបន្លឺឡើងដែលបង្ហាញថាដល់ពេលសម្រាកញ៉ាំអាហារថ្ងៃត្រង់។

កំឡុងពេលអាហារថ្ងៃត្រង់ អ្នកឃើញថាអ្នកស្ថិតក្នុងរោងអាហារដ៏ធំមួយ ហើយអង្គុយជិតមនុស្សម្នាក់ដែលមកពីប្រទេសអ្នកដែរ។ មើលទៅគេដូចជាមិនចង់និយាយរកអ្នកទាល់តែសោះ។ ប៉ុន្តែអ្នក ព្យាយាមដើម្បីទទួលបានព័ត៌មានពីគេ។ អ្នកដឹងថាគាត់ធ្វើការនៅទីនោះអស់រយៈ៦ខែមកហើយ តែគេនៅតែជាប់ប្រាក់ខែជាបុគ្គលិកសាកល្បងការងារដំបូងទៀត។ អ្នកធ្វើការគណនាក្នុងចិត្តដើម្បីឱ្យដឹងថាអ្នកអាចសល់ប្រាក់ប៉ុន្មានបន្ទាប់ពីកាត់កងថ្លៃស្នាក់នៅអាហារ និងអ្វីដែលចាំបាច់ផ្សេងទៀត។

ប្រាក់សេសសល់គឺមិនច្រើនទេ។ ប្រាកដណាស់វាច្រើនជាងប្រាក់ដែលអ្នករកបាននៅកន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំ។ ប៉ុន្តែការគិតបែបនេះធ្វើឱ្យអ្នកស្មុគស្មាញខ្លាំងព្រោះអ្នកត្រូវគិតរាប់ខែ រាប់ឆ្នាំដើម្បីសម្រេចគោលដៅនៅខាងមុខ។

◈◈◈

មួយថ្ងៃៗអ្នកដូចជាមិនបានសម្រាកសោះ។អ្នកធ្វើការស្ទើរតែ១២ម៉ោងពេញក្នុងមួយថ្ងៃ ហើយអ្នកអាចសម្រាកបានពេលដែលមានគេមកប្រាប់ថាឱ្យឈប់។ ពេលចេញពីធ្វើការអ្នកសំដៅទៅបន្ទប់រាងប្រអប់គូបរបស់អ្នក ហើយអ្នកក៏បានសម្អាតបន្ទប់ទឹករួម ចំអិនអាហារក្នុងផ្ទះបាយរួម។ ធ្វើរួចអ្នកអង្គុយលើគ្រែរបស់អ្នកដែលព័ទ្ធជុំវិញដោយសម្លេងវិទ្យុ ទូរទស្សន៍និងសម្លេងមនុស្ស។

អ្នកផ្ញើសារទៅណារិន ដោយនិយាយប្រាប់គេថាអ្នកទើបតែបញ្ចប់ការងារថ្ងៃដំបូង ហើយអ្នកមានភាពស្រពិចស្រពិលនឹងការងារនោះ។ អ្នកប្រាប់គាត់ពីប្រាក់ខែដែលទាបជាងការផ្សាយរបស់គេ ម៉ោងការងារវែង ហើយអ្វីដែលសំខាន់នោះគឺគ្មានកិច្ចសន្យាការងារឡើយ។ អ្នកសួរយោបល់គេថាអ្នកគួរតែធ្វើយ៉ាណា។

អ្នកអត់បានទទួលសារតបពីគាត់វិញទេ។ ប្រហែលជាគាត់បានទៅគេងបាត់ទៅហើយ? អ្នកសង្ឃឹមថាគាត់មិនក្រៀមក្រំដោយដោយសារតែរឿងកាលពីល្ងាចមិញទៅចុះ។

◈◈◈

នៅថ្ងៃបន្ទាប់ នៅក្នុងរោងចក្រគឺមានលក្ខណៈដូចគ្នាទៅនឹងថ្ងៃមុនប្លែកត្រង់

ថាថ្ងៃនេះអ្នក ត្រូវធ្វើការជាមួយម៉ាស៊ីនតែម្នាក់ឯង។ គេប្រាប់អ្នកថាអ្នកមិនអាចអង្គុយបានទេ អញ្ចឹងហើយឱ្យតែពេលធ្វើការហើយ អ្នកតែងតែមានអារម្មណ៍ថាឈឺជើង។ ពេលខ្លះតែមិនសូវញឹកញាប់ មេក្រុមមកជិតនិងស្រែកដាក់អ្នកអំពីរឿងអ្វីមួយ។ អ្នកគិតថាគាត់ចង់ឱ្យអ្នកទុកដាក់គំនរឱ្យមានរបៀបជាងនេះ បើទោះជាអ្នកបានរៀបចំវាឱ្យមានរបៀបរួចហើយក៏ដោយ។ នៅពេលសម្រាកញ៉ាំអាហារថ្ងៃត្រង់ អ្នកបានផ្ញើសារទៅណារិនម្តងទៀត ហើយប្រាប់គាត់អ្នកពិតជាពិចារណាស្វែងរកការងារថ្មី។ ប៉ុន្តែអ្នកនៅតែមិនមានការឆ្លើយតប។ ប្រហែលជាគាត់នៅកន្លែងធ្វើការហើយទុកទូរសព្ទនៅផ្ទះទេដឹង? អ្នកមានអារម្មណ៍ថាការព្រួយបារម្ភបានកំពុងចូលមក។ អ្នកពិតជាចង់និយាយជាមួយគេណាស់។

ពាក់កណ្តាលរសៀលមេក្រុមចាប់ផ្តើមស្រែកដាក់អ្នកម្តងទៀតដោយគ្មានហេតុផលច្បាស់លាស់ឡើយ។ អ្នកយល់ថាគាត់ជាមនុស្សម្នាក់ក្នុងចំនោមមនុស្សទាំងអស់ដែលចូលចិត្តត្រួតត្រាគេឯងដើម្បីបង្ហាញឋានៈការងាររបស់គាត់។ អ្នកឃើញគាត់ដើរកាត់ពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយទៀត ដើរស្រែកគំរាមគេឯង។



អ្នកបានសម្រេចចិត្តថាអ្នកនឹងរកការងារថ្មី។

ពេលចប់ការងារ អ្នកប្រាប់អ្នកចាត់ការថាអ្នកលាឈប់។ គាត់ហាក់បីជាមិនខ្វល់អ្វីបន្តិចឡើយ។គាត់និយាយថាមានមនុស្សជាច្រើនផ្សេងទៀតចាំរង់ចាំធ្វើការរបស់អ្នក។ នៅពេលអ្នកទៅយកប្រាក់ឈ្នួល គេប្រាប់អ្នកថាលុយនោះគឺជាលុយដែលនៅសល់ក្រោយពីទូរទាត់ថ្លៃស្នាក់នៅ។ ហើយអ្នកត្រូវចាកចេញភ្លាមជាបន្ទាន់។ អ្នកចាកចេញពីរោងចក្រទាំងគ្មានអ្វីទាំងអស់ ប៉ុន្តែអ្នកនៅតែមានអារម្មណ៍ថាមានសេរីភាព ស្របពេលអ្នកដើរចេញតាមទ្វារទាំងនោះ។

◈◈◈

អ្នកប្រមូលកាបូបរបស់អ្នកចេញពីបន្ទប់ប្រអប់គូបដែលពោរពេញទៅដោយសម្លេងថ្លង់ទាំងនោះ។ វាគឺជាអារម្មណ៍ដ៏ធូរស្បើយដែលចាកចេញពីបន្ទប់ទាំងនោះផងដែរ។ ឥឡូវ អ្នកត្រូវរកកន្លែងណាមួយដើម្បីស្នាក់នៅ។ ទីបំផុតអ្នកអាចស្វែងរកសណ្ឋារគារមួយ។ សណ្ឋាគារនោះមានតម្លៃថ្លៃបន្តិច តែអ្នកសម្រាកតែមួយយប់ ពីរយប់ទេ។

អ្នកអង្គុយនៅក្នុងបន្ទប់សណ្ឋាគារនៅយប់នោះ  អ្នកព្យាយាមទូរសព្ទទៅណារិន។ សម្លេងរ៉ឺងៗក៏បានបន្លឺឡើង។ អ្នកផ្ញើសារប្រាប់គាត់ថាអ្នកបានឈប់ពីការងារហើយនិងសូមឱ្យគាត់ទាក់ទងមកអ្នកវិញផង។  អ្នកបញ្ចប់សារដោយនិយាយថា៖ ខ្ញុំសង្ឃឹមថាខ្ញុំមិនបានធ្វើអ្វីខុសដាក់បងឡើយ។  សូមទូរសព្ទមកខ្ញុំវិញផង។

អ្នកក៏បានផ្ញើសារទៅសូរិយាផងដែរ។នាងជាមនុស្សម្នាក់គត់ដែលគាំទ្រគំនិតរបស់អ្នក១០០% ហើយគិតថាអ្នកសមនឹងទទួលបានអ្វីដែលប្រសើរជាងនេះ។

ប៉ុន្តែនៅតែគ្មានការឆ្លើយតបពីណារិន។ អ្នកក៏បានលង់លក់ទៅដោយមានទូរសព្ទអ្នកនៅក្បែរ។

◈◈◈

ថ្ងៃបន្ទាប់អ្នកចំណាយពេលជិះឡានក្រុងយ៉ាងយូរដើម្បីទៅមជ្ឈមណ្ឌលជ្រើសរើសការងារ (មួយដែលរៀបចំការងាររោងចក្រឱ្យអ្នក) ដើម្បីមើលថាតើពួកគេអាចជួយអ្នករកការងារផ្សេងទៀតបានដែរឬអត់។

បន្ទាប់ពីរង់ចាំបន្តិច អ្នកឃើញថាអ្នកអង្គុយទល់មុខស្ត្រីម្នាក់ដែលមើលទៅរវល់ដែលមានឈ្មោះកាម៉ាលា។  អ្នកប្រាប់ពីបញ្ហាដែលអ្នកមានចំពោះការងារមុន ជាពិសេសប្រាក់កំរៃដែលមិនដូចការផ្សាយ ព្រមទាំងការមិនព្រមព្រៀងធ្វើកិច្ចសន្យា។ អ្នកក៏លើកប្រាប់ថាអ្នកត្រូវធ្វើការ១២ម៉ោង ហើយគេមិនមានផ្តត់ផ្គង់ស្រោមដៃនិងវ៉ែនតាការពារសុវត្ថិភាពដល់អ្នកឡើយ។

កាម៉ាលាស្តាប់អ្វីគ្រប់យ៉ាងដែលអ្នកនិយាយហើយគាត់បានកត់ត្រាផងដែរ។ នៅពេលដែលអ្នកនិយាយចប់ គាត់ដាក់ប៊ិចចុះហើយអង្គុយផ្អែកក្នុងកៅអី។

គាត់និយាយថា“មិនអីទេ” “ទុកឱកាសឱ្យខ្ញុំពន្យល់អ្នករឿងខ្លះ។ អ្វីដំបូងឯងត្រូវដឹងគឺថាការផ្លាស់ប្តូរការងារនៅពេលអ្នកនៅក្នុងប្រទេសនេះគឺមិនមែនងាយស្រួលអញ្ចឹងទេ។ គេចេញលិខិតអនុញ្ញាតការងារ ឱ្យប្អូនសម្រាប់ប្រភេទការងារខាងលើនេះ។ ដូច្នេះវាមានន័យថាអ្នកមិនអាចទៅធ្វើការងារផ្សេងទៀតនោទេ។”

នេះជាដំណឹងដ៏សែនអាក្រក់។ អ្នកមានអារម្មណ៍ថាព្រួយបារម្ភ។ អ្នកមិនបានសូម្បីតែគិតអំពីល័ក្ខខ័ណ្ឌមានក្នុងលិខិតការងារ។រំពេចនោះអ្នកត្រូវប្រឈមមុខជាមួយទិដ្ឋភាពដែលត្រូវត្រលប់ទៅធ្វើការនៅក្នុងរោងចក្រវិញ។  អ្នកមានអារម្មណ៍ចង់យំ។

កាម៉ាលាអាចមើលឃើញថាអ្នកមានសភាពក្រៀមក្រំដល់កម្រិតណា។ គាត់

មើលទៅកំណត់ត្រារបស់គាត់ ហើយចាប់ផ្តើមរកមើលអ្វីមួយក្នុងកុំព្យូទ័ររបស់គាត់។ ទីបំផុតគាត់ដូចជារកឃើញអ្វីដែលគាត់ចង់រក។

គាត់និយាយ “នេះនែ” គាត់អានព័ត៌មាននៅលើអេក្រង់កុំព្យូទ័រ។ “នេះប្រហែលជាចម្លើយ”

អ្នកអត់ដឹងថាគាត់ចង់និយាយពីអ្វីនោះទេប៉ុន្តែអ្នកមានអារម្មណ៍ថាប្រហែលជាមានជម្រើសផ្សេងទៀត។ “ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដែលកម្មករចំនាកស្រុកអាចផ្លាស់ប្តូរការងារបាននោះគឺនៅពេលនិយោជកបំពានលើច្បាប់ការងារ។ ប៉ុន្តែមុនពេលអ្នកអាចរំភើបបាន ខ្ញុំសូមដាស់តឿនអ្នកថាអ្នកនឹងត្រូវឆ្លងកាត់ដំណើរការផ្សេងទៀត រាប់បញ្ចូលទាំងក្រដាសស្នាម និងថ្លៃសេវាកម្ម។ តើអ្នកច្បាស់ទេថានេះជាអ្វីដែលឯងចង់បាន?”

នៅពេលនោះអ្នកមានអារម្មណ៍លើសពីសប្បាយចិត្តទៅទៀតដែលជម្រើសនោះមិនតម្រូវឱ្យអ្នកត្រលប់ទៅធ្វើការនៅរោងចក្រវិញ។

អ្នកងក់ក្បាលហើយនិយាយថា “ចាស”

“ប្រាកដណាស់!! បើទោះជាដំណើរការនេះចប់ ក៏ពួកយើងត្រូវការពេលខ្លះដើម្បីរកការងារថ្មីឱ្យអ្នក”

អ្នកនិយាយថា “ខ្ញុំយល់ហើយ។ អរគុណចំពោះការជួយរបស់អ្នក”

វាជាដំណើរការដ៏យូរ។ អ្នកចំណាយពេលអស់ពីរបីថ្ងៃដើម្បីបំពេញពាក្យសុំឈរក្នុងជួរបង់ថ្លៃសេវា ហើយបន្តបំពេញពាក្យសុំផ្សេងទៀត។ កាម៉ាលាគឺជាជំនួយការដ៏ធំ។ គាត់ស្កែននិងថតចម្លងឯកសារសម្រាប់អ្នក ហើយប្រាប់អ្នកកន្លែងណាដែលត្រូវទៅ។ គាត់ក៏ចំណាយពេលជាច្រើនដើម្បីស្វែងរកការងារផ្សេងទៀត។ ប៉ុន្តែនៅចុងថ្ងៃទីពីរ គាត់នៅតែមិនអាចរកការងារណាដែលសាកសម។ នេះជាកង្វល់ពីព្រោះអ្នកមិនអាចបំពេញពាក្យសុំរហូតដល់អ្នកទទួលបានការងារផ្សេងទៀត។

នៅថ្ងៃទីបីអ្នកត្រលប់ទៅមជ្ឈមណ្ឌលបុគ្គលិក ហើយឃើញថាកាម៉ាលាកំពុងអង្គុយទល់មុខនឹងស្ត្រីម្នាក់ទៀត។ គាត់ហៅអ្នកមកជិតហើយសូមឱ្យអ្នកអង្គុយចុះ។

កាម៉ាលាណែនាំអ្នកឱ្យស្គាល់ស្ត្រីម្នាក់នោះដែលមានឈ្មោះព្រីសាណា ហើយគាត់ពន្យល់ថាស្ត្រីម្នាក់នោះជាមនុស្សម្នាក់ក្នុងចំណោមអតិថិជនធំ។ ព្រីសាណាធ្វើការឱ្យភោជនីយដ្ឋានធំមួយក្នុងចំណោមភោជនីយដ្ឋានធំៗទាំងអស់ នៅក្នុងទី

ក្រុង ហើយពួកគេស្វែងរកបុគ្គលិកបន្ថែម។

អ្នកមានអារម្មណ៍ថាពួកគេកំពុងតែនិយាយពីអ្នក ហើយព្រីសាណាចង់សួរអ្នកពីបីសំណួរ។

ព្រីសាណាចាប់ផ្ដើមសួរសំណួរអ្នកជាភាសាអង់គ្លេស។ ជារឿងល្អខ្លាំងណាស់ដែលអ្នកក៏រៀនភាសាអង់គ្លេសបានយ៉ាងល្អនៅពេលអ្នកនៅរៀន។អ្នកប្រាប់គាត់ថាអ្នកមានបទពិសោធន៍បំរើការងារក្នុងភោជនីយដ្ឋាន ហើយអ្នកបានបើកហាងអាហារផ្ទាល់ខ្លួននៅស្រុក។នៅចុងនៃការសម្ភាសន៍ដ៏ខ្លីនេះព្រីសាណាយកលេខទូរស័ព្ទរបស់អ្នកហើយនិយាយថាគាត់នឹងនិយាយទៅថៅហ្វាយគាត់សិន។

នៅពេលព្រីសាណាទៅបាត់។ កាម៉ាលាពន្យល់ថាការងារនៅភោជនីយដ្ឋានគឺមានមនុស្សជាច្រើនចង់ធ្វើ។ នោះគឺជាភោជនីយដ្ឋានមួយក្នុងចំណោមភោជនីដ្ឋានផ្សេងទៀតនៅក្នុងទីក្រុងជាពិសេសប្អូនអាចបានលុយទឹកតែបានច្រើន។ប៉ុន្តែគាត់ក៏បានរំលឹកអ្នកថាអ្នកត្រូវខិតខំធ្វើការ ហើយម៉ោងធ្វើការអាចយូរ។ ប្រាកដណាស់ធ្វើការងារនៅទីនោះនឹងអាចជួយអ្នកក្នុងការបំពេញពាក្យសុំលិខិតអនុញ្ញាតការងារ ។

អ្នកមានអារម្មណ៍ល្អអំពីការងារនេះហើយអ្នកអរគុណកាម៉ាលាដែលបានគិតដល់គាត់។ អ្វីដែលអ្នកត្រូវធ្វើគឺចាំព្រីសាណាទូរស័ព្ទមក។

◈◈◈

ព្រីសាណាមិនបានទូរស័ព្ទមកអ្នកទេ ប៉ុន្តែបុរសឈ្មោះអារ៉េនបានទូរសព្ទមកអ្នក។គាត់សូមឱ្យអ្នកទៅភោជនីយដ្ឋាននៅយប់នោះដើម្បីសាកការងារ។គាត់ថាអ្នកគួរតែពាក់សំពត់ពណ៌ខ្មៅនិងអាវពណ៌សរនិងស្បែកជើងដែលប្រើទៅស្រួល ហើយថាអ្នកមិនគួរទៅយឺត។ អ្នកព្យាយាមអរគុណគាត់ប៉ុន្តែគាត់បានដាក់ទូរសព្ទចុះរួចទៅហើយ។

ល្អមែន!! អ្នកគិតថាអ្នកត្រូវតែប្រឹងឱ្យអស់សមត្ថភាពចំពោះឱកាសនេះ។

ឥឡូវអ្វីដែលអ្នកត្រូវការគឺសំពត់ពណ៌ខ្មៅនិងអាវពណ៌សរ ហើយស្បែកជើងដែលពាក់ទៅស្រួលជើង!

◈◈◈

នៅយប់នោះអ្នកទៅភោជនីយដ្ឋានក្នុងសំលៀកបំពាក់ថ្មី។ ភោជនីដ្ឋាននោះមានឈ្មោះថា "ដំរីខៀវ"។ ហើយអ្នកដឹងយ៉ាងឆាប់រហ័សថាវាជាភោជនីដ្ឋាន

មួយក្នុងចំណោមភោជនីដ្ឋានធំៗនិងមមាញឹកខ្លាំងបំផុតនៅក្នុងទីក្រុង។ ហេតុផលនោះគឺថាវាមានអាហារឆ្ងាញ់និងសេវាកម្មល្អ ហើយនឹងសមត្ថភាពអស្ចារ្យរបស់បុគ្គលិក។

អេរ៉េនដែលជាអ្នកទូរស័ព្ទមកអ្នក តាមការពិតជាអ្នកគ្រប់គ្រងនៅទីនោះសោះ។ គាត់មានចរិតស្ងៀមស្ងាត់តែហ្មត់ចត់។ នៅពេលគាត់ណែនាំពីការងារគ្រប់គ្នាស្ដាប់និងធ្វើតាមភ្លាមទោះជាគាត់មិនស្រែកដាក់ឬមានអាការៈខឹងសម្បារក៏ដោយ។ គាត់ខិតខំធ្វើការជាងអ្នកគ្រប់គ្នា គាត់ធ្វើការនាំមុខ ហើយអ្នកមានអារម្មណ៍ថាបុគ្គលិកធ្វើតាមគាត់គ្រប់ទីកន្លែង។

ពេលអ្នកមកដល់ គាត់កំពុងតែរវល់រៀបចំកន្លែងសម្រាប់ពេលល្ងាចខាងមុខនេះ ហើយគាត់មានពេលវេលាតិចណាស់សម្រាប់អ្នក។ គាត់មើលអ្នកលើក្រោមបន្តិចរួចក៏ត្រលប់ទៅធ្វើអ្វីដែលគាត់កំពុងធ្វើ ស្របពេលនោះដែរគាត់សួរអ្នកសំណួរខ្លះ។

"ដែលខ្លាចថាមានការងារច្រើនអត់?"

"អត់ទេ លោក"

"កុំហៅខ្ញុំលោក"ហៅខ្ញុំថា អេរ៉េន ចុះ" " តើអ្នកចេះធ្វើការជាក្រុមអត់?"

"ចាស លោក...អូ!!...អេរ៉េន"

"តើអ្នកអាចធ្វើអ្វីដែលគេប្រាប់បានអត់? មានន័យថាធ្វើបានយ៉ាងរហ័ស ហើយមានប្រសិទ្ធភាព"

"ចាស។អេរ៉េន"

"យើងនឹងអាចដឹងថាអ្នកអាចធ្វើវាបានឬអត់នៅយប់នេះ, ត្រូវអត់?"

បន្ទាប់មកគាត់ហៅអ្នករត់តុផ្សេងទៀតមកជិត។

"នាងត្រូវធ្វើការជាមួយ នីន នៅយប់នេះ។គាត់គឺជាម្នាក់ក្នុងចំណោមបុគ្គលិកល្អជាច្រើននាក់ផ្សេងទៀត។ នាងនឹងត្រូវធ្វើតាមអ្វីគ្រប់យ៉ាងដែលគាត់ប្រាប់។ យល់ទេ?"

អ្នកងក់ក្បាល

"មានសំណួរអ្វីអត់?'"

អ្នកគ្រវីក្បាល

"ល្អណាស់! ចាប់ផ្ដើមធ្វើការទៅអញ្ចឹង។"

ស្របពេលអ្នកចាប់ផ្តើមធ្វើការជាមួយ នីន អ្នកដឹងខ្លួនថាអ្នកមិនបានដឹងសូម្បីតែពីប្រាក់កម្រៃដែលអ្នកនឹងទទួលបាន។

វាជារាត្រីមួយដ៏រវីរក់បំផុតដែលអ្នកធ្លាប់ជួប។ ចាប់ពីក្បាលល្ងាចដល់បន្ទាប់ពាក់កណ្តាលយប់ អ្នករត់ចុះឡើងពីផ្ទះបាយទៅកន្លែងទទួកភ្ញៀវ កត់ត្រាការកម្មង់អាហារ លើកអាហារ និងលាងចាន។ អ្វីគ្រប់យ៉ាងដែល នីន ប្រាប់អ្នកឱ្យធ្វើអ្នកក៏ធ្វើវាភ្លាម។ អ្នកធ្វើខុសខ្លះ ប៉ុន្តែ នីន បានជួយកែភ្លាម។ អ្នក មានអារម្មណ៍ថាអេរ៉េនកំពុងតែមើលអ្នក។ គាត់ហាក់ជាចាំមើលអ្វីគ្រប់យ៉ាង ចង្អុលបាប្រប់បុគ្គលិកមើលអតិថិជន មើលថែរក្សាកន្លែងទាំងមូល គាត់ហាក់បីដូចជាក្បាលម៉ាស៊ីនដ៏ធំរបស់ភាជនីយដ្ឋាន។

បន្ទាប់ពីចប់ការងារ អ្នកមានអារម្មណ៍អស់កម្លាំងជាពន់ពេកស្ទើរមិនអាចកំរើកបាន។ ទើបតែពេលនេះទើបអ្នកដឹងថាជើងអ្នកឈឺដល់កំរិតណា។ រាត្រីនោះកន្លងផុតយ៉ាងរហ័សហើយស្រពិចស្រពិល តែអ្នកចូលចិត្ត។ អ្នកទទួលបានប្រាក់ឈ្នួល រាប់បញ្ចូលទាំងលុយទឹកតែដែលប្រមូលបានហើយបែងចែកទៅឱ្យបុគ្គលិកទាំងអស់។ វាជាចំនួនលុយដែលល្អគ្រប់គ្រាន់ សមនឹងតម្លៃការងារ៧ម៉ោង។

មុនពេលអ្នកចាកចេញអ្នកឮអេរ៉េនសួរនីនអំពីការងាររបស់អ្នក។ នីន ងក់ក្បាល ហើយអេរ៉េនហាក់ដូចជាពេញចិត្ត។ គាត់ក៏ងាក់មករកអ្នក។

“តើថ្ងៃស្អែកអ្នកអាចមកធ្វើការទៀតទេ?

“ចាស! លោក!”

“ហៅ ខ្ញុំថាអេរ៉េន!”

“ចាស! អេរ៉េន!”

អ្នកចាកចេញជាមួយនីននិងអ្នករត់តុផ្សេងទៀត។ នីនសួរចង់ដឹងអ្នកស្នាក់នោះឯណាហើយអ្នកបានប្រាប់គាត់ពីឈ្មោះសណ្ឋាគាររបស់អ្នក។ អ្នកក៏បន្ថែមទៀតថាអ្នកមិនអាចស្នាក់នៅទីនោះយូរទៀតទេពីព្រោះអ្នកមិនមានលទ្ធភាពឡើយ ។ អ្នកក៏និយាយជាមួយបុគ្គលិកដទៃទៀតយ៉ាងស្និទ្ធស្នាល អំពីបុគ្គលិកម្នាក់ដែលកំពុងរកមិត្តរួមបន្ទប់ជួល។ នីននិយាយថាគាត់នឹងប្រាប់ឱ្យអ្នកដឹងនៅថ្ងៃស្អែក។

មុនពេលអ្នកលាគាត់ អ្នកបានអរគុណគាត់ដែលបានជួយអ្នកនៅល្ងាចនោះ។

គាត់តបថា “មិនអីទេ តែកុំធ្វើឱ្យខ្ញុំអស់សង្ឃឹមណា”

អ្នកនិយាយថា “ខ្ញុំមិនធ្វើឱ្យបងអស់សង្ឃឹមឡើយ”

◈◈◈

យប់ទីពីរបស់អ្នកនៅភោជនីយដ្ឋាន “ដំរីខៀវ” គឺរវល់ជាងយប់ទីមួយ។ ឥឡូវនេះជាចុងសប្តាហ៍ ហើយកន្លែងនោះកំពុងប្រញាប់ដៃជើង។ មានបុគ្គលិកបន្ថែមធ្វើការហើយមានគេប្រាប់ឱ្យអ្នកធ្វើការឱ្យបានលឿនជាងយប់មុន។

ពាក់កណ្តាលល្ងាចនោះ នៅពេលអ្នកធ្វើដំណើរត្រលប់ទៅផ្ទះបាយវិញ អ្នកមានអារម្មណ៍ថាទូរសព្ទរបស់អ្នកញ័រ។ អ្នកមើលអេក្រង់ទូរស័ព្ទមួយភ្លែត។ នោះគឺណារិន។ អ្នករុញវាបន្តិចហើយឆ្លើយតប ”សូរស្តី។ ខ្ញុំមិនអាចនិយាយបាននៅពេលនេះទេ”

“ប្អូននៅឯណា?”

“ខ្ញុំនៅឯណា? បងនៅឯណា?”

“បងពិតជាសុំទោស។ បងអាចពន្យល់ប្អូនបាន។ គ្រាន់តែប្រាប់បងសិនមកថាតើបងអាចរកប្អូនដោយវិធីណា?

ពេលនេះស្រាប់តែអ្នកឃើញនីនកំពុងសម្លឹងមើលមកអ្នក។ គាត់គ្រវីក្បាលហើយចង់បង្ហាញថាអ្នកគួរតែឈប់និយាយទូរស័ព្ទភ្លាម។

អ្នកនិយាយ “ខ្ញុំត្រូវទៅហើយ” “ខ្ញុំនៅដំរីខៀវ”

នីនហុចអាហារឱ្យអ្នក។ “ប្រសិនអេរ៉េនឃើញដូចនេះ ឯងនឹងត្រូវបញ្ឈប់ពីការងារហើយ។ យល់អត់?”

“ចាស! សុំទោស”។ និយាយរួចអ្នកក៏ត្រលប់ទៅកន្លែងទទួលភ្ញៀវវិញ។

◈◈◈

ទម្រាំអ្នកចេញពីធ្វើការនៅយប់នោះគឺម៉ោងជាង២យប់បាត់ទៅហើយ។អ្នកចាកចេញពីភោជនីយដ្ឋានជាមួយនីននិងក្មេងស្រីផ្សេងទៀត។ហើយអ្នកដែលអ្នកឃើញដំបូងគេគឺណារិន។ពេលអ្នកផ្សេងដឹងថាគេកំពុងចាំអ្នក ពួកគេក៏នាំគ្នាសើច។

នៅពេលនោះអ្នកមិនច្បាស់ថាអ្នកគួរនិយាយជាមួយគាត់ឬអត់។

អ្នកសួរថា”បងបាត់ទៅណា?”។ នៅពេលនោះភាពមួរម៉ៅតាមសម្លេងរបស់អ្នកបានសម្តែងចេញយ៉ាងច្បាស់។ អ្នកនិយាយបន្តថា ”ខ្ញុំបានទូរស័ព្ទទៅអ្នក។ ព្រមទាំងផ្ញើសារផងដែរ!”



“បងដឹង។ តែស្ដាប់បងសិន។ ឱ្យបងសុំទោស។ បងអាចពន្យល់បាន”

អ្នកបន្តដើរ ហើយគាត់ឃើញថាអ្នកមិនសប្បាយចិត្តដល់កំរិតណា។ ទីបំផុតគាត់ក៏រត់មកចំពីមុខអ្នក ដូច្នេះអ្នកក៏ឈប់។ គាត់និយាយថា ”សូមអង្វរ!” ”ស្ដាប់បងសិន។”

អ្នកឈប់ហើយស្ដាប់គេពន្យល់

គេនិយាយថា” ដំបូងបងចង់ប្រាប់ថាឡានដែលបងបើកទៅយកប្អូននោះមិនមែនឡានបងទេ”

អ្នកនិយាយថា “ល្អហើយ ខ្ញុំពិតជាមានអារម្មណ៍ធូរទ្រូងតិច”

គាត់ញញឹមបន្តិច ប៉ុន្តែស្នាមញញឹមគាត់បាត់ទៅវិញពេលគាត់ឃើញអ្នកអត់ញញឹម។

“បងខ្ចីឡាននោះពីមិត្តរបស់បង។ ហើយបងគិតថាឡាននោះធ្វើឱ្យប្អូនមានអារម្មណ៍ស្ញប់ស្ញែងចំពោះបង។ ម្យ៉ាងទៀតបងភ្លេចទូរសព្ទរបស់បងក្នុងឡានោះ ហើយមិត្តបងបានចេញក្រៅក្រុងដើម្បីបំពេញការងាររបស់គេ។ បងទើបតែទៅ

យកទូរសព្ទរបស់បងមកវិញនៅថ្ងៃនេះទេ។

អ្នកសម្លក់គាត់ហើយនិយាយថា "បងគិតថាខ្ញុំជឿការដោះសាអញ្ចឹងដែរ?"

"ពិតមែនណា! បងមិនអាចទូរសព្ទទៅប្អូនវិញព្រោះលេខទូរស័ព្ទរបស់ប្អូនគឺនៅក្នុងទូរសព្ទនោះ។ ដូច្នេះបងក៏ទៅកន្លែងដែលប្អូនស្នាក់នៅប៉ុន្តែប្អូនចេញទៅបាត់។ បន្ទាប់មកបងក៏ទៅរោងចក្រហើយពួកគេថាប្អូនចាកចេញហើយ។ ខ្ញុំមិនអាចធ្វើអ្វីទាំងអស់គឺមានតែចាំយកទូរស័ព្ទមកវិញ។

អ្នកសួរថា "បងមករកខ្ញុំ?"

គេងក់ក្បាលហើយនិយាយថា "បាទ!"

អ្នកនិយាយនិងញញឹមដាក់គាត់ជាលើកដំបូងនាល្ងាចនោះ

"ល្អហើយអញ្ចឹង"

"ឥឡូវអ្នកធ្វើការនៅភោជនីយដ្ឋាន ដំរីខៀវ?"

"ចាស!"

"ឡូយតើ!"

"កន្លែងហ្នឹងល្អ"

អ្នកទាំងពីរមើលគ្នាទៅវិញទៅមកមួយស្របក់ បន្ទាប់មកគេចាប់ដៃអ្នក។ "និយាយអញ្ចឹងអូនអនុញ្ញាតឱ្យបងជូនទៅដើរលេងទៀតអត់?"

អ្នកនិយាយទាំងញញឹម "ប្រហែលបាន" "តែខ្ញុំមិនច្បាស់ថាយប់ណាបានទំនេរទេ"

គាត់និយាយថា "ខ្ញុំនឹងចាំរហូតដល់ពេលណាអ្នកទំនេ" "យើងប្រហែលជាត្រូវជិះឡានក្រុង។ បានអត់?"

អ្នកញញឹមនិងងក់ក្បាល "ខ្ញុំសាំនឹងជិះឡានក្រុងទៅហើយ"

◈◈◈

៦ខែក្រោយមក អ្នកនិយាយទូរស័ព្ទជាមួយម្តាយរបស់អ្នក។

"ម៉ែទទួលបានលុយខ្ញុំផ្ញើរទៅឬនៅ?"

"ពួកយើងទទួលបានហើយ។ អរគុណហើយកូន!! លុយទាំងនោះពិតជាធ្វើឱ្យរឿងគ្រប់យ៉ាងប្រែប្រួល "

“ចាសម៉ែ!! ចាំលើកក្រោយកូនផ្ញើរទៀត។ ចុះពុកម៉េចទៅហើយម៉ែ?”

“មិនអីទេកូន!! តែឥឡូវមិនដែលឃើញលោក.......មកផ្ទះយើងទេ។ កូនដាក់ឈ្មោះគេថាម៉េច?”

អ្នកនិយាយទាំងសើច “លោកស្នេកគីណាម៉ែ”

“អរគុណព្រះដែលលោកស្នេកគីឈប់ទៅផ្ទះយើង”

“ម៉ែ!! ពួកយើងនឹងទៅលេងផ្ទះនៅនៅចុងឆ្នាំនេះ”

“កូននិយាយថាពួកយើងហ្អេស?”

អ្នកនិយាយទាំងសើចថា “ចាស! កូននិយាយថាពួកយើង។”

“កូននិយាយមែនទែន?”

“ខ្ញុំអត់ដឹងទេ ម៉ែ!!! ចាំមើលសិន...អញ្ចឹងខ្ញុំត្រូវទៅធ្វើការហើយ។”

ផ្ញើក្ដីស្រលាញ់របស់ខ្ញុំទៅស៊ីតា និងពុកផង។ កូនស្រលាញ់ម៉ែ។ កូនជំរាបលា។

◈◈◈

អ្នកបានធ្វើការនៅទីក្រុងបានជាងមួយឆ្នាំហើយ នៅពេលអ្នកបានទទួលបានស្រោមសំបុត្រក្នុងប្រអប់សារដែល មានកាតអញ្ជើញដែលបានរចនាយ៉ាងស្រស់ស្អាត អ្នកក៏ញញឹម។




នៅលើខ្នងសំបុត្រមានអក្សរគូសខ្មៀករបស់ស្វរិយាដែលនិយាយ ”មុខដំណែងជាដៃគូររកស៊ី គឺនៅទំនេរនៅឡើយ។ ហាស ហា! ដាក់ពាក្យដោយផ្ទាល់ឱ្យឆាប់ៗមក ☺”

◈◈◈

ណារិនសួរដោយចង្អុលតាមកញ្ចក់រថយន្តថា “ផ្លូវមួយណា ?” ផ្លូវនៅក្នុងភូមិអ្នកមិនសូវមានភ្លើងដាក់តាមដងផ្លូវច្រើននោះទេ អញ្ចឹងហើយផ្លូវទាំងអស់មើលទៅដូចគ្នាពេលយប់។

អ្នកនិយាយព្រមទាំងចង្អុលទៅផ្លូវថា “នៅទីនោះ! តាមផ្លូវមួយនេះ! អ្នកស្ទើរតែមិនជឿថាអ្នកមកឃើតដល់ថ្នាក់នេះ”

ណារិនជាន់ហ្វ្រាំង ថយក្រោយ ហើយអែបចូលកៀនផ្លូវ។

អ្នកស្រែកថា “នៅទីនោះ!” ”ចតនៅទីណាក៏បាន នៅតាមនេះ”

នៅខាងមុខអ្នកឃើញឃីហោដែលមានភ្លើងភ្លឺៗ *ហាងលក់ទឹកដោះគោនិងទឹកឃ្មុំ*អមដោយសេវាកម្មអ៊ីនធឺណិត។ ណារិនចតឡាន ហើយអ្នកទាំងពីរចេញក្រៅ។

មានមនុស្សជាច្រើននៅទីនោះ ហើយហៀរមកថ្នល់ទៀត។ អ្នកដើរក្នុងលក្ខណៈគួរសមកាត់ហ្វូងមនុស្ស រហូតអ្នកអាចចូលតាមទ្វារ។ អ្នកមកដល់ទាន់ពេលល្មមនៅពេលថៅហ្វាយក្រុងកាត់ខ្សែបូនិងប្រកាសការបើករបស់មុខជំនួញនេះ។ អ្នកគ្រប់គ្នាទះដៃអបអរសាទរ។ នៅក្បែរថៅហ្វាយក្រុង អ្នកឃើញសូរិយាដែលពោរពេញទៅដោយមោទនភាព។ ពេលដែលនាងឃើញអ្នក នាងស្រែកហើយប្រញាប់ប្រញាល់ដើរសំដៅមករកអ្នក។

គាត់និយាយព្រមទាំងអោបអ្នក “យើងស្មានថាឯងមិនបានមកទេ!”

“សុំទោសណាសំលាញ់!!ស្ទះខ្លាំងនៅច្រកព្រំដែន!អបអរសាទរ!ហាងនេះមើលទៅអស្ចារ្យណាស់!”

“អរគុណ!!!! ហាងនេះទាមទារនូវការខិតខំជាច្រើន។ឯងមកអត់ទាន់សុន្ទរកថារបស់ខ្ញុំ។ យើងក៏បានអរគុណឯងដែរ”

“អរគុណរឿងអ្វី ?”

“អរគុណចំពោះការជួយយើងតាំងពីដើមរៀងមក។ ឯងមានចាំកាលពីថ្ងៃដែលយើងនៅផ្សារទេ ?

អ្នកនិយាយទាំងសើចថា “ពេលដែលយើងរកលុយ!”

សូរិយានិយាយថា ”ឥឡូវមើលមកអ្នកវិញ” “ជំនួយការអ្នកគ្រប់គ្រង ?ខ្ញុំពិតជាមានមោទនភាព

ចំពោះអ្នកណាស់"

"គ្មានរឿងទាំងនោះនឹងកើតឡើងទេ បើគ្មានឯង"

"និយាយឥតបានការ!"

"ខ្ញុំនិយាយពិតមែន!បើគ្មានឯង ប្រហែលជាយើងដើរផ្លូវខុសបាត់ទៅហើយ!!!"

សូរិយានិយាយមកអ្នកតែសំដៅទៅណារិនដែលកំពុងតែនិយាយគ្នាជាមួយអ្នកជិតនោះថា"មើលទៅឯងដូចជាជ្រើសរើសបានល្អដល់ហើយ"រើសដោយខ្លួនឯងមែនអត់? ហើយម៉េចដែរ?"

អ្នកញញឹមហើយនិយាយថា "មានអីល្អតើ! ចុះឯងវិញហ្នំ?"

"មានអីល្អតើ" សូរិយាតប

សូរិយាចង់សំដៅទៅបុរសរាងសង្ហានៅក្បែរនោះ គេជាអ្នកចាក់តន្ត្រីហើយពិធីជប់លៀងក៏ចាប់ផ្តើមឡើងនៅជុំវិញអ្នក។

សូរិយាមកជិតអ្នកហើយនិយាយថា "តោះរាំអត់?"

អ្នកមើលទៅណារិន "ខ្ញុំនឹងប្រឹងឱ្យអស់ពីសមត្ថភាព។ គាត់មិនមែនតែងតែអញ្ជឹងនោះទេ..."

សូរិយាស្រែកថា "ទេ!" យើងចង់និយាយថាទៅរាំអត់?"

អ្នកញញឹមហើយចាប់នាំគាត់ទៅកន្លែងរាំ។ អ្នកមានអារម្មណ៍ថាពេលវេលាហាក់ដូចជាដើរលឿនណាស់។

**ចប់**

# ក្រោកឈរដើម្បីតស៊ូ



នៅព្រលឹម អ្នកទៅកសិដ្ឋានលោកពូសំរិន និងមីងជា។ អ្នកដឹងថាសូរិយានៅទីនោះដើម្បីជួយរឹតទឹកដោះគោពួកគាត់។ ហើយអ្នកចង់ទៅឱ្យទាន់ពេលដែលពួកគេនៅជុំគ្នា។

អ្នករកឃើញថាពួកគេនៅក្រោល។ ពួកគេទើបតែរឹតទឹកដោះគោរួច ហើយអង្គុយជុំវិញលើកៅអីផឹកតែ។ លោកពូវិទូដែលជាអ្នកចិញ្ចឹមឃ្មុំក៏នៅទីនដែរ។ មើលទៅគាត់ទើបតែយកទឹកឃ្មុំបានពីបីក្រឡ។

អ្នកប្រកាសប្រាប់អ្នកទាំងអស់គ្នាថា ”ខ្ញុំបានសម្រេចចិត្តថានឹងនៅទីនេះ” សូរិយាលោតមកអោបអ្នក។

នាងនិយាយថា“នេះជាជម្រើសដែលគ្មានថ្ងៃធ្វើឱ្យឯងស្ដាយក្រោយឡើយ” “ ពួកយើងនឹងធ្វើឱ្យការរកស៊ីនេះរីកចំរើន!”

អ្នកក៏អាចមើលឃើញថាលោកពូសំរិន និងអ្នកមីងជារីករាយនឹងការជ្រើសរើសរបស់អ្នកដល់កម្រិតណា។ស្របពេលនោះដែរលោកតាវិច្ឆូក៏សួរថាមានរឿងអ្វីកើតឡើង។ លោកពូសំរិននិយាយពន្យល់គាត់ឮៗដូច្នេះ ទើបគាត់អាចឮបាន។

អ្នកអង្គុយជាមួយពួកគេ និងទទួលយកទឹកតែពីអ្នកមីងជាដោយលក្ខណៈសម្ដែងការដឹងគុណ

“ឥឡូវខ្ញុំត្រូវរកវិធីដើម្បីតស៊ូការរៀនមួយឆ្នាំទៀត”

មីងជានិយាយថា“រៀនចប់ជារឿងសំខាន់ព្រោះថាការអប់រំនឹងផ្ដល់ជម្រើសដល់ក្មួយនៅពេលក្រោយ”

អ្នកនិយាយ និងងក់ក្បាលដើម្បីគ្រាំទ្រថា “មីងនិយាយត្រូវ តែកង្វល់របស់ខ្ញុំតែម្យ៉ាងគឺគ្រួសារខ្ញុំ។ ពួកយើងត្រូវតែខិតខំរកប្រាក់ដើម្បីសងបំណុល។ ខ្ញុំច្បាស់ថាពូកយើងនឹងអាចដោះស្រាយរឿងនេះបាន”

សារជាថ្មីម្តងទៀត លោកតាវិច្ឆសូមឱ្យលោកពូសំរិនជួយពន្យល់អ្វីដែលបាននិយាយ។

◈◈◈

ថ្ងៃបើកបវេនកាលចុងក្រោយរបស់អ្នកដូចដែលអ្នកបានរំពឹងទុក។ តែក៏មានផលវិបាកចាប់ផ្តើមកើតមានឡើងផងដែរ។ អ្នកដឹងថាអ្នកត្រូវខំរៀននៅឆ្នាំនេះ ប៉ុន្តែវាពិបាកក្នុងការផ្តោតអារម្មណ៍ព្រោះតែអ្នកគិតពីរឿងគ្រប់យ៉ាងដែលកើតមាននៅផ្ទះរបស់អ្នក។

អ្នកនៅតែធ្វើការជាប្រចាំថ្ងៃនៅ កន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំ ហើយសូរិយាផ្តល់ម៉ោងធ្វើការបន្ថែមដើម្បីឱ្យអ្នកអាចរកចំណូលបន្ថែម។ ការរកស៊ីនោះមានការរីកចម្រើនយឺត ហើយអ្នកឱ្យប្រាក់ដែលអ្នករកបានទាំងអស់ទៅម្តាយអ្នកដើម្បីដោះបំណុល។ បើទោះជាអ្នកឱ្យប្រាក់គាត់ទាំងអស់ ក៏ការសងប្រចាំខែនៅតែមិនគ្រប់គ្រាន់ឱ្យលោកស្នេកគីពេញចិត្តដែរ។ ពេលខ្លះ គាត់ផ្តល់យោបល់ឱ្យម្តាយអ្នកលក់ផ្ទះ។ នេះជាការគិតមួយដែលធ្វើម្តាយអ្នកក្រៀមក្រំ។ ម្តាយអ្នកមិនដែលនិយាយរឿងនេះនៅពេលឪពុកអ្នកនៅក្បែរឡើយ។ អ្នកមិនហ៊ានគិតឡើយថាឪពុកអ្នកនឹងមានប្រតិកម្មយ៉ាងណានោះទេ ជាពិសេសផ្ទះនោះជាកម្មសិទ្ធរបស់គ្រួសារជាច្រើនជំនាន់។

ស្ទើររាល់យប់អ្នកព្យាយាមមកផ្ទះយឺតតាមដែរអាចធ្វើទៅបានដើម្បីឱ្យប្រាកដចិត្តថាគាត់បានសម្រាន្តលក់ហើយ។

អ្នកគិតថាវាស្ទើរតែមិនអាចទៅរួចក្នុងការធ្វើកិច្ចការសាលានៅពេលគាត់មិនទាន់សម្រាន្តលក់។ជានិច្ចកាល នៅពេលសូរិយាកំពុងធ្វើការនៅខាងមុខអ្នកតែងតែធ្វើកិច្ចការសាលានៅពីក្រោយកន្លែងលក់ទឹកដោះគោ និងទឹកឃ្មុំ។

ការរំខានដែលមាននៅក្នុងផ្សារ គឺល្អជាងការរំខានពេលដែលឪពុកអ្នកស្រែក។

បន្ទាប់មកនៅពេលអ្នកមិនសូវបានរំពឹងទុក គ្រប់យ៉ាងក៏បានផ្លាស់ប្តូរ។

◈◈◈

ថ្ងៃមួយនៅរដូវរងារ នៅពាក់កណ្តាលឆ្នាំសិក្សា អ្នក និងសូរិយាឈរនៅក្រៅថ្នាក់ ហើយពេលនោះមានមិត្តរួមថ្នាក់អ្នកម្នាក់ឈ្មោះគីរី មកនិយាយលេងជាមួយអ្នកទាំងពីរ។

គេនិយាយមកអ្នកថា “ខ្ញុំមិនដឹងថាសោះថាឪពុកអ្នកត្រលប់ទៅនេសាទត្រីវិញ”

ដំបូងឡើយអ្នកមិនយល់សោះថាគាត់ចង់និយាយពីអ្វីសោះ

"ឪពុកខ្ញុំ?"

គីរីឃើញអ្នកដូចជាភ្ញាក់ផ្អើលក៏និយាយថា៖

"អូ! ខ្ញុំឃើញគាត់មុននេះ គាត់កំពុងរៀបចេញទូក"

"ឪពុកខ្ញុំ?នៅទន្លេ?" "ហាក់បីជាមានស្នូរប្រកាសអាសន្នឮឡើងក្នុងក្បាលរបស់អ្នក"

គីរីងក់ក្បាល ហើយនិយាយថា"ខ្ញុំចាប់អារម្មណ៍ព្រោះគាត់បានយកដុំថ្មពីរបីដំទៅជាមួយផង។ គាត់ធ្វើបែបនេះធ្វើឱ្យខ្ញុំគិតថាមិនសូវស្រួលសោះ"

"ដុំថ្ម?"

ការប្រកាសអាសន្នក៏បានផ្ទុះឡើង។ អ្នកទុកកាបូបចុះ ហើយរត់។ នៅពេលអ្នកមកដល់ទន្លេ គ្មានសញ្ញារបស់ឪពុកអ្នកនៅក្បែរទូកឡើយ។ នៅលើទន្លេ អ្នកឃើញទូកពីរបី ប៉ុន្តែអ្នកពិបាកមើលថាអ្នកណាខ្លះនៅលើទូក។ អ្នកក៏ប្រញាប់សំដៅទៅអ្នកនេសាទផ្សេងទៀត។

"សូមមេត្តាជួយខ្ញុំផង! ឪពុកខ្ញុំនៅទីនោះ។ គាត់កំពុងតែមានគ្រោះថ្នាក់។" ខ្ញុំគិតថាគាត់តែនៅលើក្នុងទូកមួយក្នុងចំណោមទូកទាំងនោះ!"

អ្នកនេសាទម្នាក់នោះអាចមើលដឹងថាអ្នកស្លន់ស្លោដល់កំរិតណា ហើយគាត់ក៏យល់ព្រមជួយ។ សូរិយាក៏បានមកដល់ ហើយអ្នកទាំងពីរក៏ឡើងជិះកាណូតនោះទៅ។ អ្នកនេសាទនោះបានរុញកាណូតចេញពីច្រាំងឡើងជិះកាណូត ហើយក៏បញ្ឆេះម៉ាស៊ីនចេញដំណើរ។

អ្នកស្រែកខ្លាំងពេលជិះកាត់ទន្លេ ចំណែកល្បឿនកាណូតវិញគឺបើកក្នុងល្បឿនលឿនខ្លាំងសម្បើមណាស់។

នៅពេលអ្នកចូលជិតដល់ទូកដំបូងអ្នកនេសាទក៏មើលតាមសំណាញ់គាត់។ វាមិនមែនជាទូក ឪពុកអ្នកទេ។អ្នកក៏ធ្វើដំណើរទៅមុខទៀត។មានទូកមួយទៀតនៅខាងមុខ ហើយអ្នកនេសាទនោះក៏បើកសំដៅទៅកាន់ទូកនោះ។

ពេលអ្នកមកកាន់តែជិតទូកទីពីរនេះ អ្នកមានអារម្មណ៍កាន់តែហេងហាង។ អ្នកអត់មានឃើញនរណាម្នាក់នៅលើទូកនោះទេ។ ប្រហែលជាពួកគេនៅខាងក្រោម?អ្នកព្យាយាមអើតមើល ហើយយកដៃគ្របមុខដើម្បីបាំងពន្លឺទឹក នៅពេលអ្នកមកក្បែរទូក អ្នកក៏ទ្រហោយំ។ ភាពភ័យខ្លាចរបស់អ្នកគឺបានបង្ហាញឡើង។ ទូកនោះទទេស្អាត។ គ្មានសូម្បីតែសំណាញ់។

“ឪពុកខ្ញុំឈឺមែន។ ប៉ុន្តែនេះមិនមែនជាហេតុផលដែលអាចឱ្យគាត់ធ្វើអត្តឃាតបានឡើយ។ ហេតុផលធំបំផុតនោះគឺថាគាត់ឈឺចិត្តដែលគាត់មិនអាចមើលការខុសត្រូវគ្រួសារគាត់បាន។ គាត់អាច ឃើញអ្វីដែលគ្រួសារបានឆ្លងកាត់ ប៉ុន្តែគាត់មានអារម្មណ៍តែលតោលដែលមិនអាចជួយអ្វីបាន។ ខ្ញុំយល់ថាក្នុងនាមជាប្តីឬឪពុក វាគ្មានអារម្មណ៍អ្វីដែលពិបាកជាងនេះនោះទេ។

អ្នកអានពាក្យពីក្រដាស់ឮៗ។ ក្នុងសាលគឺពេញដោយមនុស្សដែលវាអាចផ្ទុកបាន។ អ្នកភូមិទាំងអស់ប្រាកដជានៅទីនោះ។ មានថែមទាំងអ្នកឈរនៅពីក្រោយ។ នៅជួរខាងមុខម្តាយរបស់អ្នកជូតទឹកភ្នែកស្របពេលគាត់លួងស៊ីតា។ លោកពូសំរិន អ្នកមីងជា និងសូរិយាគឺអង្គុយនៅជាប់នោះ។ អ្នកក៏ឃើញលោកតាវិធូដែលអង្គុយក្បែរខាងក្រោយ។

“ពួកយើងមិនច្បាស់ថាអនាគតនិងរៀបចំអ្វីខ្លះចំពោះពួកយើងទេ”។ អ្នកអានបន្តថា “ប៉ុន្តែមានរឿងមួយដែលខ្ញុំប្រាកដចិត្តគឺគ្រប់គ្នាប្រាកដជានឹងចងចាំខ្ញុំ។” “ខ្ញុំប្តេជ្ញាថាមានអ្វីមួយវិជ្ជមាននឹងកើតឡើងពីសោកនាដកម្មមួយនេះ។” “ខ្ញុំមិនដឹងថាវាជាអ្វីនៅឡើយទេ ប៉ុន្តែប្រហែលជាមានវិធីមួយដើម្បីទប់ស្កាត់អ្នកផ្សេងកុំឱ្យឆ្លងកាត់អ្វីដែលយើងឆ្លងកាត់។” “វានោះគឺសេចក្តីសង្ឃឹម។ “ អរគុណអ្នកទាំងអស់គ្នាដែលបានមកចូលរួមពិធីនេះ។” “ពុកពិតជាសាទរណាស់”

នៅខាងក្រៅសាល មានមនុស្សជាច្រើនសំដៅមកអ្នកនិងសំដែងការអានិតអាសូរ។ ម្នាក់ក្នុងចំណោមមនុស្សទាំងអស់គឺស្ត្រីម្នាក់ឈ្មោះអក្ខរាដែលអ្នកភូមិដែលអ្នកស្គាល់មិនសូវជិតដិត។ គាត់ចាប់ដៃអ្នកនិងនិយាយក្នុងសម្លេងស្រទន់។

គាត់និយាយថា “អរគុណ” “សម្តីរបស់ឯងពិតជាមានន័យដ៏ជ្រាលជ្រៅចំពោះគ្រួសារខ្ញុំណាស់។ លក្ខខណ្ឌជីវិតយើងគឺប្រហាក់ប្រហែលគ្នា ហើយពួកយើងក៏បួងសួងសុំអ្វីមួយដែលយើងអាចធ្វើបាន។

អ្នកចង់សួរគាត់បន្ថែមប៉ុន្តែមានមនុស្សផ្សេងទៀតនៅចាំជាជួរដើម្បីស្វាគមន៍អ្នកហើយអ្នកឃើញថាគាត់ក៏មិនមានផាសុខភាពក្នុងការនិយាយវាក្នុងចំណោមមនុស្សដែរ។ គាត់ច្របាច់ដៃអ្នកម្តងទៀតរួចចាកចេញ។

មនុស្សម្នាក់ទៀតដែលដើរសំដៅមកកាន់អ្នកគឺលោកតាវិធូ។ គាត់កាន់ដៃអ្នកដាក់ក្នុងដៃដ៏ស្វិតជ្រីជ្រួញរបស់គាត់ហើយនិយាយតិចៗ សំដែងភាពសោកស្តាយរបស់គាត់។អ្នកឃើញថាគាត់មានអ្វីមួយចង់និយាយប៉ុន្តែក្នុងហេតុផលខ្លះធ្វើគាត់មានការរារែក។

ទីបំផុតគាត់មើលអ្នកហើយនិយាយថា ”កុំភ្លេចទៅរកពូណា”។

អ្នកងក់ក្បាលហើយប្រាប់គាត់ថាអ្នកនឹងធ្វើតាមគាត់។

◈◈◈

អ្នកក៏ទៅកន្លែងគាត់នៅថ្ងៃបន្ទាប់។ ជាធម្មតាគាត់មើលថែរក្សាសំបុកឃ្មុំ។ គាត់តែងតែនៅជាមួយសត្វឃ្មុំនៅផ្ទះ។

គាត់សួរថា “ឯងចង់ឃើញឃ្មុំខ្ញុំទេ?”

អ្នកនិយាយទាំងសភាពស្ទាក់ស្ទើរថា “ចាស”។ តែនេះមិនមែនជាអ្វីដែលអ្នកបានរំពឹងទុកនោះឡើយ។

គាត់និយាយទាំងញញឹមចេញធ្មេញថា “ កុំភ័យអី! ពូមានសំលៀកបំពាក់ការពារ ”

មួយសន្ទុះក្រោយមក អ្នកបានស្លៀកពាក់ការពារហើយដើរកាត់ហ្វូងឃ្មុំ។ លោកតាវិធូបង្ហាញអ្នកពីរបៀបយកក្រមួនចេញពីសំបុកឃ្មុំនិងយកទឹកឃ្មុំ។ អ្នកអាចមើលដឹង ថាគាត់ស្រលាញ់ឃ្មុំ ដល់កំរិតណាហើយអ្នកស្តាប់ពេលគាត់ពន្យល់លំអិតអំពីមួយណាជាឃ្មុំកម្មករ និងមួយណាជា ឃ្មុំសម្រាប់ការបន្តពូជ។ គាត់ក៏បានរៀបរាប់ពីវិធីឃ្មុំទាំងនោះសហការគ្នាក្នុងការធ្វើសំបុកដ៏ល្អមួយ។

គាត់និយាយថា “មនុស្សមួយចំនួនយល់ថាខ្លួនគេសំខាន់ណាស់”។ “ក៏ប៉ុន្តែមនុស្សយើងមិនអាចរស់ដោយគ្មានសត្វតូចៗទាំងនោះទេ។គ្មានអ្វីអាចរស់ដោយគ្មានលម្អងឃ្មុំបានឡើយ។”

នៅពេលទឹកឃ្មុំបានប្រមូល លោកតាវិធូនាំអ្នកទៅផ្ទះ ទឹកឃ្មុំដែលជាកន្លែងគាត់ធ្វើការចំរាញ់យកទឹកឃ្មុំ។ នៅរសៀលនោះ គាត់ចម្រាញ់បានទឹកឃ្មុំចំនួន ១០ក្រឡុសម្រាប់ដាក់លក់នៅលើទីផ្សារ។

គាត់និយាយថា “នេះសម្រាប់គ្រួសាររបស់ឯង” “ឯងអាចមកយកទៀតនៅរាងរាល់ថ្ងៃពុធ”

អ្នកនិយាយថា “លោកតាវិធូ ” “ ខ្ញុំយកមិនបានទេ”

ប៉ុន្តែវិទូទទូច “កុំបារម្ភ។ ឯងត្រូវធ្វើការឱ្យពូ។ ពូចាស់ហើយ។ ពូត្រូវការអ្នកណាម្នាក់មកជួយពូ”

អ្នកក៏បានអរគុណគាត់ហើយនិយាយថាអ្នកនឹងមកជួបគាត់ទៀតនៅអាទិត្យក្រោយ។



បន្ទាប់មក នៅពេលអ្នកចាកចេញ គាត់ហៅអ្នកហើយនិយាយថា “ កុំភ្លេចអ្វីដែលឃ្មុំបង្រៀនក្មួយថ្ងៃនេះណា។ រួមគ្នាជាកម្លាំង។ សហការគ្នា”

ពេលដែលអ្នកមកដល់ពាក់កណ្ដាលផ្លូវត្រលប់ទៅផ្ទះ ទើបអ្នកយល់ពីអ្វីដែលលោកតាវិធូព្យាយាមចង់ឱ្យអ្នកយល់។ ប្រហែលអ្វីដែលគាត់ចង់និយាយនោះគឺថាប្រសិនបើអ្នកចង់ផ្ចាញ់លោកស្នេកគី ហើយចង់មានការផ្លាស់ប្ដូរអ្នកត្រូវតែពឹងអ្នកដទៃ។ អ្នកត្រូវតែចូលរួមជាមួយអ្នកណាដែលជិះទូកតែមួយ។ រួមគ្នាជាកម្លាំង។ អ្នកក៏គិតដល់អក្ខរាដែលជាស្ត្រីដែលមកជួបអ្នកបន្ទប់ពី បុណ្យសពឪពុកអ្នក។

◈◈◈

អ្នកមិនពិបាកនឹងរកស្ត្រីម្នាក់ដែលឈ្មោះអក្ខរាឡើយ ព្រោះភាគច្រើនអ្នកភូមិស្គាល់គ្នា។

អ្នកគោះទ្វារផ្ទះរបស់គាត់។ តែគ្មាននរណាឆ្លើយឡើយ។ មួយសន្ទុះក្រោយមក មានក្មេងស្រីម្នាក់ បើកទ្វារហើយហៅអ្នកចូលក្នុង។ ក្មេងនោះមានអាយុប្រហែលជាតិចជាងសុីតាមួយឆ្នាំ។ អ្នកគិតក្នុងចិត្តថាម៉េចក៏ក្មេងនោះមិនទៅ

សាលា។

នៅពេលដែលក្មេងនោះបើកទ្វារ នាងក៏បានហៅអ្នកឱ្យចូលផ្ទះ។ អ្នកស្ទាក់ស្ទើរនឹងចូលក្នុងផ្ទះ។

អ្នកនិយាយថា “សួរស្តី?”

ពេលនោះស្រាប់តែមាន សម្លងរបស់ក្មេងពីរបីនាក់ចេញមក។ ជាថ្មីម្តងទៀត អ្នកឆ្ងល់ថាហេតុអ្វីពួកគេមិននៅសាលារៀន ហើយអ្នកក៏សំគាល់ឃើញពីសភាពគួរឱ្យអាណិតរបស់សំលៀកបំពាក់របស់ពួកគេ។ ខ្លះចាស់ ខ្លះរហែក ខ្លះចង្អៀត។ នៅពេលអ្នកមើលជុំវិញផ្ទះ អ្នកឃើញថាគ្មានគ្រឿងសង្ហារឹម ឬកំរាលពូកទំនើបអ្វីទាំងអស់។

រំពេចនោះស្ត្រីឈ្មោះ អក្ខរាបានចេញពីបន្ទប់មួយក្នុងចំណោមបន្ទប់ទាំងនោះ ដោយកាន់ធុង និង អេប៉ុង។ គាត់មើលទៅមានការភ្ញាក់ផ្អើលដែលឃើញអ្នកឈរនៅទីនោះ។

”អ្នកនិយាយថា “សុំទោស “ខ្ញុំមិនគួរណាចូលក្នុងទេ”

អ្នកចាប់ផ្តើមដើរចេញប៉ុន្តែគាត់ឃាត់អ្នក។

គាត់និយាយថា “ឈប់សិន” “ចាំមួយភ្លែត”

គាត់ទៅបន្ទប់គាត់វិញហើយក៏ហៅអ្នកចូល។ នៅក្នុងបន្ទប់អ្នកឃើញគាត់មើលថៃ ស្ត្រីចំណាស់ម្នាក់ដែលមើលទៅខ្សោយ ដេកស្តូកស្តឹងនៅលើគ្រែ។

គាត់និយាយថា “នេះគឺម្តាយខ្ញុំ”

អ្នកនិយាយទៅស្ត្រីចំណាស់នោះ តែមិនដឹងថាគាត់ដឹងថាអ្នកមានវត្តមាននៅទីនោះឬក៏អត់ឡើយ។ អ្នកសម្លឹងមើលជុំវិញ ហើយឃើញថា ក្រៅពីគ្រែ គឺបន្ទប់នោះគ្មានអ្វីទាំងអស់។

◈◈◈

បន្ទាប់មក អ្នកដើរជាមួយអក្ខរា។ គាត់និយាយប្រាប់អ្នកថាវិធីតែមួយគត់ដែលគាត់អាចសន្ទនាគ្នាបាននោះគឺត្រូវចេញទៅក្រៅផ្ទះ។ អ្នកសួរអំពីគ្រួសារគាត់ហើយគាត់ក៏ប្រាប់អ្នកអំពីរឿងគ្រួសារគាត់។

វាជាដំណើររឿងមួយដែលមានភាពស្រដៀងជាច្រើននឹងរឿងអ្នក។ ដូចឪពុកអ្នកដែរ ប្តីគាត់បានជួបវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ។ គាត់ធ្លាប់ជាកសិករដែលខ្ចីលុយគេដើម្បីទិញពូជ និង ជី។ នៅពេលដំណាំ គាត់ខូចដោយសារភ្លៀង និង

ទឹកជំនន់ គាត់គ្មានជម្រើសក្រៅពីខ្ចីលុយបន្ថែម។ បន្ទាប់ពីរដូវដ៏អាក្រក់នោះ គាត់ដឹងថាគាត់ធ្លាក់ក្នុងរណ្ដៅមួយដែលគាត់មិនអាចងើបចេញបាន។ អ្នកដូចជាមិនភ្ញាក់ផ្អើលទេថាអ្នកដែលគាត់ឱ្យគាត់ខ្ចីលុយគឺលោកស្នេកគី។

ដោយមានកូន៥នាក់ និង ម្ដាយជរាម្នាក់នៅក្នុងបន្ទុក សំពោធលើប្ដីគាត់គឺកាន់តែធ្ងន់ឡើង។ គាត់បញ្ចប់ដោយការធ្វើចំណាកស្រុកដើម្បីរកការងារធ្វើហើយធ្វើការនៅលើទូកនេសាទត្រី។ដំបូងពួកគេទទួលបានលុយខ្លះពីគាត់ប៉ុន្តែក្រោយមកគ្មានលុយផ្ញើមកទៀត ហើយជាងមួយឆ្នាំហើយដែលស្ត្រីនោះមិនបានឮដំណឹងពីប្ដីគាត់។

បន្ទាប់មកមានដំណឹងដ៏មហាអាក្រក់មួយនោះគឺគាត់បានស្លាប់បាត់ទៅហើយ ជាក់ស្ដែងគឺស្លាប់ដោយសារជម្ងឺ បើទោះជាគ្មានគ្រូពេទ្យបានបញ្ជាក់។

អក្ខរាកប់សាកសពប្ដីគាត់ ហើយឥឡូវគាត់ស្ថិតនៅក្រោមការត្រួតត្រារបស់លោកស្នេកគី។ គាត់គ្មានមានលទ្ធភាពបញ្ជូលកូនទៅសាលាទេ។ គាត់បានប្រគល់ទ្រព្យសម្បត្តិស្ទើរតែទាំងអស់ទៅ ចងការគេដើម្បីយកលុយសងបំណុល។

គាត់និយាយផងជូតទឹកភ្នែកផងថា "មានថ្ងៃខ្លះ ខ្ញុំគិតថាខ្ញុំមិនអាចបន្តទៅមុខបានទៀតឡើយ" " ប៉ុន្តែនៅពេលខ្ញុំមើលមុខកូនៗខ្ញុំ..."

អ្នកចាប់ដៃគាត់និងនិយាយថាអ្នកគោរពគាត់ដល់កំរិតណា។ អ្នកដឹងពីសភាពដ៏លំបាករបស់គ្រួសារអ្នក ដូច្នេះអ្នកអាចបស្រមៃវាចេញថាវាទៅជាបែបណានៅពេលមានកូន៥ និងម្ដាយជរាម្នាក់ទៀតក្នុងបន្ទុក។

អ្នកផ្ដល់យោបល់ "ចុះហេតុអ្វីយើងមិនទៅជួបគាត់ ?"

អក្ខរាសួរថា "អ្នកណាគេដែរ ? អ្នកចងការម្នាក់នោះ ?"

អ្នកងក់ក្បាល" ពួកយើងអាចព្យាយាមនិយាយរកហេតុផលជាមួយគាត់"

អក្ខរាមើលទៅមិនប្រកដប្រជាសោះ។ "គាត់ជាមនុស្សពិបាកនិយាយគ្នាណាស់។ខ្ញុំបានសាករួចហើយ។"

ខ្ញុំដឹង... ចុះបើយើងទៅទាំងពីរអ្នក ? គួរសាកអត់ ?

"អ្នកដឹងថាអក្ខរាស្អប់គំនិតនេះ ប៉ុន្តែគាត់ដូចជាមិនមានជម្រើសផ្សេងទៀតទេ។

◈◈◈

នៅថ្ងៃបន្ទាប់ អ្នកទាំងពីរក៏ទៅការិយាល័យរបស់ លោកស្នេកគី ទាំង

ភិតភ័យ។ ឈ្មោះពិតគាត់គឺហ៊ុយ ហើយឈ្មោះហ៊ុយឥណទាននិងសេវាកម្មហិរញ្ញវត្ថុគឺនៅជាប់នឹងបង្អួចខាងមុខ ។

អ្នកទៅកន្លែងទទួលភ្ញៀវដែលកខ្វក់ហើយសួរអ្នកទទួលភ្ញៀវដែលមានសភាពធុញទ្រាំ ថាតើអ្នកអាចជួបលោកហ៊ុយបានទេ។ ស្ត្រីម្នាក់នោះស្ទើរតែមិនឆ្លើយតបអ្នកនៅពេលគាត់ងក់ក្បាលចង្អុលទៅទ្វារ។

នៅពេលអ្នកដើរចូលក្នុងការិយាល័យរបស់គាត់ លោកហ៊ុយងើបក្បាលពីតុមើលមកអ្នកក្នុងសភាពសង្ស័យ។ គាត់ដូចភ្ញាក់ផ្អើលនៅពេលឃើញអ្នកទាំងពីរនៅជាមួយគ្នា។

គាត់សួរ "បាទ?" " តើអ្នកទាំងពីរត្រូវការអ្វីដែរ?"

អក្ខរាសម្លឹងមកអ្នក។ វាហាក់បីដូចជាអ្នកត្រូវបានគេបោះឆ្នោតឱ្យក្លាយជាអ្នកនាំពាក្យ។

អ្នកនិយាយថា "អរគុណដែលអនុញ្ញាតឱ្យខ្ញុំអាចជួបអ្នក" "ពួកយើងសុំនិយាយជាមួយលោកបានដែរអត់?"

គាត់និយាយដោយគ្មានភាពអត់ធ្មត់ថា "ខ្ញុំកំពុងស្តាប់ហើយតើ"

អ្នកដកដង្ហើមធំ។ អ្នកនៅមិនទាន់ច្បាស់ថាអ្នកនឹងនិយាយពីអ្វី។

"លោកហ៊ុយ... វាទាក់ទងនឹងការខ្ចីលុយ។ ដូចលោកបានដឹងហើយពួកយើងទាំងពីរបានបាត់បង់បុរសក្នុងគ្រួសារដែលជាអ្នករកស៊ីចិញ្ចឹម..."

លោកហ៊ុយហាក់ដូចជាដឹងថាការសន្ទនានេះទៅជាយ៉ាងណា ហើយគាត់ប្រវីក្បាលគាត់

អ្នកបន្តថា "ការពិតនោះគឺថា ពួកយើងឥឡូវមានវិធីក្នុងការសងបំណុលអ្នក។ បើទោះជាពិបាកយ៉ាងណាក៏ពួកយើងនឹងព្យាយាម ។ ហើយបំណុលនេះបានបំផ្លាញគ្រួសាររបស់ពួកយើង។ តើលោកអាចផ្លាស់ប្តូរល័ក្ខខ័ណ្ឌនៃប្រាក់ជំពាក់នេះបានទេ? បែបបទនៃការរស់នៅរស់បានផ្លាស់ប្តូរ។ តើមានវិធីអ្វីដែលពួកយើងអាចសងប្រាក់អ្នកតិចជាងនេះ?"

លោកហ៊ុយសើចនៅពេលគាត់ឮសម្តីចុងក្រោយនេះ។

គាត់និយាយថា "សងតិចជាងហ្នឹង?"

គាត់និយាយតិចៗ ប៉ុន្តែអ្នកមានអារម្មណ៍ភ័យដែរដែលហាក់បីដូចជាមានភ្នំភ្លើងនៅខាងក្នុងខ្លួនគាត់ដែលរកកល់នឹងផ្ទុះ។ គាត់បន្តថា "តើអ្នកនិយាយពិត

មែនឬ? សូមឱ្យខ្ញុំពន្យល់អ្នករឿងមួយចុះ។ នេះជាការរកស៊ី។ នេះជាវិធីដែលអាចឱ្យខ្ញុំរស់បាន។ តើអ្នកគិតថាការរកស៊ីនេះស្រួលណាស់មើលទៅ? ជាពិសេសនៅពេលមានគ្រួសារដូចអ្នក ដែលមិនអាចសងលុយទាន់ពេលវេលា។ អ្នកគិតពីគ្រួសារអ្នក ចុះគ្រួសារខ្ញុំវិញនោះ? តើខ្ញុំអាចធ្វើឱ្យគ្រួសារខ្ញុំមានស្ថេរភាពយ៉ាងដូចម្តេចទៅ?"

អ្នកនិយាយបន្តថា "លោកហ៊ុយ ពួកយើងមិនបានមានន័យថាពួកយើងនឹងមិនសងលុយនោះទេ ពួកយើងគ្រាន់តែចង់និយាយថា..."

អ្នកនិយាយមិនទាន់ចប់ផង គាត់ក្រោកឈរ ហើយភ្នំភ្លើងក៏ផ្ទុះឡើង។

គាត់ស្រែក "ចេញ! ចេញពីការិយាល័យខ្ញុំភ្លាម!"

គាត់នាំអ្នកចេញក្រៅ ឆ្លងកាត់កន្លែងទទួលភ្ញៀវ ទៅដល់ដងផ្លូវ។

គាត់និយាយះថា "នៅពេលក្រោយបើខ្ញុំឃើញពួកឯងទៀត ខ្ញុំចង់ឃើញទាំងលុយរបស់ឯង។ យល់ឬទេ?"

គាត់សម្លក់មើលយើងអស់មួយស្របក់ រួចគាត់ក៏ដើរចូលក្នុងវិញទៅ។

អក្ខរាមើលទៅហាក់បីជារន្ធត់ ប្រៀបដូចជាមានគេបៀតបៀនរាងកាយគាត់អញ្ចឹង។

អ្នកក៏រាំងស្មារតី ហើយនិយាយ "មានរឿងអ្វីកើតឡើង?" រួចអ្នកដើរជុំវិញដើម្បីព្យាយាមសម្រេចចិត្តថានឹងត្រូវធ្វើអ្វីជាបន្ទាប់។ អ្នកអស់យោបល់ អ្វីដែលអ្នកកំពុងមានអារម្មណ៍នោះគឺកំហឹង និងការខកចិត្ត។

បន្ទាប់មកអ្នកក៏នឹកដល់គ្រួសាររបស់អ្នក។ នេះជាអ្វីដែលអ្នកធ្វើឡើងដើម្បីពួកគាត់។ តើខ្លួនអ្នកនឹងដើរចេញទាំងបែបនេះឬ? នៅពេលអ្នកបែរមុខមករកអក្ខរា នាងក៏បានឃើញការប្តេជ្ញាចិត្តដ៏មុតមាំក្នុងកែវភ្នែករបស់អ្នក។

អ្នកនិយាយថា"អត់ទេ។ រឿងនេះមិនត្រូវឱ្យចប់ទាំងអញ្ចឹងទេ។ ពួកយើងនឹងមិនបោះបង់ឡើយ។ បានអត់?"

◈◈◈

បន្ទាប់មកទៀត នាថ្ងៃដដែលនោះ អ្នកទូរស័ព្ទទៅសូរិយា។ នាងហាក់ដូចជាមានអារម្មណ៍ក្រៀមក្រំដូចអ្នកដែរ នៅពេលនាងបានស្តាប់ឮអ្វីដែលបានកើតឡើង។

នាងនិយាយថា "គាត់មិនសមធ្វើដាក់អ្នកអញ្ចឹងទេ។ តើគាត់គិតថាខ្លួនគាត់ជានរណា?"

អ្នកក៏ប្រាប់នាងបន្ថែមទៀតនូវអ្វីដែលអ្នកគិតចង់ធ្វើបន្ទាប់រួចអ្នកយល់ព្រមថានឹងជួបនាងនាពេលបន្តិចទៀត នៅក្លឹបយុវជន។

សូរិយានិយាយថា "ខ្ញុំនឹងទៅប្រមូលមិត្តផ្សេងទៀតឱ្យទៅជាមួយ"

◈◈◈

មានមិត្តប្រាំនាក់ដែលមកជាមួយ សូរិយានៅក្លឹបយុវជន ពួកគេពិតជាចង់ជួយអ្វីគ្រប់យ៉ាងដែលពួកគេអាចធ្វើបាន។ សំណួរដែលគួរសួរនោះគឺថា តើអ្វីទៅជាវិធីល្អបំផុតដើម្បីដោះស្រាយបញ្ហានេះ? មានការពិភាក្សាគ្នាជាច្រើនអំពីជម្រើសផ្សេងទៀត ប៉ុន្តែរហូតដល់ក្មេងស្រីម្នាក់ដែលមានឈ្មោះ កញ្ញានិយាយអ្វីមួយដែលធ្វើឱ្យអ្នកនឹកដល់គំនិតមួយផ្សេងទៀត រំពេចនោះ។

សូរិយាបានកំពុងនិយាយអំពីកម្រិតនៃផលប៉ះពាល់ដែលប្រាប់កម្ចីនោះបានធ្វើដល់គ្រួសារជាច្រើន ហើយកញ្ញាក៏បានឆ្លើយតបដោយនិយាយថា "ខ្ញុំជឿជាក់យ៉ាងច្បាស់ថាមានមនុស្សជាច្រើនក៏យល់ឃើញដូចយើងដែរ"

អ្នកនិយាយថា "មែនហើយ។ មនុស្សភាគច្រើននឹងយល់ស្របដូចនេះដែរ។ ហេតុអ្វីយើងមិនទៅសុំពួកគាត់? ហេតុអ្វីពួកយើងមិនចាប់ផ្ដើមដាក់ញត្តិ?"

អ្នកនិយាយថា "ញត្តិ? អ្នកចង់សំដៅទៅពាក្យស្នើដែលយើងចុះហត្ថលេខាដើម្បីគាំទ្រអ្វីមួយហ្នឹងមែនទេ?"

អ្នកងក់ក្បាល"ប្រាកដណាស់!"។អ្នកចាប់ផ្ដើមមានអារម្មណ៍រំភើបអំពីគំនិតនេះ។

សូរិយាសួរ "តើញត្តិនោះគួរសរសេរអំពីអ្វីទៅ?"

"សរសេររៀបរាប់នូវអ្វីដែលគ្រួសាររបស់ពួកយើងបានឆ្លងកាត់ និងអ្វីដូចជា "ប្រសិនបើអ្នកមិនយល់ស្របនឹងប្រភេទលក្ខខណ្ឌនៃការឱ្យខ្ចីលុយបែបនេះ សូមចុះហត្ថលេខានៅត្រង់នេះ"

សូរិយាដូចជាស្ថិតនៅក្នុងភាពស្រពិចស្រពិលដដែល រួចនាងសួរថា "តើយើងប្រគល់ញត្តិនេះទៅនរណាទៅ?"

អ្នកតបថា៖ ខ្ញុំអត់ដឹងទេ។ រួចចុះអភិបាលក្រុងវិញ?

◈◈◈

ម្នាក់ក្នុងចំណោមមនុស្សទាំងអស់នៅក្នុងក្រុម ហាក់ដូចជាមិនទាន់ជឿជាក់លើគម្រោងនេះនៅឡើយទេ រួចគាត់សួរថា "តើអ្នកមិនគិតថា អ្នកចងការម្នាក់នោះ នឹងផ្ដោតអារម្មណ៍ទៅលើញត្តិនេះទេ?"

អ្នកតបថា "ប្រហែលគាត់នឹងចាប់អារម្មណ៍ ឬប្រហែលជាអត់"។ អ្នកក៏ចាប់ផ្ដើមមានចម្ងល់អំពីគម្រោងនេះ។ អ្នកសួរថា "តើនេះមិនមែនជាអ្វីដែលមានតម្លៃក្នុងការសាកល្បងទេឬ? ទម្រាំដល់ មាននរណាម្នាក់មានគំនិតល្អជានេះ?"

នេះជាគំនិតល្អបំផុត ដែលអ្នកគ្រប់គ្នាបានបញ្ចេញយោបល់ ដូច្នេះក្រុមរបស់យើងបានសម្រេចចិត្តក្នុងការសាកល្បងវា។ ជាចុងក្រោយ យើងដូចជាមិនខាតបង់អ្វីឡើយ។ ដោយមានការពិភាក្សាបន្ថែមទៀត គម្រោងត្រូវបានបង្កើតឡើង ហើយគ្រប់គ្នាទទួលបានតួនាទីរៀងៗខ្លួន។ តួនាទីរបស់អ្នកគឺការសរសេរសេចក្ដីសង្ខេបអំពីអ្វីដែលកើតឡើងមកកាន់គ្រួសារអ្នក ដោយមានជាមួយនូវសំណូមពរសូមចុះហត្ថលេខាប្រសិនបើអ្នកគិតថាមិនយុត្តិធម៌។បន្ទាប់មកក្រដាសញត្តិនេះត្រូវបានគេបោះពុម្ពជាគំនរ រួចត្រូវបានបែងចែកទៅអ្នកស្ម័គ្រចិត្តទាំងអស់។

◈◈◈

នៅចុងសប្ដាហ៍បន្ទាប់ ពេលគឺពេញមួយចុងសប្ដាហ៍ គ្រប់គ្នានៅក្នុងក្រុមបានប្រើប្រាស់ពេលវេលាទំនេររបស់ពួកគេដើម្បីចេញក្រៅនិងចែកចាយញត្តិ។ សមាជិកក្រុមនីមួយៗត្រូវបានគេចាត់ឱ្យទៅតំបន់ផ្សេងៗគ្នានៃស្រុក។ គម្រោងនោះគឺថាពួកគេនឹងដើរពីផ្ទះមួយទៅផ្ទះមួយ ពីហាងមួយទៅហាងមួយទៀត និងដើរទៅកាន់មនុស្សម្នានៅលើដងវិថី។

ផលលំបាកផ្ទាល់ខ្លួនរបស់អ្នកនោះគឺថាអ្នកត្រូវព្យាយាមនិងប្រមូលហត្ថលេខាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយនេះក្លាយជាដំណើរស្វែងរករបស់អ្នក។រាល់ពេលដែលអ្នកទៅគោះទ្វារឬដើរសំដៅទៅកាន់អ្នកដែលនៅលើដងវិថី អ្នកសុំអង្វរពួកគេជាមួយភាពក្លៀវក្លារបស់អ្នក ដើម្បីសុំការសណ្ដោសប្រណីពីពួកគាត់។ ជាអំណរគុណណាស់ មនុស្សភាគច្រើនស្ដាប់អ្វីដែលអ្នកនិយាយ និងព្រមចុះហត្ថលេខា។ នេះប្រហែលជា ពួកគេយល់ឃើញថារឿងរ៉ាវមួយនេះពិតជាមានន័យដល់កម្រិតណាចំពោះអ្នក។

អ្នកខ្លះហាក់ដូចជាមិនចាប់អារម្មណ៍។ ពួកគេគ្រវីក្បាល ហើយនិយាយថា "អត់ត្រូវការទេ" ហើយដើរយ៉ាងលឿនទៅបិទទ្វារ។ អ្នកចង់ស្រែកថា "សូមមេត្តាស្ដាប់ខ្ញុំនិយាយសិន"។ ប៉ុន្តែអ្នកមិនធ្វើដូច្នោះទេ អ្នកព្យាយាមទប់ស្កាត់ការខកចិត្ត ហើយជំនួសមកវិញដោយស្នាមញញឹម។ រួចអ្នកនិយាយយ៉ាងច្បាស់បំផុត តាមដែលអ្នកអាចនិយាយបាននូវពាក្យ៖ "អរគុណ!"។

នេះជាការងារដ៏លំបាក។ តាមពិតទៅនេះជាការងារដ៏លំបាកបំផុតដែលអ្នកបានធ្វើ ហើយមានពេលខ្លះអ្នកឆ្ងល់ថា ថាតើអ្វីដែលអ្នកបានធ្វើពិតជាមាន

តម្លៃចំពោះការខិតខំប្រឹងប្រែងរបស់អ្នកឬក៏អត់។ បន្ទាប់មកអ្នកគិតដល់អ្នកស្ម័គ្រចិត្តនៅក្នុងក្រុមដែលបានលះបង់ពេលទំនេរដើម្បីជួយអ្នក និងអក្ខរា។

បន្ទាប់មកទៀត អ្នកក៏ដើរសំដៅទៅមនុស្សផ្សេងទៀតដើម្បីបន្តការងាររបស់អ្នក។

◈◈◈

ពេលជិតចុងសប្តាហ៍ អ្នកបានមកដល់ខាងក្រៅការិយាល័យកាសែតក្នុងស្រុកមួយ។ អ្នកបានសម្រេចចិត្តថាអ្នកនឹងចូលខាងក្នុងដើម្បីសុំហត្ថលេខាខ្លះ។

នៅទីនោះមានមនុស្សពីរបីនាក់ដែលអង្គុយនៅពីមុខកុំព្យូទ័រ អ្នកទាំងអស់នោះមើលទៅដូចជារវល់។ អ្នកដើរចុះឡើងបន្តិច ដោយសង្ឃឹមថាមាននរណាម្នាក់នឹងសម្គាល់ឃើញអ្នក។ ទីបំផុត មានអ្នកយកព័ត៌មានវ័យក្មេងម្នាក់មើលមកអ្នកបន្តិចរួចសួរថាតើនាងអាចជួយអ្វីបានខ្លះ។ អ្នកប្រាប់នាងថា អ្នកមានញត្តិ និងហត្ថលេខាដែលអ្នកប្រមូលបានយ៉ាងច្រើនតាមដែលអាចធ្វើទៅបាន។

ដៃចុចកុំព្យូទ័របណ្តើរ នាងសួរអ្នកថា “តើវាគឺជាអ្វីទៅ?”

អ្នកចាប់ផ្តើមប្រាប់នាងពីដំណើររឿង ប៉ុន្តែអ្នកមិនច្បាស់ថានាងកំពុងស្តាប់អ្នកឬក៏អត់ ព្រោះនាងបានផ្តោតអារម្មណ៍ទៅលើអេក្រង់កុំព្យូទ័រ។ តែនៅពេលដែលអ្នកនិយាយដល់ការស្លាប់របស់ឪពុកអ្នក ទើបគាត់ស្ទាក់ស្ទើរបន្តិច ហើយមើលមកអ្នក។ បន្ទាប់មក អ្នកប្រាប់នាងអំពីអក្ខរា និងស្ថានភាពរបស់គាត់ ហើយអ្នកអាចនិយាយបានថានាងចាប់ផ្តើមមានចំណាប់អារម្មណ៍បន្តិចម្តងៗ។

វាដូចជាមិនយូរទេ នៅពេលនាងបើកសៀវភៅ ហើយចាប់ផ្តើមសួរសំណួរអ្នក។ នាងសួរសំណួរជាស៊េរីដូចជា ខ្ចីលុយពីនរណា ព្រមទាំងអាជីបរបស់ឪពុកអ្នក ហើយនាងគូសវាសអ្វីដែលអ្នកបានឆ្លើយនៅក្នុងសៀវភៅរបស់នាង។

បន្ទាប់មក នាងសួរអ្នកថាតើ ពេលណាអ្នកមានបំណងប្រគល់ញត្តិទៅអភិបាលក្រុង។ នាងថានាងនឹងនៅទីនោះ និងថតរូបភាពខ្លះសម្រាប់ការសែតរបស់នាង។ នេះពិតជាព័ត៌មានដ៏អស្ចារ្យ! អ្នកប្រាប់នាងថាអ្នកនឹងឱ្យនាងដឹង។

វាហាក់ដូចជាមិនគ្រប់គ្រាន់ ដូច្នេះនាងព្យាយាមបញ្ចុះបញ្ចូលអ្នកផ្សេងទៀតឱ្យចុះហត្ថលេខា។អ្នកពិតជាសប្បាយចិត្តណាស់ដែលអ្នកបានដើរចូលក្នុងការិយាល័យនោះ!

◈◈◈

នៅចុងសប្តាហ៍ ក្រុមទាំងមូលបានជួបជុំគ្នាម្តងទៀតនៅក្លឹបយុវជនដើម្បីមើលថាញត្តិមានដំណើរការដល់ណាហើយ។ អ្នកពិតជាសប្បាយចិត្តចំពោះ

ចំនួនហត្ថលេខាដែលបាន ប៉ុន្តែអ្នកមិនដឹងថាសមាជិកក្រុមធ្វើវាដោយដល់ណានោះទេ។

នៅពេលអ្នកដើរចូលអ្វីដែលអ្នកកត់សម្គាល់នោះគឺថាអ្នកគ្រប់គ្នាអង្គុយជារង្វង់មូល បីដូចជាមានអារម្មណ៍ថាអាប់អួរ។

អ្នកសួរសូរិយាថា "អត់មានការឆ្លើយតបល្អមែនទេ?"

នាងកគ្រវីក្បាល ហើយបេះដូងអ្នកហាក់ជាធ្លាក់ចុះក្រោម។

អ្នកបន្តថា "តើពួកយើងបានហត្ថលេខាប៉ុន្មានដែរ?"

សូរិយាមើលញត្តិនៅខាងមុខនាង រួចនាងនិយាយ "បានតែបីទេ"

អ្នកស្ទើរតែមិនជឿ "បី?" អ្នករកបានច្រើនជាងហាសិប ឯពួកគេវិញរកបានតែបី។

បន្ទាប់មក អ្នកសង្កេតឃើញថាសូរិយា និងអ្នកឯទៀតព្យាយាមទប់ស្នាមញញឹម។

អ្នកសួរ "មានរឿងអ្វីហ្នឹង?"

រំពេចនោះ គ្រប់គ្នាក៏ផ្ទុះសំណើច។

សូរិយាសែក្រ "មិនមែនបីទេ ប៉ុន្តែគឺបីរយ!"

អ្នកយកដៃមកខ្ទប់មាត់រួចនិយាយថា "តើឯងនិយាយពិតអត់? នេះពិតជាអស្ចារ្យណាស់! ខ្ញុំបានជាងហាសិប"

សូរិយានិយាយ "ច្រើនជាងបីរយ ហាសិបហត្ថលេខា។ ការងារសប្តាហ៍នេះគឺមិនអន់ទេ!"។

អ្នកនិយាយ៖ "ពិតជាមិនអន់ទេ។ អរគុណអ្នកទាំងអស់គ្នាជាខ្លាំង។ សូមឱ្យខ្ញុំអរគុណអ្នកតាមរយៈការប៉ាវញ៉ាំទឹកដោះគោក្រឡុកនៅយប់នេះ"។

◈◈◈

មួយសប្តាហ៍ក្រោយ អ្នកទាំងអស់គ្នាបានជួបជុំគ្នា នៅការិយាល័យអភិបាលក្រុងដើម្បីប្រគល់ញត្តិ។ អ្នករាយការណ៍ព័ត៌មានម្នាក់នោះក៏នៅទីនោះតាមសន្យាដែរ នឹងបានផ្តិតយករូបភាពនាខណៈនោះផងដែរ។

អភិបាលក្រុងចេញពីការិយាល័យ ហើយអ្នកនិងសូរិយាក៏ប្រគល់ញត្តិទៅគាត់។ អ្នកសង្ឃឹមថាញត្តិនោះនឹងអាចទាញយកចំណាប់អារម្មណ៍អំពីកម្មវិធីដែល

អយុត្តិធម៌ និងដែលបានធ្វើបាបគ្រួសារជាច្រើន។ អ្នកក៏បានផ្ដល់អនុសាសន៍ថា ថ្ងៃណាមួយ នេះនឹងធ្វើឱ្យមានការផ្លាស់ប្ដូរនៃច្បាប់។

អភិបាលក្រុងឈរសម្រាប់ការថតរូប អរគុណអ្នកគ្រប់គ្នា រួចក៏ដើរចូលក្នុងវិញបាត់ទៅ។

អ្នកនៅឈរនៅទីនោះ រួចសូរិយាអោបអ្នកហើយនិយាយថា "ធ្វើបានល្អមែន"

ប៉ុន្តែអ្នកក៏បានដឹងថាអ្វីដែលអ្នករាល់គ្នាកំពុងតែគិតនោះគឺ "ឥឡូវនេះ មានរឿងអ្វីកើតឡើង?"

បន្ទាប់មក អ្នករាការណ៍ព័ត៌មានដើរសំដៅមកអ្នក អ្នកក៏សម្គាល់ឃើញថានាងកំពុងតែញញឹម។

នាងនិយាយថា "ខ្ញុំគិតថា ខ្ញុំមានរឿងល្អសម្រាប់អ្នកទាំងអស់គ្នា។"

ក្រុមទាំងមូលមកជួបជុំគ្នា ដោយចង់ដឹងថានាងនឹងនិយាយអំពីអ្វី។

នាងនិយាយថា "ដូចអ្វីដែលអ្នកទាំងអស់គ្នាបានដឹងរួចមកហើយ។ ខ្ញុំមានចំណាប់អារម្មណ៍ក្នុងការសរសេរអំពីញត្តិនេះ និងឥទ្ធិពលនៃកម្ចីប្រាក់ដែលជះមកលើគ្រួសារទាំងនោះ។ ខ្ញុំក៏ចង់បាន ព័ត៌មានពីលោកហ៊ុយដែរ ដូច្នេះខ្ញុំក៏ទៅជួបគាត់។

អ្នកនិយាយថា "ឱព្រះជាម្ចាស់អើយ អញ្ចឹងមានន័យថាគាត់ដឹងពីរឿងញត្តិនោះហើយ"

នាងងក់ក្បាល៖ "ចាស! គាត់ដឹង។ នៅពេលគាត់ឮខ្ញុំសរសេរអំពីដំណើររឿងនេះ គាត់មានអារម្មណ៍អាណិតគ្រួសាររបស់អ្នក"។

នេះគឺជាការភ្ញាក់ផ្អើលរបស់អ្នកយ៉ាងពិតប្រាកដ រួចអ្នកសួរ៖ "ដោយរបៀបណាទៅ?"។

នាងបន្តថា "បន្ទាប់ពីការពិចារណាយ៉ាងច្រើនរបស់គាត់ គាត់ក៏សម្រេចចិត្តចរចារម្ដងទៀតទាក់ទងនឹងល័ក្ខខ័ណ្ឌនៃកម"

អ្នកស្ទើរតែមិនជឿអ្វីដែលអ្នកស្ដាប់ឮ រួចអ្នកសួរ "ពិតមែនឬទេ?"

នាងបន្ត៖ "វាគឺជាការពិត"។ ស្របពេលនោះ នាងបើកសៀវភៅរបស់នាង រួចនិយាយថា "ខ្ញុំបានថែមទាំងសរសេរវា។ មើលទៅដូចជាបំណុលរបស់អ្នកត្រូវបានកាត់បន្ថយជាខ្លាំង"

អ្នកអោបអក្ខរា សូរិយា ព្រមទាំងអ្នកកាសែតរូបនោះ!

ភ្លាមនោះអ្នកគ្រប់គ្នាអបអរ លោតចុះលោតឡើង ស្រែកសប្បាយ។

រយៈពេលមួយវិនាទី អ្នកដើរចេញមកក្រៅពីហ្វូងមនុស្សបន្តិច ហើយមើលទិដ្ឋភាពទាំងនោះ។ តើនេះកើតឡើងដោយរបៀបណាទៅ? តើអ្នកដើរមកដល់ចំនុចនេះដោយរបៀបណាទៅ?

រួចអ្នកនឹកដល់សម្តីរបស់លោកតាវិធូថា "រួមគ្នាជាកម្លាំង"

អ្នកនិយាយតិចៗមកកាន់ខ្លួនអ្នក៖ "អរគុណលោកតាវិធូ"។

◈◈◈

អ្វីដែលអ្នកចាប់អារម្មណ៍នោះគឺថា លោកតាវិធូពិតបានមានឥទ្ធិពលលើអ្នកខ្លាំងណាស់ក្នុងរយៈពេលពីរខែចុងក្រោយនេះ។

សូរិយាបានប្រាប់អ្នកអំពីការស្លាប់របស់លោកតាវិធូ នៅពេលគាត់កំពុងសម្រាន្ត។ នេះជាដំណឹងសោកសៅ។

ប៉ុន្តែហាក់ជាមានការរំពឹងទុកមុន។ គ្មាននរណាម្នាក់ដឹងថាវិទូមានអាយុប៉ុន្មានឡើយ ប៉ុន្តែការគិតជារួមនោះគឺថាគាត់មានអាយុយ៉ាងតិចណាស់៩០ឆ្នាំ ឬប្រហែលជាចាស់ជាងនេះទៀតផង។ អ្នកសម្គាល់ឃើញថាថ្មីៗនេះ គាត់ហាក់បីជាធ្វើការយឺតជាងមុន។ នៅពេលនៅចម្ការឃ្មុំ អ្នកសម្គាល់ឃើញថាអ្នកគឺជាមនុស្សដែលធ្វើការកាន់តែច្រើន។

ពេលខ្លះអ្នកមានអារម្មណ៍ថាលោកតាវិធូកំពុងតែអង្គុយក្នុងម្លប់ឈើ ហើយសម្លឹងមើលអ្នកនិយាយអំពីឃ្មុំរបស់គាត់។

ដូច្នេះដំណឹងមរណៈភាពរបស់គាត់ គឺមិនគួរឱ្យភ្ញាក់ផ្អើលទេ។ ប៉ុន្តែអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺនៅពេលសូរិយានិយាយអំពីអ្វីដែលគាត់បានសរសេរនៅសំបុត្របណ្តាំមរតក។

សូរិយានិយាយថា "ឯងនឹងមិនជឿរឿងនេះទេ។ គាត់បានផ្ទេរមរតកទាំងអស់មកគ្រួសារឯង រួមបញ្ចូលទាំងចម្ការឃ្មុំ ឧបករណ៍ សំបុកឃ្មុំ និងគ្រប់យ៉ាងផ្សេងទៀត!"

នេះមិនមែនជាអ្វីដែលអ្នកធ្លាប់ស្រមៃនោះទេ។ នៅពេលអ្នកគិតអំពីវាអ្នកយល់ថាវាដូចជាត្រឹមត្រូវ។ អ្នកចាប់ផ្តើមដឹងថាគាត់បង្រៀនអ្នកគ្រប់យ៉ាង ដូចនេះអ្នកអាចចាប់យកការចិញ្ចឹមឃ្មុំជាមុខរបរជាលក្ខណៈគ្រួសារ។

◈◈◈

ម្តាយអ្នកក្លាយជាអ្នកមើលឃ្មុំ។ បើទោះជាដំបូងឡើយគាត់ខ្លាចឃ្មុំទិច តែ

ក្រោយមកយ៉ាងឆាប់រហ័ស គាត់ក៏ចូលចិត្តការងារនេះ។

អ្នកសប្បាយចិត្តក្នុងការចំណាយពេលបង្រៀនម្តាយអ្នក នូវអ្វីដែលវិទូបានបង្រៀនអ្នក។

ម្តាយអ្នកបាប្រ់អ្នកថា “ខ្ញុំនឹងយកការមើលឃុំជំនួសការនេសាទ នៅថ្ងៃណាក៏បាន”។

ទឹកឃ្មុំអាចផ្តល់ចរិកាដល់អ្នកច្រើនជាងការនេសាទ។ ប្រាក់ចំនូលរបស់អ្នក និងប្រាក់សងលោក ស្នេកគី បានជួយកាត់បន្ថយភាពតានតឹងនៃបញ្ហាហិរញ្ញវត្ថុរបស់គ្រួសារអ្នក។

នាល្ងាចមួយនៅចុងឆ្នាំសិក្សា សូរិយាបានអញ្ជើញអ្នកមកនិយាយនៅក្លឹបយុវជន។

នៅពេលនាងដើរចូលក្នុងក្លឹប នាងនិយាយថា“ខ្ញុំគិតថាអ្នកនឹងគិតថាវាជារឿងដែលគួរឱ្យចាប់អារម្មណ៍មួយ”

តែវាបែរទៅជា បងប្អូនរបស់ចន្ទលីណាដែលជាអ្នកនិយាយ។ នាងជាក្មេងស្រីដែលបានឆ្លងកាត់រឿងដ៏អាក្រក់ បន្ទាប់ពីធ្វើចំណាក់ស្រុកទៅរកការងារធ្វើ។ វាជារឿងដែលឈឺចាប់។ នាងធ្វើការនៅរោងចក្រអស់រយៈពេលពីរឆ្នាំ។ លក្ខខណ្ឌការងារគឺមិនល្អឡើយ ហើយប្រាក់ដែលទទួលបានក៏តិច តែនាងមិនអាចចាកចេញពីការងារនោះបាន។នាងក្លាយជាទាសកររបស់និយោជកចំណែកសុខភាពរបស់នាងគឺកាន់តែអាក្រក់ឡើង នាងមានសំណាងណាស់ដែលនាងមិនបានស្លាប់នៅទីនោះ។

នៅពេលត្រលប់មកផ្ទះវិញ អ្នកនិងសូរិយាបានឈប់នៅហាងកាហ្វេមួយដើម្បីផឹកភេសជ្ជៈខ្លះ។

ស្របពេលកំពុងផឹកភេសជ្ជៈ សូរិយានិយាយថា “ខ្ញុំច្បាស់ណាស់អ្នកពិតជារីករាយដែលមិនបានទៅធ្វើការនៅទីនោះ”

អ្នកតប “យ៉ាងហោចណាស់ខ្ញុំបានត្រៀមច្រើនជាងនាង ហើយខ្ញុំសូមអរគុណអ្នកនិងចន្ទលីណា”

អ្នកគិតអំពីអ្វីដែលបងប្អូនចន្ទលីណាបានឆ្លងកាត់ ពីថៅហ្វាយដែលគ្មានសីលធម៌។

អ្នកបន្តថា “ខ្ញុំគិតថាវាគួរឱ្យខកចិត្តណាស់ដែលមានមនុស្សជាច្រើនដែលមិនខ្វល់ទាល់តែសោះអំពីសុខុមាភាពអ្នកដ៏ទៃ ដរាបណាពួកគេអាចរកលុយ

បាន។មានអ្វីមួយដែលអាចកាត់បន្ថយបញ្ហាត្រូវអត់? លុយចំពោះពួកគេគឺសំខាន់ជាងមនុស្សដែលពួកគេជួល ទាំងនោះគឺជាជីវិតដែលពួកគេបំផ្លាញ"

សូរិយាមើលអ្នកហើយញញឹម។

អ្នកសួរ "មានរឿងអ្វី?"

នាងនិយាយ "ខ្ញុំមិនដែលឃើញអ្នកខឹងដូចនេះទេ តាំងពីមានរឿងជាមួយលោក ស្មេកគី"

អ្នកតបថា "ហ្នឹងជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយ។បំផ្លាញជីវិតអ្នកដ៏ទៃ ព្រោះចង់បានលុយបន្ថែម"

នៅពេលសូរិយាផឹកភេសជ្ជៈ អ្នកអាចនិយាយបានថា នាងកំពុងគិតពីរឿងអ្វីមួយយ៉ាងមុតមាំ។ ទីបំផុត នាងហាក់ដូចជាយល់រឿងមួយនោះ។

នាងនិយាយ "ឯងដឹងអត់? នេះជាអ្វីដែលឯងងប់ងល់ វាជាការតស៊ូដើម្បីរកយុត្តិធម៌។ ខ្ញុំអាចឃើញវានៅក្នុងកែវភ្នែករបស់អ្នក នេះជាអ្វីដែលជំរុញអ្នក"។

អ្នកគិតរឿងនេះបន្តិច រួចងក់ក្បាល "អញ្ចឹង ខ្ញុំគួរធ្វើអ្វីទៅ?"។

នាងបន្ត "នេះប្រហែលជាអ្វីមួយដែលអ្នកគួរគិតនឹងធ្វើសម្រាប់ជីវិតរបស់អ្នក?"

អ្នកតបថា "អ្នកចង់និយាយអំពីអ្វី? ពួកយើងនឹងធ្វើឱ្យហាងកាហ្វេរបស់យើងទាន់សម័យជាងគេបង្អស់នៅក្នុងស្រុកនេះ!"

សូរិយាញញឹមដាក់សេចក្ដីសាទររបស់អ្នក។

នាងនិយាយ "ស្តាប់ខ្ញុំសិន។ ការធ្វើឱ្យហាងកាហ្វេអ៊ីធឺណិតជោគជ័យគឺជាសុបិនរបស់ខ្ញុំ។ ខ្ញុំពិតជាក្លៀវក្លាចំពោះវា។ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយនោះគឺថា នៅទីបំផុត យើងរាល់គ្នាត្រូវតែដើរតាមសុបិនរបស់យើងរៀងៗខ្លួន។ ពួកយើងគួរធ្វើអ្វីដែលយើងចង់ធ្វើ ពីព្រោះពួកយើងនឹងធ្វើអ្វីៗផ្សេងទៀតដើម្បីសម្រេចវា។ យើងនឹងធ្វើបានល្អ។

អ្នកសួរ "ឯងមិនចង់បានខ្ញុំជាដៃគូររកស៊ីរបស់អ្នកទេហ្អេស?"

អ្នកធ្វើមុខដូចជាកូនឆ្កែតូចមួយដ៏កំសត់ជាងគេបង្អស់ ដែលនេះធ្វើឱ្យសូរិយាសើច។

នាងតប "ប្រាកដណាស់ខ្ញុំចង់បានឯងជាដៃគូរ! ប្រសិនបើឯងពិតជាចង់ធ្វើវា។ អ្វីដែលខ្ញុំចង់និយាយនោះគឺថាប្រសិនបើឯងមានចំនង់ចំនូលចិត្តនឹង

រឿងផ្សេង យើងមិនចង់ក្លាយជាអ្នកដែលរារាំងគោលដៅរបស់ឯងឡើយ។ មានតែប៉ុណ្ណឹង"

អ្នកនិយាយជាមួយស្នាមញញឹម "ឯងចង់ដេញយើងមែន? ឯងប្រហែលជារកបានដៃគូរផ្សេងទៀតហើយ តែពួកគេមិនអាចធ្វើឱ្យហាងយើងរីកចម្រើនដូចពួកយើងទេ!"

សូរិយាសើច ហើយកគ្រវីក្បាល។

"ឯងជាអ្នកកំប្លែង។ ដឹងខ្លួនអត់?"

អ្នកក៏សើចដែរ ប៉ុន្តែនៅខាងក្នុងអ្នកមានអារម្មណ៍ថាមានអ្វីមួយសំខាន់កើតឡើង។

◈◈◈

មួយឆ្នាំក្រោយមក មានរឿងជាច្រើនបានកើតឡើង ហើយអ្នកកំពុងអង្គុយនៅហាងលក់ទឹកដោះគោនិងទឹកឃ្មុំអមដោយសេវាកម្មអ៊ីនធឺណិត ហើយខំរកមើលអ្វីដែលអាចធ្វើទៅរួច ក្នុងការធ្វើឱ្យ ហាងលក់ទឹកដោះគោនិងទឹកឃ្មុំអមដោយសេវាកម្មអ៊ីនធឺណិតកាន់តែល្អឥតខ្ចោះ។

អ្នកនិយាយទៅសូរិយា "អ្នកណាអ្នកធ្វើវា?"

នាងញញឹម "សាកវាសិនទៅ បន្ទាប់មកខ្ញុំនឹងប្រាប់ថានរណា"

អ្នកក៏ផឹកវាបន្តិច វាមានរស់ជាតិល្អជាងរូបរាងវាទៅទៀត។

អ្នកនិយាយ "ខ្ញុំសូមទទួលស្គាល់ថា នេះពិតជាឆ្ងាញ់! ឆ្ងាញ់ជាងរបស់ដែលខ្ញុំធ្វើទៀត។ ខ្ញុំត្រូវតែដឹងនរណាជាអ្នកធ្វើវា"

សូរិយាមើលតាមប្រហោងមួយពីផ្ទះបាយ រួចស្រែក "មានមនុស្សម្នាក់ចង់ជួបបង"

បន្តិចក្រោយមក ណារិនក៏ចេញមកពីផ្ទះបាយ។

អ្នកបើកភ្នែកធំៗ ហើយឈាមក៏ច្រាលមកផ្ទៃមុខរបស់អ្នក។ អ្នកគាំងនិយាយស្ដីអត់ចេញ។

គាត់ចូលមកអង្គុយពីមុខអ្នក រួចនិយាយ "សុខសប្បាយអត់?"

អ្នកមើលទៅសូរិយាដែលកំពុងសប្បាយនឹងភាពភ្ញាក់ផ្អើលរបស់អ្នក "ខ្ញុំសុខសប្បាយជាធម្មតា។ អរគុណ។ ចុះបងវិញ?"

ណារិនងក់ក្បាល រួចនិយាយ៖ "ល្អហើយ! អរគុណ។ ប្អូនមិនដែលទៅទីក្រុងធំសោះ ប៉ុន្តែបងឮថាប្អូនឥឡូវរៀននៅសកលវិទ្យាល័យ មែនអត់?"

អ្នកនៅតែភ្ញាក់ផ្អើល រួចតប៖ "ចាស"

គាត់បន្តថា "រៀនយ៉ាងម៉េចហើយ? បងជឿថាប្អូនកំពុងតែរៀន ដូច្នេះប្អូនអាចកែតម្រូវអយុត្តិធម៌ក្នុងពិភពលោកបានត្រូវទេ?"

អ្នកសួរ៖ "បងមកដល់យូរប៉ុណ្ណាហើយ?"

គាត់តប៖ "ពីរបីសប្ដាហ៍ហើយ។ នេះជាវិស្សមកាលរបស់ពួកយើង ហើយបងមិននឹកស្មានសោះថាអាចជួបប្អូននៅទីនេះទេ"។

ណារិនញញឹម "បងត្រលប់មកផ្ទះវិញហើយ! បងធ្លាប់គិតថាបងនឹងត្រលប់មកវិញព្រោះបងមានរឿងអយុត្តិធម៌ជាច្រើនចង់ឱ្យប្អូនជួយកែតម្រូវ។ ព្រមជួយបងអត់?"

អ្នកតបទាំងញញឹមថា "ប្រហែលដែរ ចាំមើលសិន"

សូរិយានិយាយ "នែ!! តើពួកឯងដឹងអត់ថានេះធ្វើឱ្យខ្ញុំនឹកដល់អ្វីមួយ?ពេលណាទៅន៎?អូ!ពីរឆ្នាំមុន? ខ្ញុំចាំថាពួកយើងទាំងបីនាក់អង្គុយជុំវិញ រីករាយនឹងទឹកដោះគោក្រឡុក។ហើយឥឡូវនេះពួកយើងចាប់យកផ្លូវដើរខុសគ្នានិងជម្រើសផ្សេងគ្នា។ ឥឡូវជាថ្មីម្តងទៀត ពួកយើងអង្គុយជុំវិញ។ វាហាក់បីដូចជាគ្មានអ្វីផ្លាស់ប្តូរ។"

អ្នកញញឹម ហើយមើលជុំវិញហាងកាហ្វេ "បើតាមគំនិតខ្ញុំ អ្វីគ្រប់យ៉ាងពិតជាបានផ្លាស់ប្តូរ។ រឿងទីមួយនោះគឺថា សូមមើលមកកាន់កន្លែងដ៏អស្ចារ្យដែលអ្នកបានបង្កើតមួយនេះ ហើយមានខ្ញុំដែលជាមនុស្សតែម្នាក់ក្នុងចំណោមមនុស្សដែលរៀននៅសកលវិទ្យាល័យ តើអ្នកជឿអត់? ចុះអ្នកវិញ កំលោះទីក្រុង? ត្រឡប់មកកន្លែងអ្នកចាប់ផ្តើមវិញ?"

សូរិយាងក់ក្បាល៖ " ខ្ញុំគិតថាមានរឿងមួយឬពីរយ៉ាង ដែលបានផ្លាស់ប្តូរ។"

អ្នកលើកកែវទឹកដោះគោក្រឡុកឡើងរួចជុលជាមួយនឹងកែវរបស់មិត្តអ្នក។

"នេះសម្រាប់ការបង្កើតជម្រើសល្អ មិត្តល្អ និងសំខាន់ជាងគេនោះគឺការធ្វើទឹកដោះគោក្រឡុកដ៏សែនឆ្ងាញ់!"

**ចប់**





# សំណួរឆ្លុះបញ្ចាំង និងសង្ខេបសាច់រឿង

បន្ទាប់ពីអ្នកបានអានសៀវភៅនេះ និងរកឃើញអំពីលទ្ធផលផ្សេងៗនៃសាច់រឿង។ សំណួរឆ្លុះបញ្ចាំងទាំងនេះប្រហែលជាអាចជួយអ្នកក្នុងការដំណើរការសាច់រឿង ហើយប្រហែលជាអាចឱ្យអ្នកឃើញអ្វីដែលមានអត្ថន័យចំពោះជីវិតរបស់អ្នក។ អ្នកអាចឆ្លើយសំណួរទាំងនេះជាក្រុម ឬដោយម្នាក់ឯង។ តាមរយៈការឆ្លើយជាក្រុមឬជាលក្ខណៈបុគ្គល យើងអាចធ្វើឱ្យអ្នកគិតដល់អ្វីដែលអ្នកបានរៀនតាមរយៈបទពិសោធន៍ទាំងនេះ។

## សំណួរ

១. តើការជ្រើសរើសរបស់អ្នកទទួលបានលទ្ធផលអ្វី?

២. តើអ្នកមានការសោយចិត្តអ្វីខ្លះ បន្ទាប់ពីបានអានរឿងនេះចប់?

៣. តើអ្នកមានបានឆ្លងកាត់របត់ដែលមិនអ្នកបានរំពឹងទុកនៅក្នុងរឿងនេះដែរ ឬទេ? អ្វីខ្លះ ?

៤. ចូរពិពណ៌នាអំពីអារម្មណ៍របស់អ្នកមាន នៅពេលអ្នកជួបប្រទះភាពអយុត្តិធម៌បែបនោះ។

៥. ប្រសិនបើ អ្នកបានធ្វើការសម្រេចចិត្តជាក្រុម តើអ្នកពិភាក្សាគ្នាតាមរបៀបណា? តើអ្នកធ្វើការសម្រេចចិត្តជ្រើសរើសមួយណា ប្រសិនបើមានយោបល់ខុសគ្នាបែបនេះ?

៦. តើអ្នកទទួលបានអ្វីខ្លះតាមរយៈបទពិសោធទាំងអស់នេះ?

៧. ប្រសិនបើអ្នកអាចធ្វើការផ្លាស់ប្តូរអ្វីមួយបាន តើអ្នកចង់ឃើញលទ្ធផលបែបណា?

៨. តើអ្នកមានការសោកស្តាយដែលអ្នកបានធ្វើការសម្រេចចិត្តចំពោះតួឯក? ចូរអានជម្រើសទាំងឡាយដែលមាននៅក្នុងរឿង។

៩. តើអ្នកអាចគិតឃើញថាចាត់វិធានការអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកដើម្បីកុំឱ្យខ្លួនអ្នកធ្លាក់ចូលទៅក្នុងស្ថានភាពដ៏អាក្រក់ដូចស្ថានភាពនៅក្នុងសាច់រឿង?

អង្គការទស្សនៈពិភពលោកគឺជាអង្គការមនុស្សធម៌គ្រីស្តសាសនាដែលប្តេជ្ញាខិតខំប្រឹងប្រែងធ្វើការងារដើម្បីកុមារ គ្រួសារនិងសហគមន៍នានាក្នុងការតស៊ូជំនះនឹងភាពក្រីក្រនិងភាពអយុត្តិធម៌។ ដោយមានកម្លាំងចិត្តដែលកើតចេញពីជំនឿបែបគ្រីស្តសាសនា អង្គការទស្សនៈពិភពលោកបានប្តេជ្ញាខិតខំប្រឹងប្រែងធ្វើការងារ ដើម្បីជួយប្រជាជនដែលងាយរងគ្រោះក្នុងពិភពលោក។ អង្គការទស្សនៈពិភពលោកធ្វើការបម្រើមនុស្សទាំងឡាយដោយមិនប្រកាន់សាសនា ជាតិសាសន៍ ឬភេទនោះឡើយ។

កម្រងសៀវភៅ Vanguard៖ ត្រួសត្រាយផ្លូវថ្មីៗ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងការធ្វើ ចំណាកស្រុកដោយពុំមានសុវត្ថិភាព

រក្សាសិទ្ធិដោយអង្គការទស្សនៈពិភពលោកឆ្នាំ២០១៥

ISBN ៩៧៨-០-៩១៨២៦១-៥៣-៣

អ្នកនិពន្ធដោយ៖ Lan Pugh

រក្សាសិទ្ធិគ្រប់យ៉ាងរក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃសៀវភៅដែលបានបោះពុម្ពផ្សាយនេះអាច ត្រូវបានផលិតឡើងវិញក្នុងទម្រង់ណាមួយ ដោយពុំមានការអនុញ្ញាតពីអ្នកបោះពុម្ពផ្សាយជាមុនឡើយ លើកលែង តែការដកស្រង់សង្ខេបសម្រាប់យកទៅធ្វើការពិនិត្យផ្ទៀងផ្ទាត់ប៉ុណ្ណោះ។

រៀបចំ និងបោះពុម្ពផ្សាយដោយកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស (ETIP) ក្នុងនាមជាតំណាងនៃអង្គការ ទស្សនៈពិភពលោកអន្តរជាតិ ។

ចំពោះព័ត៌មានបន្ថែមអំពីការបោះពុម្ពផ្សាយនេះ ឬ ការបោះពុម្ពផ្សាយរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ឬប្រសិនបើត្រូវការច្បាប់ចម្លងបន្ថែមអំពីការបោះពុម្ពផ្សាយនេះសូមទាក់ទង wvi_publishing@wvi.org។

អង្គការទស្សនៈពិភពលោកអន្តរជាតិ សូមសំដែងនូវការកោតសរសើរចំពោះការទទួលយកសេចក្តីលម្អិតក្នុងឯកសារនេះ ជាប្រយោជន៍សម្រាប់ប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលស្រាវជ្រាវ រៀចំកម្មវិធីអនុវត្តកម្មវិធី ឬ វាយតម្លៃកម្មវិធី។

អ្នកគ្រប់គ្រងតំណាងឲ្យកម្មវិធី ETIP ៖ Amy Collins និពន្ធនាយក៖ Heather Elliott អ្នកគ្រប់គ្រងការបោះពុម្ព៖ Katie Klopman Fike អ្នកពិនិត្យកែសម្រួល៖ Katie Chalk អ្នកពិនិត្យអក្ខរាវិរុទ្ធ៖ Bob Newman អ្នកពិនិត្យខ្លឹមសារ៖ John Whan Yoon, Fei Wang, Le Thi Thanh Hang, Southasa Bousdy, Thanyathip Chatsawat, Ku Paw and Sophal Chea អ្នករចនាគម្របខាងក្រៅ និងទំព័រខាងក្នុង៖ Inis Communication អ្នករចនារូបភាព៖ Natasha Bautista and Rishi Mandhyan រៀបចំរចនា និងបោះពុម្ពដោយ Inis Communication – www.iniscommunication.com